IUCN

អភិបាលកិច្ចទឹក

ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម

ការពិគ្រោះយោបល់អំពីទឹកនៅតំបន់មេគង្គ

ULKOASIAINMINISTERIÖ
UTRIKESMINISTERIET

ការកំណត់តំបន់ភូមិសាស្ត្រនៅក្នុងឯកសារនេះ និងការរំលេចបែបនេះនៅក្នុងឯកសារនេះ មិនមានន័យថាជាការសំដែងយោបល់ពីអង្គការ IUCN ឬក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ឡើយ ទាក់ទងនឹងស្ថានភាពចំពោះមុខច្បាប់នៃប្រទេស ដែនដី ឬទីកន្លែង ឬ សមត្ថកិច្ចរបស់ខ្លួន ឬ ដែលទាក់ទងនឹងការកំណត់ព្រំប្រទល់ ឬ ព្រំដែនប្រទេស។ ទស្សនៈដែលបង្ហាញនៅក្នុងឯកសារនេះ ពុំសុទ្ធតែ ឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ អង្គការ IUCN ឬ
របស់ក្រសួងការបរទេសនៃប្រទេស
ហ្វាំងឡង់ឡើយ។ របាយការណ៏នេះជាការសំយោគរបាយការណ៏ចំនួនបី របស់ទីប្រឹក្សា ដែលបានរៀបចំឡើងនៅក្នុងឆ្នាំ 2008 -2009 សម្រាប់កម្មវិធីពិគ្រោះយោបល់អំពីទឹកប្រចាំតំបន់មេគង្គ ដែលសំរបសំរួលដោយអង្គការ IUCN ពុំធានាអំពីសុក្រឹត្យភាព ឬ ភាពពេញលេញនៃព័ត៌មាននេះឡើយ ហើយអង្គការ IUCN ឬនិយោជិតរបស់ខ្លួន មិនទទួលខុសត្រូវចំពោះការបង់ខាត ឬ ការខូចខាតណាមួយ ដែលអាចកើតចេញពីការពឹងផ្អែកលើព័ត៌មានដែលមានបង្ហាញជូននេះឡើយ។
ការបោះពុម្ពនេះបានធ្វើឡើងដោយមានការគាំទ្រមួយផ្នែកពីក្រសួងការបរទេសនៃ ប្រទេសហ្វាំងឡង់។

បោះពុម្ពដោយ : អង្គការ IUCN ស្នាក់ការធំ ទីក្រុង Gland ប្រទេសស្វីស និងបាងកក ប្រទេសថៃ

រក្សាសិទ្ធ : © 2009, សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ។
ការផលិតឡើងវិញនូវឯកសារនេះ ក្នុងគោលបំណងអប់រំ ឬ មិនសម្រាប់ពាណិជ្ជកម្ម អាចអនុញ្ញាតឱ្យធ្វើបានដោយពុំចាំបាច់មានការអនុញ្ញាតជាលាយលក្សអក្សរពីម្ចាស់រក្សាសិទ្ធិឡើយ ក្នុងករណីដែលមានចុះសេចក្តីយោងបានពេញលេញ។
ការផលិតឡើងវិញនូវ ឯកសារនេះសម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀតត្រូវហាមឃាត់ ប្រសិនបើគ្មានការអនុញ្ញាតជាលាយលក្សអក្សរជាមុនពីម្ចាស់រក្សាសិទ្ធិ។

ការដកស្រង់ : S. Turner, G. Pangare, and R.J. Mather (2009), eds. *Water Governance: A situational analysis of Cambodia, Lao PDR and Vietnam.* Mekong Region Water Dialogue Publication No. 2 Khmer translation. Gland, Switzerland: IUCN. 49 pp.

ISBN: 978-2-8317-1266-6

រូបថតលើក្រប : Ganesh Pangare, IUCN, Bangkok

រចនាបថអត្ថបទ: Binayak Das

ផលិតដោយ: IUCN Asia Regional Water and Wetlands Programme

ផ្តល់មូលនិធិដោយ : ក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ និងអង្គការ IUCN

របាយការណ៍នេះអាចរកបានពី:

នាយកសម្របសម្រួល កម្មវិធីទឹក និងតំបន់ដីសើមនៃអង្គការ IUCN ប្រចាំតំបន់អាស៊ី
អាស័យដ្ឋាននៃការិយាល័យ:

63 Sukhumvit, Soi 39, Sukhumvit Road, Wattana,
Bangkok 10110 Thailand.
Tel + 66 2 662 4029

អភិបាលកិច្ចទឹក

ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម

ការពិគ្រោះយោបល់អំពីទឹកនៅតំបន់មេគង្គ

មាតិកា

ពាក្យបំព្រួញ 2

សេចក្តីសង្ខេបប្រតិបត្តិ 4

១. សេចក្តីផ្តើម 10

២. កម្ពុជា 12

២.១ ទិដ្ឋភាពរួម 12

២.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងខាងស្ថាប័ន 12

២.៣ ស្ថានភាពនៃវិស័យនានា 19

២.៤ ការសន្និដ្ឋាន-ឧបសគ្គ និងអនុសាសន៍ 22

៣. ប្រទេសឡាវ 25

៣.១ ទិដ្ឋភាពរួម 25

៣.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងស្ថាប័ន 25

៣.៣ ស្ថានភាពនៅចំពោះមុខច្បាប់នៃវិស័យនានា 29

៣.៤ សេចក្តីសន្និដ្ឋាន ឧបសគ្គ និងអនុសាសន៍ 32

៤. ប្រទេសវៀតណាម 35

៤.១ ទិដ្ឋភាពរួម 35

៤.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងស្ថាប័ន 35

៤.៣ ស្ថានភាពនៃវិស័យនានា 39

៤.៤ ការសន្និដ្ឋាន ឧបសគ្គ និងអនុសាសន៍ 43

៥. អនុសាសន៍ និងការសន្និដ្ឋាន 46

៥.១ បញ្ហាគន្លឹះ 46

៥.២ អនុសាសន៍សម្រាប់ MRWD 49

ឯកសារយោង 52

តារាង

តារាងទី ១. ការចាត់ចែងស្ថាប័ននៅកម្ពុជា 16
តារាងទី ២. របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ចនៅប្រទេសកម្ពុជា 23
តារាងទី ៣. ផ្ទៃដីស្រោចស្រពរវាងឆ្នាំ 1991 –2003, ប្រទេសឡាវ 29
តារាងទី ៤. របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅប្រទេសឡាវ 34
តារាងទី ៥. ការចាត់ចែងខាងស្ថាប័ន នៅប្រទេសវៀតណាម 37
តារាងទី ៦. របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅប្រទេសវៀតណាម 44
តារាងទី ៧. តារាងសង្ខេប - របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច 46

ពាក្យបំព្រួញ

ADB	Asian Development Bank	ធនាគារអភិវឌ្ឍន៍អាស៊ី
BDP	Basin Development Plan	ផែនការអភិវឌ្ឍន៍អាងទន្លេ
BOD	Biochemical Oxygen Demand	តម្រូវការអុកស៊ីសែនសម្រាប់ប្រតិកម្មគីមីជីវសាស្ត្រ
CANTA	Cambodia National Tourist Authority	អាជ្ញាធរទេសចរណ៍ជាតិកម្ពុជា
CBDRM	Community-Based Disaster Risk Management	ការគ្រប់គ្រងគ្រោះភ័យនៃគ្រោះធម្មជាតិដោយសហគមន៍
CC	Climate Change	ការប្រែប្រួលអាកាសធាតុ
CDC	Commune Development Council	ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ
CFDO	Community Fisheries Development Office	ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ
CNMC	Cambodia National Mekong Committee	គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
DARD	Department of Agriculture and Rural Development	នាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងជនបទ
EAC	Electricity Authority of Cambodia	អាជ្ញាធរអគ្គិសនីកម្ពុជា
EDC	Electricité Du Cambodge	អគ្គិសនីកម្ពុជា
ESI	Environment Sustainability Index	សន្ទស្សន៍និរន្តរភាពបរិស្ថាន
FiA	Fishery Administration	រដ្ឋបាលជលផល
FiC	Fishery Community	សហគមន៍នេសាទ
FMMP	Flood Management and Mitigation Programme	កម្មវិធីគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់
FWUC	Farmer Water User Community	សហគមន៍អ្នកប្រើប្រាស់ទឹក
GDP	Gross Domestic Product	ផលិតផលក្នុងស្រុកសរុប
GWP	Global Water Partnership	ដៃគូពិភពលោកសម្រាប់ទឹក
IDMC	Irrigation and Drainage Management Company	ក្រុមហ៊ុនគ្រប់គ្រងធារាសាស្ត្រ និងប្រព័ន្ធដោះទឹក
IFReDI	Inland Fisheries Research and Development Institute	វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
IWRM	Integrated Water Resources Management	ការគ្រប់គ្រងធនធានទឹកចម្រុះ
LNMC	Lao National Mekong Committee	គណៈកម្មាធិការជាតិទន្លេមេគង្គឡាវ
LWR	Law on Water Resources	ច្បាប់ស្តីពីធនធានទឹក
MAFF	Ministry of Agriculture, Forestry and Fisheries	ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
MARD	Ministry of Agriculture and Rural Development	ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ
MCTPC	Ministry of Communication, Transportation, Post and Construction	ក្រសួងគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់
MEF	Ministry of Economy and Finance	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MIH	Ministry of Industry and Handicraft	ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
MIME	Ministry of Industry, Mines and Energy	ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
MOC	Ministry of Construction	ក្រសួងសំណង់
MOE	Ministry of Environment	ក្រសួងបរិស្ថាន
MOH	Ministry of Health	ក្រសួងសុខាភិបាល
MONRE	Ministry of Natural Resources and Environment	ក្រសួងធនធានធម្មជាតិ និងបរិស្ថាន
MOST	Ministry of Science and Technology	ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

MoT	Ministry of Tourism	ក្រសួងទេសចរណ៍
MOT	Ministry of Transport	ក្រសួងដឹកជញ្ជូន
MOTI	Ministry of Trading and Industry	ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម
MOWRAM	Ministry of Water Resources and Meteorology	ក្រសួងធនធានទឹក និងឧតុនិយម
MPH	Ministry of Public Health	ក្រសួងសុខភាពសាធារណៈ
MRC	Mekong River Commission	គណៈកម្មការទន្លេមេគង្គ
MRD	Ministry of Rural Development	ក្រសួងអភិវឌ្ឍន៍ជនបទ
MRWD	Mekong Region Water Dialogues	កិច្ចពិគ្រោះយោបល់អំពីទឹកនៅតំបន់មេគង្គ
MTT	Ministry of Trade and Tourism	ក្រសួងពាណិជ្ជកម្ម និងទេសចរណ៍
MW	Mega Watts	មេហ្គាវ៉ាត់
NGO	Non-Governmental Organisation	អង្គការមិនមែនរដ្ឋាភិបាល
NSDP	National Strategic Development Plan	ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
NTP	National Target Program	កម្មវិធីចំណុចដៅរបស់ជាតិ
NWG	National Working Group	ក្រុមការងារថ្នាក់ជាតិ
NWRC	National Water Resources Council	ក្រុមប្រឹក្សាធនធានទឹកជាតិ
NWRP	National Water Resources Policy	គោលនយោបាយធនធានទឹកជាតិ
NWRS	National Water Resources Strategy	យុទ្ធសាស្ត្រធនធានទឹកជាតិ
PARDS	Provincial Agriculture and Rural Development Service	មន្ទីរកសិកម្ម និងសេវាកម្មអភិវឌ្ឍន៍ជនបទខេត្ត
PIMD	Participatory Irrigation Management Development	ការគ្រប់គ្រង ការអភិវឌ្ឍន៍ធារាសាស្ត្រដោយមានការចូលរួម
PPC	Provincial Peoples Committee	គណៈកម្មាធិការប្រជាជនខេត្ត
RBM	River Basin Management	ការគ្រប់គ្រងអាងទន្លេ
RBO	River Basin Organisation	អង្គការអាងទន្លេ
RWSS NTP	Rural Water Supply and Sanitation National Target Programme	កម្មវិធីចំណុចដៅជាតិ ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ
SA	Sub-Area	អនុតំបន់
SAWG	Sub-Area Working Group	ក្រុមការងារអនុតំបន់
SEDP	Sustainable Energy Development Program	កម្មវិធីអភិវឌ្ឍន៍ថាមពលដោយនិរន្តរភាព
SNV	The Netherlands Development Organization	អង្គការអភិវឌ្ឍន៍នៃប្រទេសហូឡង់
STEA	Science, Technology and Environment Agency	ទីភ្នាក់ងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន
UNDP	United Nations Development Programme	កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
UNESCO	United Nations Educational, Scientific and Cultural Organization	អង្គការសហប្រជាតិដើម្បី ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌
VDC	Village Development Committee	គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
VND	Vietnamese Dong	ប្រាក់ដុងវៀតណាម
VNWP	Vietnam National Water Partnership	ដៃគូថ្នាក់ជាតិស្តីពីទឹកនៃប្រទេសវៀតណាម
WRCC	Water Resources Coordinating Committee	គណៈកម្មាធិការសម្របសម្រួលធនធានទឹក
WREA	Water Resources and Environment Administration	រដ្ឋបាលធនធានទឹក និងបរិស្ថាន
WSUG	Water and Sanitation User Group	ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ
WUO	Water Users' Organisation	អង្គការអ្នកប្រើប្រាស់ទឹក

សេចក្តីសង្ខេបប្រតិបត្តិ

តំបន់មេគង្គ ដែលគ្របដណ្តប់ដែនដីនៃប្រទេសកម្ពុជា ឡាវ វៀតណាម ថៃ ភូមា និងតំបន់ស្វយ័តទីបេត៍ ខេត្តយុនណាន គីងហៃ និងក្វាងស៊ីនៃប្រទេសចិន [1] គឺជាតំបន់សេដ្ឋកិច្ចមួយក្នុងចំណោមតំបន់នានាដែលរីកចម្រើនយ៉ាងឆាប់រហ័សនៃពិភពលោក ។ ក្នុងចំណោមប្រជាពលរដ្ឋចំនួនសរុប 300 លាននាក់នៃតំបន់នេះ ប្រជាជនច្រើនជាង 100 លាននាក់ ពឹងផ្អែកលើជលផល និងផលិតផល និងសេវាកម្មផ្សេងៗទៀត នៃប្រព័ន្ធទន្លេសំខាន់ៗ (ឡាន់ឆាង-មេគង្គ នូ-សាល់វីន ភាគខាងលើនៃទន្លេយ៉ាងហ្សេ អ៊ីរ៉ាវ៉ាឌី ចៅប្រាយ៉ា ទន្លេរ៉េត) ទន្ទឹមនឹងកំណើននៃការប្រើប្រាស់ធនធានទឹកសម្រាប់ពាណិជ្ជកម្ម ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធទឹក និងការបំពុលទឹកបាននឹងកំពុងកើនឡើង ។

វេទិការពិគ្រោះយោបល់អំពីទឹកតំបន់ទន្លេមេគង្គ (MWD) ដែលបានបង្កើតឡើងដោយអង្គការសហប្រជាជាតិដើម្បី អភិរក្សធម្មជាតិ (IUCN) និងដែលមានការគាំទ្រដោយក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ បាននឹងកំពុងចាប់ផ្តើមធ្វើការជាមួយប្រទេសនានានៅក្នុងតំបន់មេគង្គ ដើម្បីធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចទឹក ដោយសម្រួលឱ្យមានការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងធ្វើអោយកាន់តែប្រសើរឡើងក្នុងការប្រកបរបរចិញ្ចឹមជីវិត សុខភាពមនុស្សជាតិ និងសុវត្ថភាពប្រព័ន្ធអេកូឡូស៊ី ។ កម្មវិធីនេះ មានគោលដៅធ្វើអោយប្រសើរនូវដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅជុំវិញការគ្រប់គ្រង និងការអភិរក្សធនធានទឹកក្នុងតំបន់មេគង្គ និងដើម្បីផ្តល់ឱកាសដល់រដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិលចូលរួមនៅក្នុងវេទិការ និងដើម្បីភ្ជាប់នូវទស្សនៈទានខុសៗគ្នានានាអំពីការអភិវឌ្ឍន៍ទឹក ។

យុទ្ធសាស្ត្ររបស់ MWD គឺដើម្បីអភិវឌ្ឍន៍ផែនការនៃប្រទេសដែលស្ថិតនៅក្នុងអនុតំបន់ទន្លេមេគង្គ និងភ្ជាប់ដំណើរការនៃវេទិការតំបន់ អោយមានការផ្លាស់ប្តូរព័ត៌មានកាន់តែល្អជាងមុន ព្រមទាំងការផ្លាស់ប្តូរចំណេះដឹង ចលនានៃការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធកាន់តែទូលំទូលាយ និងកំណើនការទទួលស្គាល់អំពីការពាក់ព័ន្ធគ្នាទៅវិញទៅមកនៃបញ្ហានានា។ នៅក្រោមកម្មវិធីនេះក្រុមការងារថ្នាក់ជាតិ (NWGs) ដែលជាអ្នកជំនាញការតំណាងអោយរដ្ឋាភិបាល សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល (NGOs) ផ្នែកឯកជន និងគ្រឹះស្ថានអប់រំ/ស្ថាប័នស្រាវជ្រាវ ត្រូវបានបង្កើត ឡើងដើម្បីកសាងយុទ្ធសាស្ត្រក្នុងការអនុវត្តវេទិការទឹកតំបន់ទន្លេ មេគង្គក្នុងប្រទេសនីមួយៗ។

ដើម្បីកំណត់បញ្ហាគន្លឹះនានា ទីប្រឹក្សាក្នុងស្រុកត្រូវបានជ្រើសរើសអោយធ្វើការនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម រវាងខែតុលា ឆ្នាំ2008 និងខែមករា ឆ្នាំ2009 ដើម្បីរៀបចំសិក្សាវិភាគស្ថានភាពនៅក្នុងប្រទេសនីមួយៗ ។ ការសិក្សានេះ បានធ្វើការវាយតំលៃទៅលើរចនាសម្ព័ន្ធគោលនយោបាយអភិបាលកិច្ចទឹកដែលមានស្រាប់ ភាពត្រឹមត្រូវតាមផ្លូវច្បាប់ រចនាសម្ព័ន្ធបញ្ញត្តិច្បាប់ ស្ថាប័ន និងមូលដ្ឋាននៃការធ្វើសេចក្តីសំរេចចិត្តនានា សំរាប់ប្រទេសនៃអនុតំបន់មេគង្គ ។ ការសិក្សានានាត្រូវបានប្រើប្រាស់ដើម្បីជួយ NWGs ក្នុងការធ្វើអត្តសញ្ញាណបញ្ហាជាគន្លឹះនៃអភិបាលកិច្ចទឹកសម្រាប់ប្រទេសនីមួយៗ និងផ្តល់អនុសាសន៍លើប្រធានបទ ដែលពាក់ព័ន្ធនានាសម្រាប់វេទិការឆ្នាំ 2009-2010 និងលើកយកនូវគោលការណ៍សំខាន់ៗនៃទំហំនៃការងារ សំរាប់ធ្វើអោយកាន់តែប្រសើរឡើងនូវអភិបាលកិច្ចទឹក ។ លទ្ធផលដែលបានមកពីការសិក្សាវិភាគទាំងនោះនឹងត្រូវបានប្រើប្រាស់ដើម្បីតំណាងអោយ NWG ក្នុងការរៀបចំផែនការនានា និងការអនុម័ត និងការគាំទ្រ ។ បន្ទាប់ពីនេះ មានការប្រជុំពហុអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ ដែលតំណាងមកពីរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល (NGO) តំណាងសហគមន៍ គ្រឹះស្ថានសិក្សា/ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន ដើម្បីចាត់បញ្ហានានាជាអាទិភាព និងឯកភាព

---

1 ADB រួមបញ្ចូលខេត្តយុនណាន និងក្វាងស៊ីនៃប្រទេសចិន នៅក្នុងនិយមន័យរបស់ខ្លួនអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ចនៃ GMS ចំណែកអាងជាក់ស្តែងនៅក្នុងទន្លេមេគង្គ រួមបញ្ចូលផ្នែកនានានៃតំបន់ស្វយ័តទីបេត៍ (TAR) និងខេត្តគីងហៃ។ ដូច្នេះ យើងទទួលយកនិយមន័យធំទូលាយជាងគេ អំពីតំបន់មេគង្គ ដោយរួមបញ្ចូលខេត្តទាំងបួននេះ។

លើប្រធានបទសំខាន់ៗសម្រាប់ការពិនិត្យជាបន្ថែម សម្រាប់អំឡុងឆ្នាំ 2009 និង 2010 ។

វិស័យនានាដែលបានពិនិត្យនៅក្នុងប្រទេសនីមួយៗបានធ្វើឡើងតាមលក្ខខណ្ឌយោងដែលបានឯកភាពដោយ NWGs នៃប្រទេសនីមួយៗ ។ បញ្ហាពាក់ព័ន្ធ និងអភិបាលកិច្ចទឹក មិនដែលបានលើកឡើងនៅក្នុងការសិក្សាណាមួយទាំងនេះទេ ដូចជា ការថែរក្សានូវលំហូរបរិស្ថាន (ការអភិវឌ្ឍន៍អាងទន្លេ និងការថែរក្សាភាវៈមានជីវិតដែលមាននៅក្នុងទន្លេ) និងការគ្រប់គ្រងតំបន់ដីសើម ។ អង្គការ IUCN ទទួលស្គាល់អំពីសារៈសំខាន់នៃលំហូរបរិស្ថានក្នុងការទ្រទ្រង់ដល់ការប្រើប្រាស់ធនធានទឹកប្រកបដោយសមធម៌ និងដោយនិរន្តរភាព ព្រមទាំងចាត់ទុកថាជាធាតុសំខាន់មួយនៅក្នុងការអភិវឌ្ឍធនធានទឹកប្រកបដោយការទទួល ខុសត្រូវលើបរិស្ថាន ។ បើទោះជាបែបនេះក៏ដោយ កត្តាទាំងនេះមិនត្រូវបានកំណត់ជាប្រធានបទពាក់ព័ន្ធសម្រាប់ NWGs ពិចារណាឡើយ ហេតុដូចនេះវាមិនត្រូវបាននិយាយនៅក្នុងផ្នែកណាមួយទាល់តែសោះនៃការសិក្សាទាំងបីនោះ ។ ការគ្រប់គ្រងតំបន់ដីសើមក៏មិនត្រូវបានបញ្ចូលទៅក្នុងការសិក្សាទាំងនេះដែរ ដោយសារថាអង្គការ IUCN កំពុងស្ថិតក្នុងដំណើរការរៀបចំការចេញផ្សាយដាច់ដោយឡែកមួយ ដែលនឹងធ្វើការពិចារណាជាពិសេសអំពីបញ្ហាអភិបាលកិច្ចទឹក ដែលទាក់ទងជាមួយការគ្រប់គ្រងតំបន់ដីសើមនៅក្នុងតំបន់ មេគង្គ សំរាប់ការបោះពុម្ពផ្សាយនៅឆ្នាំ 2010 ។

វិស័យគន្លឹះដែលបានពិនិត្យមើលនៅក្នុងប្រទេសទាំងបីគឺ :

វិស័យ	កម្ពុជា	ឡាវ	វៀតណាម
ប្រព័ន្ធធារាសាស្ត្រ	X	X	X
ជលផល និងវារីវប្បកម្ម	X	X	X
វារីអគ្គិសនី និងថាមពល	X	X	X
ទេសចរណ៍ និងនាវាចរណ៍	X	X	X
ការផ្គត់ផ្គង់ទឹក និងអនាម័យ	X	X	X
ឧស្សាហកម្ម និងភូមិសិប្បកម្ម			X

របាយការណ៍សំយោគនេះ បង្ហាញអំពីលទ្ធផលសំខាន់ៗពីការសិក្សាទាំងបី និងអធិប្បាយអំពីបញ្ហាខ្លះៗ ភាពខុសគ្នា និងភាពដូចគ្នារវាងប្រទេសទាំងបី ។ យើងសង្ឃឹមថា របាយការណ៍នេះនឹងផ្តល់ជាមធ្យោបាយសម្រាប់ធ្វើការកំណត់នូវឱកាស សម្រាប់ប្រទេសនានា ក្នុងការចែករំលែកព័ត៌មាន និងសិក្សាអំពី ប្រទេសជិតខាងរបស់ខ្លួន នៅក្នុងការដោះស្រាយបញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹងទឹក និងការប្រឈមនានានៃការអភិវឌ្ឍន៍។

បញ្ហាគន្លឹះ

ការសន្និដ្ឋានរួមសំខាន់បំផុត មានដូចតទៅ :

១. ការគ្រប់គ្រងធនធានទឹក កំពុងធ្វើឡើងទៅតាមវិស័យដោយឡែកពីគ្នា ប៉ុន្តែពុំមានលក្ខណៈចម្រុះឡើយ។

បច្ចុប្បន្ននេះគោលការណ៍នានានៃការគ្រប់គ្រងចម្រុះធនធានទឹក (IWRM) បានត្រឹមតែរៀបចំ និងណែនាំដល់អ្នកពាក់ព័ន្ធប៉ុណ្ណោះ តែការដែលបានអនុវត្តនៅមានកំរិត ។

- អង្គការអាងទន្លេត្រូវបានបង្កើតឡើងសម្រាប់ទន្លេមួយចំនួនតូច នៅក្នុងប្រទេសទាំងបី តែបទពិសោធន៍ និងប្រសិទ្ធិមកទល់ពេលនេះនៅមានកម្រិតកំណត់នៅឡើយ ។
- ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEAs) ទើបតែបានចាប់ផ្តើមនៅពេលថ្មីៗនេះប៉ុណ្ណោះ សម្រាប់ជាឧបករណ៍ដើម្បីគាំទ្រដល់ការកសាងផែនការ ឱ្យកាន់តែមានលក្ខណៈចម្រុះនៅក្នុងអាងទន្លេ។ ការកំណត់ស្តង់ដារ សម្រាប់ SEAs ត្រូវតែបង្កើតឡើង និងកែលម្អការអនុវត្ត ។

២. ក្នុងពេលដែលគោលនយោបាយត្រូវបានកែលម្អ និងក្របខ័ណ្ឌច្បាប់ត្រូវបានផ្តួចផ្តើមនៅក្នុងវិស័យជាច្រើន ភាពខ្វះចន្លោះនៅតែត្រូវបានរកឃើញ និងតំរូវអោយមានធ្វើការដោះស្រាយ ហើយនៅក្នុងករណីទាំងអស់នៃការដំណើរការបញ្ចូលច្បាប់នានាទៅក្នុងសកម្មភាពការងារទើបតែចាប់ផ្តើម ដូច្នេះការងារទាំងនេះទាមទារឱ្យធ្វើការកែលម្អបន្ថែមទៀត ។

- ប្រទេសឡាវនៅពុំទាន់មានគោលការណ៍សម្រាប់ការកសាង

គោលនយោបាយជាតិជារួមស្តីពីទឹក ដែលកំណត់អំពីថាតើរដ្ឋាភិបាលចង់អភិវឌ្ឍន៍ និងគ្រប់គ្រងទឹករបស់ខ្លួនបែបណា នៅឡើយទេ។ នៅប្រទេសវៀតណាមគោលនយោបាយជាតិនៅពុំទាន់បញ្ជាក់ជំហរច្បាស់លាស់នៅឡើយទេ អំពីទិដ្ឋភាពជាច្រើននៃការគ្រប់គ្រងទឹកដូចជាការបែងចែក/ការចែក រម្លែកទឹកនៅក្នុងរដូវរាំងស្ងួត ការប្រើប្រាស់លំហូរបរិស្ថាន និង ការរក្សាទន្លេឱ្យមានស្ថានភាពល្អ។ ផ្ទុយទៅវិញនៅកម្ពុជា មានគោលនយោបាយជាតិទូលំទូលាយស្តីអំពីធនធានទឹកឆ្នាំ 2004 ប៉ុន្តែក៏នៅតែមានភាពខ្វះចន្លោះ ដែលចាំបាច់ត្រូវដោះស្រាយផងដែរ។

- វៀតណាម និងឡាវ មានច្បាប់រៀងខ្លួនមួយ ស្តីពីធនធានទឹក (ឆ្នាំ 1998 និង 1999) ដែលច្បាប់ទាំងពីរនៅត្រូវការឱ្យកែលម្អបន្ថែម និងធ្វើបច្ចុប្បន្នភាព ចំណែកកម្ពុជាមានច្បាប់ល្អមួយស្តីពីការគ្រប់គ្រងធនធានទឹក (2007) ដែលមានលក្ខណៈទូលំទូលាយជាង។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិប្រើប្រាស់ទឹកនៅពុំទាន់បានចែងច្បាស់លាស់នៅឡើយទេ នៅក្នុងប្រទេសនីមួយៗ ក្នុងចំណោមប្រទេសទាំងបីនេះ។
- ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសំរាប់អភិវឌ្ឍន៍ ថាមពលវារីអគ្គិសនីត្រូវការឱ្យកែលម្អបន្ថែមសម្រាប់គ្រប់ប្រទេសទាំងអស់នៃអនុតំបន់ទន្លេមេគង្គ។ ការបើកចំហ ការផ្សព្វផ្សាយព័ត៌មាន និងការលើកទឹកចិត្តដល់អ្នករងគ្រោះ ដែលរងគ្រោះពីការកសាងទំនប់វារីអគ្គិសនីទៅក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ត្រូវតែកែលម្អនូវរាល់ករណីទាំងអស់ ។
- បើទោះជាប្រទេសកម្ពុជាមានគោលនយោបាយជាតិ សម្រាប់វិស័យផ្គត់ផ្គង់ទឹកនិងអនាម័យ(2004)ហើយក៏ដោយ ក៏ប្រទេសនេះត្រូវរៀបចំយុទ្ធសាស្ត្ររួម ដើម្បីអនុវត្តគោលនយោបាយដែលមានស្រាប់ និងត្រូវអនុម័តច្បាប់ស្តីពីអនាម័យផងដែរ។
- នៅក្នុងប្រទេសកម្ពុជា ច្បាប់ជលផលឆ្នាំ (2006) និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ផ្តល់ជាមូលដ្ឋានដ៏ល្អ សំរាប់ដោះស្រាយ និងគ្រប់គ្រងបញ្ហា នៅក្នុងការប្រើប្រាស់ធនធានជលផលទឹកសាប ចំណែកនៅក្នុងប្រទេសឡាវវិញ សេចក្តីព្រាងច្បាប់ជលផលឆ្នាំ(2009) កំពុងស្ថិតក្រោមការពិចារណានៅឡើយ ។ ច្បាប់ជលផលនៅប្រទេសឡាវ នឹងផ្តល់ជាមូលដ្ឋានច្បាប់ ជាលើកដំបូង សម្រាប់ការរៀបចំគ្រប់គ្រងធនធានជលផលរួមគ្នារវាងសហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។ នៅក្នុងប្រទេសវៀតណាម សហគ្រាសជលផលរបស់រដ្ឋ តំរូវអោយមានការកែទម្រង់ជាបន្ទាន់ ។

៣. តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធនិងភ្នាក់ងាររដ្ឋាភិបាលមួយចំនួនមិនត្រូវបានកំណត់អោយបានច្បាស់លាស់នៅតាមបណ្តាផ្នែកតូចៗជាច្រើនដែលមានចែងក្នុងអភិបាលកិច្ចទឹក ដែលកត្តាទាំងអស់នេះហើយជាលទ្ធផលនាំឱ្យគ្មានការកំណត់ និងគ្មានភាពច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ស្ថាប័នទាំងនេះ។ ទន្ទឹមនឹងនេះ ការសម្របសម្រួលរវាងស្ថាប័នទាំងនោះនៅមានលក្ខណៈទន់ខ្សោយ ហេតុដូចនេះការអនុវត្តគោលនយោបាយ គ្រោងការ និង កម្មវិធីនានា មិនមានប្រសិទ្ធិភាព។

- ការសម្របសម្រួលរវាងទីភ្នាក់ងារទាំងឡាយរបស់រដ្ឋាភិបាល និងផ្នែកមួយចំនួនទៀតដូចជា NGOs ទីភ្នាក់ងារផ្តល់ជំនួយ វិស័យឯកជន និងសហគមន៍មូលដ្ឋាននៅតែមានលក្ខណៈទន់ខ្សោយ។
- ការប្រមូល និងគ្រប់គ្រងទិន្នន័យនៅមិនទាន់គ្រប់គ្រាន់ និងច្បាស់លាស់ ខណៈដែលដំណើរការក្នុងការចែករម្លែក និងការផ្លាស់ប្តូរព័ត៌មាននៅតែមានភាពស្មុគស្មាញ និងទើសទែង ។ ប្រការនេះ តម្រូវជាចាំបាច់នូវធនធានមនុស្សជាច្រើនផ្នែក ដូចជាមន្ត្រីជំនាញខាងផ្នែកបច្ចេកទេស និងបុគ្គលិកវិទ្យាសាស្ត្រ ជាងនេះទៅទៀតការពង្រឹង និងកសាងសម្ថភាពរបស់មន្ត្រីជំនាញ គឺត្រូវការជាបន្ទាន់ ជាពិសេសសំរាប់ប្រទេសឡាវ និងប្រទេសកម្ពុជា។

៤. ការចូលរួមរបស់សហគមន៍ និងអ្នកពាក់ព័ន្ធដែលរង

គ្រោះទាំងឡាយនៅមានកម្រិតហើយជាទូទៅការយល់ដឹងរបស់ប្រជាសហគមន៍ និងមន្ត្រីរដ្ឋាភិបាលមានកំរិតទាប ពាក់ព័ន្ធទៅនឹងការបញ្ហានៃការគ្រប់គ្រងទឹក និងអភិបាលកិច្ច។

- នៅក្នុងផ្នែកធារាសាស្ត្រ គណៈកម្មាធិការកសិករប្រើប្រាស់ទឹក (FWUG) នៅកម្ពុជាត្រូវតែពង្រឹងភាពរបស់ខ្លួន ដើម្បីធ្វើឱ្យការចូលរួមរបស់ប្រជាកសិករ កាន់តែសកម្មថែមទៀត ខណៈដែលប្រទេសវៀតណាម ការសម្របសម្រួល និងការទំនាក់ទំនងរបស់ក្រុមហ៊ុនធារាសាស្ត្រ និងគ្រប់គ្រងការបង្ហូរទឹក (IDMC) ក៏ចាំបាច់ត្រូវកែលម្អ ដោយត្រូវផ្តល់ការលើកទឹកចិត្តនានា ដើម្បីជម្រុញឱ្យមានការអភិវឌ្ឍន៍គ្រោងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម (PIM)។ នៅប្រទេសឡាវ គេក៏ចាំបាច់ត្រូវស្វែងរកវិធីដើម្បីឱ្យកសិករ បានចូលរួមផងដែរនៅក្នុងការកសាងផែនការ និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដែលឆ្លើយតបទៅនឹងតំរូវការនៅមូលដ្ឋាន ។
- នៅក្នុងផ្នែកផ្គត់ផ្គង់ទឹក និងអនាម័យ ប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (WSUG) ហើយប្រទេសឡាវ ក៏គួរបង្កើតក្រុមបែបនេះផងដែរ ។ ប្រទេសវៀតណាម យន្តការនានា សំរាប់បង្កើនការចូលរួមពីសំណាក់ប្រជាសហគមន៍ ក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យ ក៏ត្រូវធ្វើការអភិវឌ្ឍន៍ជាចាំបាច់ផងដែរ ។
- នៅក្នុងវិស័យវារីអគ្គិសនី យន្តការនានា ដើម្បីភ្ជាប់ទំនាក់ទំនងនៃប្រជាសហគមន៍ដែលទទួលរងគ្រោះ ទៅក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្ត ជាពិសេស ទាក់ទងនឹងគម្រោងនានាដែលមានផលប៉ះពាល់ឆ្លងដែនមកលើសហគមន៍នៅតំបន់ខ្សែទឹកខាងក្រោម គឺត្រូវការជាចាំបាច់ ។
- នៅក្នុងវិស័យនាវាចរណ៍ និងទេសចរណ៍ គេត្រូវបង្កើតយន្តការនានា សម្រាប់ការពិគ្រោះយោបល់ជាមួយប្រជាសហគមន៍រងគ្រោះដោយគ្រោងការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងជានេះទៀតការរៀបចំបែងចែងផលប្រយោជន៍ដែលបានមកពីវិស័យនេះត្រូវធានាបាននូវភាពយុត្តិធម៌ ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍មួយចំនួន

ទាក់ទងនឹងបញ្ហាទឹក ប្រទេសកម្ពុជា ឡាវ និងវៀតណាម បាននឹងកំពុងប្រឈមនឹងការលំបាកយ៉ាងច្រើន ដែលមិនងាយនឹងដោះស្រាយឡើយ ។ តម្រូវការដោះស្រាយបញ្ហាប្រឈមទាំងនេះ មិនមែនគ្រាន់តែធ្វើអោយប្រសើរឡើងនូវដំណើរការ នៃការធ្វើសេចក្តីសំរេចចិត្ត រវាងស្ថាប័ននានារបស់រដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលនៃប្រទេសទាំងនោះៗទេ ប៉ុន្តែវាថែមទាំងតម្រូវអោយមានការកែលម្អថែមទៀតនូវលំហូរក្នុងការផ្លាស់ប្តូរព័ត៌មាននៅក្នុងតំបន់ទន្លេមេគង្គទាំងមូល និងធានាផងដែរថា ការសម្រេចនានា របស់ប្រទេសនីមួយៗ បានយកមកពិចារណានៅរាល់គំរោងការអភិវឌ្ឍនានានៅទូទាំងតំបន់ឱ្យបានទូលំទូលាយ ។

ផ្អែកតាមរបាយការណ៍ស្ថានភាពដែលបានមកពីប្រទេសនីមួយៗ ទីប្រឹក្សាជាតិ បានលើកឡើងនូវអនុសាសន៍ជាជំហ៊ានដំបូង ដូចខាងក្រោម ទាក់ទងទៅនឹងបញ្ហានានាដែលគួរពិចារណានៅក្នុង MWD សម្រាប់ឆ្នាំ 2009 និង 2010:

ចំពោះកម្ពុជា MWD គួរផ្តោតលើ IWRM សំរាប់ជាវិធានរួមមួយ សម្រាប់ការអភិវឌ្ឍទឹកប្រកបដោយសមធម៌ និងនិរន្តរភាព និងធ្វើការឱ្យកាន់តែលំអិតបន្ថែមទៀតលើបញ្ហាអភិបាលកិច្ចដែលទាក់ទងជាមួយនឹង :

- ការគ្រប់គ្រងធនធានជលផល
- ការអភិវឌ្ឍន៍វារីអគ្គិសនី និងការគ្រប់គ្រងផលប៉ះពាល់ និង
- ការកសាងផែនការ និងគ្រប់គ្រងការប្រព័ន្ធធារាសាស្ត្រ

សំរាប់ប្រទេសឡាវ ត្រូវបានលើកឡើងថា MWD គួរតែយកចិត្តទុកដាក់ជារួម ក្នុងការគាំទ្រដល់ការកែទម្រង់លើវិស័យទឹកដែលកំពុងអនុវត្តសព្វថ្ងៃនេះអោយស្របពេលដែលដំណើរការកែលម្អ អភិបាលកិច្ចទឹក កំពុងត្រូវបានពិគ្រោះយោបល់។

ការពិភាក្សាទៅលើគោលនយោបាយ និងយុទ្ធសាស្ត្រជាតិលើវិស័យទឹកដែលចែងអំពីទិសដៅសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក និងការទទួលស្គាល់អំពីគោលការណ៍នានានៃការគ្រប់គ្រងធនធានទឹក គួរតែត្រូវបានចាត់ទុកថាជាអាទិភាព ។

សម្រាប់ប្រទេសវៀតណាម បញ្ហាសំខាន់ដែលបានលើកស្នើជាអាទិភាពសម្រាប់ MWD គឺ :

- គួរជ្រើសរើសយកការបំពុលទឹក ដែលបង្កដោយសកម្មភាពសិប្បកម្មនានានៅក្នុងភូមិ ដើម្បីវាយតម្លៃឱ្យបានស៊ីជម្រៅ ហើយដំណើរការនៃវេទិការពិគ្រោះយោបល់គួរតែផ្តោតលើការផ្តល់អនុសាសន៍ជាក់ស្តែង ដើម្បីធ្វើការប៉ាន់ប្រមាណចំណាយក្នុងធ្វើអោយប្រសើឡើងវិញនូវករិតជាតិពុលក្នុងទឹក ។
- វិមជ្ឈការ MWD អាចជួយកំណត់អោយបានច្បាស់ អំពីការទទួលខុសត្រូវ សិទ្ធិ និងតួនាទីរបស់អាជ្ញាធរ និងអ្នកពាក់ព័ន្ធនានានៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋាន ។
- ការប្រើប្រាស់ទឹកដោយសមធម៌ MWD អាចជួយសំរបសំរួល និងដឹកនាំឱ្យមានការ ចរចាដើម្បីដោះស្រាយទំនាស់លើការប្រើប្រាស់ទឹក នៅក្នុងតំបន់ជាក់លាក់មួយចំនួន ។
- ការផ្គត់ផ្គង់ទឹក និងអនាម័យ MWD អាចជួយបញ្ជ្រាបបញ្ហាអនាម័យ និងក្រៀងគរឱ្យមានការចូលរួម និងការវិនិយោគពីវិស័យឯកជននៅក្នុងផ្នែករងនេះ ។
- ការលើកកំពស់ IWRM - តាមរយៈករណីសិក្សានានា ក៏ដូចជាវេទិការពិគ្រោះយោបល់ និងដំណើរការជាបន្តរបស់ MWD អាចជួយបង្ហាញនូវវិធានថ្មីៗ និងមានប្រសិទ្ធភាព សំរាប់កែលម្អយុទ្ធសាស្ត្ររបស់ IWRM ។

អនុសាសន៍ដំបូងរបស់ទីប្រឹក្សាត្រូវបានពិភាក្សាបន្ថែម នៅក្នុងការប្រជុំនៃអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិនាទីក្រុងវ៉េ(ប្រទេសវៀតណាម) ក្នុងខែធ្នូ ឆ្នាំ 2008 និងនៅប៉ាក់សេ (ប្រទេសឡាវ) នៅខែមករា ឆ្នាំ 2009 ព្រមទាំង នៅសៀមរាប(ប្រទេសកម្ពុជា) ខែកុម្ភៈ ឆ្នាំ 2009។ ការពិគ្រោះយោបល់នៅថ្នាក់ជាតិបានគាំទ្រដល់អនុសាសន៍ទាំងឡាយរបស់ទីប្រឹក្សា។ ចំពោះករណីនៃប្រទេសឡាវ អ្នកពាក់ព័ន្ធបានកំណត់ជាជាក់លាក់ថា ការកសាងប្រព័ន្ធធារាសាស្ត្រ និងវារីអគ្គិសនីត្រូវតែបានដាក់បញ្ចូលទៅក្នុងវិស័យកំណែទម្រង់ទឹក ។

វារីអគ្គិសនី និងជាពិសេសទស្សនៈវិស័យជារួមរបស់អភិបាលកិច្ចទឹកដែលទាក់ទងទៅផលប៉ះពាល់ឆ្លងដែនត្រូវបានកំណត់ជាអាទិភាពនៅក្នុងរបាយការណ៍ដែលសសេរដោយទីប្រឹក្សាកម្ពុជាហើយ បាននិយាយនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នក ពាក់ព័ន្ធដែលបានធ្វើឡើងនៅប្រទេសឡាវ។ សព្វថ្ងៃនេះសំណើគម្រោងថាមពលវារីអគ្គិសនីនៅលើដងទន្លេមេគង្គ កំពុងទទួលបានការយកចិត្តទុកដាក់ពីសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ហើយនៅទូទាំងឆមាសទីពីរនៃឆ្នាំ 2009 និង ដើមឆ្នាំ 2010 គណៈកម្មការទន្លេមេគង្គកំពុងសិក្សា SEA លើ គម្រោងថាមពល វារីអគ្គិសនីនៅលើដងទន្លេនេះ។ ការអនុវត្ត SEA ក្រោមការគាំទ្រពីទីប្រឹក្សាបច្ចេកទេស នឹងផ្តល់ផងដែរនូវឱកាស ដើម្បីជួយកសាងសមត្ថភាពនៃភ្នាក់ងាររបស់ជាតិនៅក្នុងការសិក្សា SEA ។ យុទ្ធសាស្ត្រល្អបំផុតសម្រាប់ MWD គឺត្រូវចូលរួមនៅក្នុងការពិគ្រោះយោបល់ និងផ្តល់ការគាំទ្រ និងតម្លៃបន្ថែមនៅក្នុង ដំណើរការនេះ (SEA) ហើយក្នុងពេលជាមួយគ្នានេះដែរ MWD ត្រូវសិក្សាពីបទពិសោធន៍អំពី SEA ជាងការសិក្សាដាច់ដោយឡែកលើវិស័យវារីអគ្គិសនីនេះ។ មេរៀនដែលទទួលបានពី SEA ក៏អាចយកទៅអនុវត្តនៅលើទន្លេដែលមានព្រំប្រទល់រួមគ្នានៅក្នុងតំបន់ទន្លេមេគង្គ ដែលរាប់បញ្ចូលទាំងទន្លេរ៉េត និងទន្លេនូសាល់វីន ផងដែរ ។

នៅក្នុងការពិគ្រោះយោបល់ជាអ្នកពាក់ព័ន្ធនានា នៃបណ្តាប្រទេសនៃអនុតំបន់ទន្លេមេគង្គ បានរកឃើញបញ្ហាជាអាទិភាព សំខាន់ជាងគេចំនួនពីរសំរាប់ប្រទេសនីមួយៗសម្រាប់ឆ្នាំ2009។ ដោយផ្អែកលើអនុសាសន៍នានាដែលបានមកពីការសិក្សាទាំងបី ក៏ដូចជាការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិនៃប្រទេសទាំងបី សកម្មភាពគន្លឹះនានានៅក្រោម MWD សម្រាប់ឆ្នាំ 2009

និង 2010 រួមមាន ៖

- ការពិនិត្យមើលលើការអនុវត្តយុទ្ធសាស្ត្ររបស់ IWRM នៅក្នុងការបង្កើត និងអនុវត្តកម្មវិធី និងសកម្មភាពនៃគម្រោងនានានៅជុំវិញអាងទន្លេសាប ក្នុងប្រទេសកម្ពុជា និងតួនាទីរបស់អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួលសកម្មភាពនានា និងការធ្វើឱ្យអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានបានចូលរួម និងការបន្តពិគ្រោះយោបល់នៅថ្នាក់ជាតិស្តីពីយុទ្ធសាស្ត្ររបស់ IWRM ក្នុងការគ្រប់គ្រងអាងទន្លេសាប ។
- ការវាយតំលៃបញ្ហាគ្រប់គ្រងធនធានជលផល ក្នុងចំណោមសហគមន៍មូលដ្ឋានជុំវិញបឹងទន្លេសាប ដោយមានការពិគ្រោះយោបល់ជាមួយអ្នកនេសាទ ដើម្បីកែលម្អកក្នុងការគ្រប់គ្រងធនធានជលផល ។
- ករណីសិក្សាលំអិតអំពីប្រព័ន្ធធារាសាស្ត្រ នៅប្រទេសឡាវ ដែលផ្តោតលើអាងណាមខាន ដោយបន្តការពិគ្រោះយោបល់នៅថ្នាក់ជាតិស្តីពីធារាសាស្ត្រនៅប្រទេសឡាវ ។
- ការវាយតំលៃផលប៉ះពាល់មកលើគុណភាពទឹកបណ្តាលពីភូមិសិប្បកម្មនៅប្រទេសវៀតណាម និងការពិគ្រោះយោបល់នៅថ្នាក់ជាតិលើអនុសាសន៍សម្រាប់ កែលម្អអភិបាលកិច្ច និងកាត់បន្ថយការបំពុល និង
- សិក្ខាសាលាមួយជាមួយ "សហគមន៍អ្នកមានចំណេះដឹង" ដើម្បីបោះពុម្ពផ្សាយព្រឹត្តប័ត្រស្តីពី "ចំណេះដឹងថ្មីៗ" និងឯកសារអនុសាសន៍មួយចំនួនស្តីពី គោលនយោបាយវិមជ្ឈការ និងអភិបាលកិច្ច នៅក្នុងដែនដីសណ្តទន្លេមេគង្គ ដោយបន្តការប្រជុំពិគ្រោះយោបល់អំពីគោលនយោបាយ ដើម្បីលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធអោយទទួលយកអនុសាសន៍ទាំងនោះ ។ ស្របជាមួយគ្នានេះដែរ អង្គការ IUCN បានកំណត់សកម្មភាព ជាអាទិភាពមួយចំនួនដូចខាងក្រោមសម្រាប់ MWD នៅឆ្នាំ 2009 ៖
- ការបោះពុម្ពផ្សាយសៀវភៅអត្ថាធិប្បាយលក្ខណៈរូបថតជាភាសាអង់គ្លេស ឡាវ និងថៃ អំពីតំបន់ស៊ីផាន់ដុន និងការពិគ្រោះយោបល់លើគោលនយោបាយ អំពីកន្លែង ដែលអាចកំណត់ជាតំបន់រ៉ាមសារ តំបន់បេតិកភណ្ឌពិភពលោក និងមនុស្សជាតិ និងស្ថានភាពបរិស្ថានជីវៈមណ្ឌលសំរាប់តំបន់នេះ
- ពិនិត្យមើលទៅលើការងាររបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ព្រមទាំងរៀនសូត្រនូវគំរូសំខាន់ៗដែលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសំរេចជោគជ័យ សំរាប់ធ្វើជាមេរៀនអនុវត្តនៅកន្លែងដទៃទៀត
- ករណីសិក្សាថ្នាក់តំបន់ ស្តីពីការអនុវត្តលើលើប្រព័ន្ធធារាសាស្ត្រនៅប្រទេសថៃ វៀតណាម កម្ពុជា និងឡាវ និង
- ការរៀបចំបោះពុម្ពសៀវភៅមួយ ស្តីពីការគ្រប់គ្រងតំបន់ដីសើម និងអភិបាលកិច្ចនៅក្នុងតំបន់ទន្លេមេគង្គ ជាមួយនឹងការចូលរួមពីអ្នកនិពន្ធនានា ដែលបានសសេរនៅក្នុងជំពូកជាច្រើននៃសៀវភៅដែលបានបោះពុម្ពនេះ ។

នៅក្នុងផែនការការងារសម្រាប់ឆ្នាំ 2009 និង 2010, MWD នឹងបន្តសម្របសម្រួលឱ្យមានវេទិកាពិគ្រោះយោបល់បន្ថែមទៀតរវាងស្ថាប័ននានា របស់រដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសដែលចូលរួមក្នុងតំបន់ទន្លេមេគង្គ ដូចដែលពួកគេកំពុងតែនឹងធ្វើអោយប្រសើរឡើងទៅមុខ ក្នុងដំណើរការគ្រប់គ្រងទឹក និងអភិបាលកិច្ច ក៏ដូចជាការថ្លឹងថ្លែងទៅលើកំណើនសេដ្ឋកិច្ចនៃប្រទេសទាំងនោះ ជាមួយនឹងការថែរក្សានូវតម្លៃរបស់ប្រព័ន្ធវិវឌ្ឍន៍នៃភាវៈមានជីវិត (ប្រព័ន្ធអេកូឡូស៊ីទន្លេ) នៅក្នុងទន្លេនិងធនធានជលជាតិ (រុក្ខជាតិដែលដុះនៅក្នុងទន្លេ) ។ ទីបំផុតដោយពិនិត្យមើលវែងឆ្ងាយហួសពីតារាងសកម្មភាពអាទិភាព ដែលមានរួចមកហើយសម្រាប់ MWD ដែលបានពីការពិនិត្យស្ថានភាពនេះ នៅតែត្រូវការការវាយតម្លៃ និងបកស្រាយបន្ថែមទៀតថាតើទៅអនាគត MWD នឹងផ្តោតលើទិដ្ឋភាពនៃអភិបាលកិច្ចដែលទាក់ទងនឹងប្រធានបទដ៏ស្រួចស្រាល់ ដូចជាការគ្រប់គ្រងទឹកក្រោមដី ការវិនិយោគធនធានបរិស្ថាន (លំហូរបរិស្ថាន) និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយរបៀបណា ។

១. សេចក្តីផ្តើម

តំបន់ទន្លេមេគង្គ ដែលគ្របដណ្តប់លើដែនដីនៃប្រទេសកម្ពុជា ឡាវ វៀតណាម ថៃ ភូមា និងតំបន់ស្វយ័តទីបេតិ៍ ខេត្តយុនណាន គីងហៃ និងក្វាងស៊ីនៃប្រទេសចិន[2] គឺជាតំបន់សេដ្ឋកិច្ចមួយក្នុងចំណោមតំបន់នានានៅលើពិភពលោកដែលរីកលូតលាស់យ៉ាងឆាប់រហ័ស ។ ក្នុងចំណោមប្រជាពលរដ្ឋសរុប 300 លាននាក់ដែលតាំងទីលំនៅ និងចិញ្ចឹមជីវិតក្នុងតំបន់នេះ ច្រើនជាង 100 លាននាក់ ពឹងផ្អែកលើធនធានជលផល និងផលិតផល និងសេវាកម្មផ្សេងៗទៀតនៃប្រព័ន្ធទន្លេធំៗ មានដូចជា (ឡានឆាំង-មេគង្គ នូ-សាល់វីន ភាគខាងលើនៃទន្លេយ៉ាំងហ្សេ អ៊ីរ៉ាវ៉ាឌី ចៅប្រាយ៉ា និងទន្លេរ៉ែត) ជាមួយនឹងតម្រូវទឹកយ៉ាងច្រើននៅក្នុងវិស័យពានិជ្ជកម្ម កាកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ធារាសាស្រ្ត ស្ពាន ផ្លូវថ្នល់ ទំបន់វារីអគ្គីសនី ។ល។) និងការបំពុលទឹកតាមរូបភាពផ្សេងៗ បាននឹង កំពុងកើនឡើងយ៉ាងឆាប់រហ័ស ។

វេទិការពិគ្រោះយោបល់អំពីទឹកតំបន់ទន្លេមេគង្គ (MWD) ដែលបានបង្កើតឡើងដោយអង្គការសហភាពដើម្បីអភិរក្សធម្មជាតិ (IUCN) ដែលមានការគាំទ្រដោយក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ បាននឹងកំពុងចាប់ផ្តើមធ្វើការជាមួយប្រទេសនានា នៅក្នុងតំបន់មេគង្គ ដើម្បីធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចទឹក ដោយសំរួលឱ្យមានការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងធ្វើអោយកាន់តែប្រសើរឡើងក្នុងការប្រកបរបរចិញ្ចឹមជីវិត សុខភាពមនុស្សជាតិ និងសុវត្ថភាពប្រព័ន្ធអេកូឡូស៊ី ។ កម្មវិធីនេះមានគោលដៅធ្វើអោយប្រសើរនូវដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅជុំវិញការគ្រប់គ្រង និងការអភិរក្សធនធានទឹកក្នុងតំបន់មេគង្គ និងដើម្បីផ្តល់ឱកាសដល់រដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិលនៃតំបន់នេះ ចូលរួមនៅក្នុងវេទិការ និងដើម្បីភ្ជាប់នូវទស្សនៈទានខុសៗគ្នានានាអំពីការអភិវឌ្ឍន៍ទឹក ។

ផែនទីៈ ទន្លេមេគង្គហូរពីប្រទេសចិន (ឡានឆាំង) កាត់តាមប្រទេស ឡាវ ថៃ កម្ពុជា និងវៀតណាម ចូលទៅសមុទ្រចិនខាងត្បូង

យុទ្ធសាស្រ្តរបស់ MWD គឺដើម្បីអភិវឌ្ឍន៍ផែនការនៃប្រទេសដែលស្ថិតនៅក្នុងអនុតំបន់ទន្លេមគង្គ និងភ្ជាប់ដំណើរការនៃវេទិការតំបន់អោយមានការផ្លាស់ប្តូរពតិមានកាន់តែល្អជាងមុន ព្រមទាំងការផ្លាស់ប្តូរចំណេះដឹង ចលនានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធកាន់តែទូលំទូលាយ និងកំណើនការទទួលស្គាល់អំពីការពាក់ព័ន្ធគ្នាទៅវិញទៅមកនៃបញ្ហានានា ។ នៅក្រោមកម្មវិធីនេះ ក្រុមការងារថ្នាក់ជាតិ (NWGs) ដែលជាអ្នកជំនាញការតំណាងអោយរដ្ឋាភិបាល សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល (NGOs) ផ្នែកឯកជន និងគ្រឹះស្ថានអប់រំ/ស្ថាប័នស្រាវជ្រាវ ត្រូវបានបង្កើតឡើង ដើម្បីកសាងយុទ្ធសាស្រ្តក្នុងការអនុវត្តវេទិការទឹកតំបន់ទន្លេមេគង្គ ក្នុងប្រទេសនីមួយៗ។

ដើម្បីកំណត់បញ្ហាគន្លឹះនានា ទីប្រឹក្សាក្នុងស្រុកត្រូវបានជ្រើសរើសអោយធ្វើការនៅក្នុងប្រទេស កម្ពុជា ឡាវ និងវៀតណាម រវាងខែតុលា ឆ្នាំ2008 និងខែមករា ឆ្នាំ2009 ដើម្បីរៀបចំសិក្សាសម្រាប់វិភាគស្ថានភាពនៅក្នុងប្រទេស ។ការសិក្សានេះ បានធ្វើការវាយតំលៃទៅលើរចនាសម្ព័ន្ធគោលនយោបាយអភិបាលកិច្ចទឹក ដែលមានស្រាប់ ភាពត្រឹមត្រូវតាមផ្លូវច្បាប់ រចនាសម្ព័ន្ធបញ្ញត្តិច្បាប់ ភាពជាស្ថាប័ន និងមូលដ្ឋាននៃការធ្វើសេចក្តីសំរេចចិត្តនានា សំរាប់ប្រទេសនៃអនុតំបន់មេគង្គ ។ ការសិក្សានានាត្រូវបានប្រើប្រាស់ដើម្បីជួយ NWGs ក្នុងការធ្វើអត្តសញ្ញាណបញ្ហាជាគន្លឹះនៃ

[2] ADB រួមបញ្ចូលខេត្តយុនណាន និងក្វាងស៊ីនៃប្រទេសចិន នៅក្នុងនិយមន័យរបស់ខ្លួនអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ចនៃ GMS ចំណែកអាងជាក់ស្តែងនៅក្នុងទន្លេមេគង្គ រួមបញ្ចូលផ្នែកនានានៃតំបន់ស្វយ័តទីបេតិ៍ (TAR) និងខេត្តគីងហៃ។ ដូច្នេះ យើងទទួលយកនិយមន័យធំទូលាយជាងគេ អំពីតំបន់មេគង្គ ដើម្បីរួមបញ្ចូលខេត្តទាំងបួន។

អភិបាលកិច្ចទឹក សម្រាប់ប្រទេសនីមួយៗ និងផ្ដល់អនុសាសន៍លើប្រធានបទដែលពាក់ព័ន្ធនានាសំរាប់វេទិកាឆ្នាំ 2009-2010 និងលើកយកនូវគោលការណ៍សំខាន់ៗនៃទំហំនៃការងារ សំរាប់ធ្វើអោយកាន់តែប្រសើរឡើងនូវអភិបាលកិច្ចទឹក។ លទ្ធផលដែលបានមកពីការសិក្សាវិភាគទាំងនោះនឹងត្រូវបានប្រើប្រាស់ដើម្បីតំណាងអោយ NWG ក្នុងការរៀបចំផែនការនានា និងការអនុម័ត និងការគាំទ្រ ។ បន្ទាប់ពីនេះ មានការប្រជុំពហុអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ ដែលជាតំណាងមកពីរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកអង្គការក្រៅរដ្ឋាភិបាល (NGO) តំណាងសហគមន៍ គ្រឹះស្ថានសិក្សា/ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន ដើម្បីចាត់បញ្ហានានា ជាអាទិភាព និងឯកភាពលើប្រធានបទសំខាន់ៗសម្រាប់ការពិនិត្យជាបន្ថែមសម្រាប់អំឡុង ឆ្នាំ 2009 និង 2010 ។

វិស័យនានាដែលបានពិនិត្យនៅក្នុងប្រទេសនីមួយៗបានធ្វើឡើងតាមលក្ខខណ្ឌយោង ដែលបានឯកភាពដោយ NWGs នៃប្រទេសនីមួយៗ ។ បញ្ហាពាក់ព័ន្ធ និងអភិបាលកិច្ចទឹក មិនដែលបានលើកឡើងនៅក្នុងការសិក្សាណាមួយទាំងនេះទេ ដូចជា ការថែរក្សានូវលំហូរបរិស្ថាន (ការអភិវឌ្ឍន៍អាងទន្លេ និងការថែរក្សាភាវៈមានជីវិតដែលមាននៅក្នុងទន្លេ) និងការគ្រប់គ្រងតំបន់ដីសើម។ អង្គការ IUCN ទទួលស្គាល់អំពីសារៈសំខាន់នៃលំហូរបរិស្ថាន ក្នុងការទ្រទ្រង់ដល់ការប្រើប្រាស់ធនធានទឹកប្រកបដោយសមធម៌ និងដោយនិរន្តរភាព ព្រមទាំងចាត់ទុកថា ជាធាតុសំខាន់មួយនៅក្នុងការអភិវឌ្ឍធនធានទឹកប្រកបដោយការទទួលខុសត្រូវលើបរិស្ថាន ។ បើទោះជាបែបនេះក៏ដោយ កត្តាទាំងនេះមិនត្រូវបានកំណត់ជាប្រធានបទពាក់ព័ន្ធសម្រាប់ NWGs ពិចារណាឡើយ ហេតុដូចនេះវាមិនត្រូវបាននិយាយនៅក្នុងផ្នែកណាមួយទាល់តែសោះ នៃការសិក្សាទាំងបីនោះ ។ ការគ្រប់គ្រងតំបន់ដីសើមក៏មិនត្រូវបានបញ្ចូលទៅក្នុងការសិក្សាទាំងនេះដែរ ដោយសារថា IUCN កំពុងស្ថិតក្នុងដំណើរការរៀបចំការចេញផ្សាយដាច់ដោយឡែកមួយ ដែលនឹងធ្វើការពិចារណាជាពិសេសអំពីបញ្ហាអភិបាលកិច្ចទឹកដែល ទាក់ទងជាមួយការគ្រប់គ្រងតំបន់ដីសើម នៅក្នុងតំបន់មេគង្គ សំរាប់ការបោះពុម្ពផ្សាយនៅឆ្នាំ2010។

វិស័យគន្លឹះដែលបានពិនិត្យមើលនៅក្នុងប្រទេសទាំងបីគឺ :

វិស័យ	កម្ពុជា	ឡាវ	វៀតណាម
ប្រព័ន្ធធារាសាស្ត្រ	X	X	X
ជលផល និងវារីវប្បកម្ម	X	X	X
វារីអគ្គិសនី និងថាមពល	X	X	X
ទេសចរណ៍ និងនាវាចរណ៍	X	X	X
ការផ្គត់ផ្គង់ទឹក និងអនាម័យ	X	X	X
ឧស្សាហកម្ម និងភូមិសិប្បកម្ម			X

របាយការណ៍សំយោគនេះ បង្ហាញអំពីលទ្ធផលសំខាន់ៗពីការសិក្សាទាំងបី និងអធិប្បាយអំពីបញ្ហាខ្លះៗ ភាពខុសគ្នា និងភាពដូចគ្នារវាងប្រទេសទាំងបី ។ យើងសង្ឃឹមថា របាយការណ៍នេះនឹងផ្ដល់ជាមធ្យោបាយសម្រាប់ធ្វើការកំណត់នូវឱកាស សម្រាប់ប្រទេសនានា ក្នុងការចែករំលែកព័ត៌មាន និងសិក្សាអំពីប្រទេសជិតខាងរបស់ខ្លួន នៅក្នុងការដោះស្រាយបញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹងទឹក និងការប្រឈមនានានៃការអភិវឌ្ឍ ។

២. កម្ពុជា

២.១ ទិដ្ឋភាពរួម

បើទោះជាកម្ពុជាសំបូរដោយធនធានទឹកសាប ដែលមានទន្លេ ស្ទឹង បឹងបួរ និងល្អាងទឹកក្រោមដីក៏ដោយ ក៏ការធ្វើអោយប្រែប្រួលនៃចរន្តទឹកហូរនៅតាមស្ទឹង បឹងបួរ និង ភាពរាំងស្ងួតនៅក្នុងតំបន់ខ្លះនៃប្រទេសបាននឹងកំពុងកើនឡើង និងគំរាមកំហែងដល់សន្តិសុខស្បៀង ការចិញ្ចឹមជីវិតទៅថ្ងៃអនាគត និងការរីកលូតលាស់នៃសេដ្ឋកិច្ចរបស់ប្រជាជនខ្មែរ ។ មិនតែប៉ុណ្ណោះធនធានទឹកនៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីការប្រែប្រួលចរន្តទឹកហូរ ការចែកចាយនៃចរន្តទឹក និងគុណភាពទឹក ដែលទាំងនេះបណ្តាលមកពីការផ្លាស់ប្តូរនូវរបបទឹកភ្លៀង និងផលប៉ះពាល់ពីការកែប្រែលក្ខណៈធម្មជាតិ ទៅជាហេដ្ឋារចនាសម្ព័ន្ធសង្គមដោយមនុស្ស ព្រមទាំងសកម្មភាពអភិវឌ្ឍនានារបស់បណ្តាប្រទេសមួយចំនួននៅផ្នែកខាងលើនៃទន្លេមេគង្គ។ បញ្ហាចំបងៗដែលជាកង្វល់គឺ :

- ផលប៉ះពាល់នៃការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការបង្វែរទឹកនៅតំបន់ខ្សែទឹកខាងលើ
- ការប្រែប្រួលនៃលក្ខណៈរូប/សណ្ឋាន/រូបរាងរបស់ទន្លេ ដោយសារការហូរច្រោះនៅតាមដងទន្លេមេគង្គ និងការប្រែប្រួល និងកើនឡើងនូវបរិមាណកំទេចកំណកនៅក្នុងទន្លេ ស្ទឹង បឹងបួរ និងនៅតាមដៃទន្លេ
- ការថយចុះនូវធនធានជលផល ដោយសារការប្រែប្រួលចរន្តទឹកហូរ ការចែកចាយចរន្តទឹក ភាពកខ្វក់នៅក្នុងទឹក ការបាត់បង់តំបន់ដីសើម ដោយសារការអភិវឌ្ឍ ការបាត់បង់ព្រៃឈើ និងការនេសាទខុសច្បាប់
- សន្ទុះនៃការបំពុលទឹកទន្លេ ស្ទឹង បឹងបួរ និងទឹកក្រោមដី ដែលបង្ករមកពីសារធាតុពុល និងការប្រើប្រាស់ជីគីមីកសិកម្ម សកម្មភាពរបស់មនុស្ស ការបញ្ចេញសំណល់រាវពាសវាលពាសកាល និងការបំពុលពីសកម្មភាពរុករករ៉ែ និង
- ការខូចខាតសមត្ថភាពរបស់ទីជំរាល ចរន្តទឹកហូរ ការចែកចាយនៃចរន្តទឹក និងគុណភាពទឹកទន្លេ ការប្រែប្រួលរបបទឹកភ្លៀង និងអាកាសធាតុ ដែលបណ្តាលមកពីការវិនាសហិនហោចនៃព្រៃឈើ តាមរយៈការអភិវឌ្ឍវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត អាជីវកម្មព្រៃឈើ ភ្លើងឆេះព្រៃ ការផ្លាស់ប្តូរដីព្រៃធម្មជាតិសំរាប់បំរើផលប្រយោជន៍របស់មនុស្ស ។ល។ និងការបាត់បង់តំបន់ដីសើម ។

ដូច្នេះរបាយការណ៍នេះ ព្យាយាមធ្វើការកំណត់អោយបាននូវការរៀបចំអភិបាលកិច្ចជាគន្លឹះមួយ អំពីចំនួននៃផ្នែកអ្នកប្រើប្រាស់ទឹក ហើយនឹងធ្វើការស្វែងយល់ ថាតើត្រូវធ្វើយ៉ាងណាដើម្បីអោយការរៀបចំទាំងនេះអាចជួយប្រទេសកម្ពុជាអោយមានសមត្ថភាពក្នុងការដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកយ៉ាងមានប្រសិទ្ធភាព ។ ភាពខ្វះចន្លោះ និងបញ្ហាជាអាទិភាពត្រូវតែរកអោយឃើញ សម្រាប់ការពង្រឹង និងកែលម្អអភិបាលកិច្ចជាមួយគ្នានឹងការកំណត់ទំហំការងារនៃការរៀបចំនេះ សំរាប់ MWD ក្នុងការជួយដោះស្រាយបញ្ហា ។

២.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងខាងស្ថាប័ន

២.២.១ គោលនយោបាយ ច្បាប់ កិច្ចព្រមព្រៀង និងយុទ្ធសាស្ត្រនានា

ធនធានទឹកដើរតួរជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ និងជាសមាសភាគចាំបាច់ក្នុងការទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ។ ខ្សែទឹកនៅក្នុងកម្ពុជា (ដូចជា: ទន្លេ ស្ទឹង បឹងបួរ ព្រែក ខ្សែទឹកក្រោមដី ។ល។) និងជាពិសេស អាងទន្លេសាប គឺជាមូលដ្ឋានគ្រឹះសម្រាប់ធនធានជលផល ធនធានទឹកសំរាប់ការប្រកបរបរកសិកម្ម ទឹកប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ និងផ្គត់ផ្គង់ក្នុងវិស័យឧស្សាហកម្ម ការផលិតវារីអគ្គិសនី និងនាវាចរណ៍ ។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ 1990 មក រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញអោយឃើញនូវការកែទម្រង់មួយចំនួនលើការងារអភិបាលកិច្ចទឹក ក្នុងគោលបំណងគាំទ្រដល់ការគ្រប់គ្រង និងប្រើប្រាស់ដោយចីរភាព និងសមធម៌នូវធនធានរបស់ប្រទេស ។ ការកែទំរង់

ទាំងនេះ ដែលផ្តោតផងដែរលើគោលនយោបាយ ហេដ្ឋារចនាសម្ព័ន្ធ និងការរំពឹងទុកទៅអនាគត គឺជាចំណុចគោលដ៏សំខាន់ដើម្បីឈាន ទៅរកអភិបាលកិច្ចទឹកកាន់តែប្រសើរជាងមុននៅកម្ពុជា បើទោះជា នៅមានផ្នែកខ្លះៗតម្រូវអោយមានការកែលម្អបន្ថែមទៀតក៏ដោយ ។

គ្រោងការថ្នាក់តំបន់

កិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍដោយចីរភាព នៅអាងទន្លេមេគង្គ ត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ 1995 ដោយរាជរដ្ឋាភិបាលកម្ពុជា ឡាវ ថៃ និងវៀតណាម ក្នុងការសហការ និងផ្សព្វផ្សាយលើការអភិវឌ្ឍប្រកបដោយចីរភាព នូវការប្រើប្រាស់ ការអភិរក្ស និងការគ្រប់គ្រងទឹកអាងទន្លេមេគង្គ ។

គ្រោងការជាក់លាក់របស់ប្រទេស

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ 1996 គឺជាឧបករណ៍មួយសំរាប់ពិនិត្យមើលនូវរាល់គំរោងទាំងឡាយណាដែលប៉ះពាល់ដល់បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។ ច្បាប់នេះក៏និយាយដល់ការទទួលយកការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) លើគ្រប់គម្រោង និងសកម្មភាពអភិវឌ្ឍនានា រួមទាំងវិស័យឯកជន និងសាធារណៈ ។ ទន្ទឹមនឹងនេះ អ្នកស្នើរសុំទាំងអស់ត្រូវតែដាក់ជូននូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់គម្រោងខ្លួនដល់ក្រសួងបរិស្ថាន ដែលជាសេនាធិការ របស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច ។

ក្រសួងបរិស្ថានថែមទាំងបានដាក់ចេញនូវគោលការណ៍ណែនាំបន្ថែមមួយចំនួន សម្រាប់គ្រប់គម្រោងទាំងអស់ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួនអោយបានត្រឹមត្រូវ ។

គោលនយោបាយជាតិស្តីពីទឹកឆ្នាំ 2004 ត្រូវបានបង្កើតឡើង និងអនុម័តអោយប្រើប្រាស់ដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីនៅ ខែមករា ឆ្នាំ 2004 ។ ទាំងនេះគឺជាគោលនយោបាយមួយនៃគោលនយោបាយដទៃទៀត សម្រាប់ការគ្រប់គ្រងធនធានទឹក និងការប្រើប្រាស់ទឹកនៅប្រទេសកម្ពុជា ។

គោលបំណងក្នុងការរៀបចំនយោបាយនេះរួមមាន :

- ការពារនិងគ្រប់គ្រងធនធានទឹកប្រកបដោយសមធម៌ និង ដោយចីរភាព
- ត្រួតពិនិត្យ និងចាត់វិធានការដើម្បីជួយស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាក្នុងវិស័យទឹក និង
- រៀបចំ និងអនុវត្តយុទ្ធសាស្រ្តជាតិ លើការគ្រប់គ្រងធនធានទឹក

NWRP ផ្តល់ការណែនាំដ៏សំខាន់ខាងគោលនយោបាយដែលមានប្រយោជន៍សម្រាប់អភិបាលកិច្ចទឹក ដោយចែងអំពីៈ

- ធនធានទឹកលើដី (ទន្លេ ស្ទឹង បឹងបួរ ព្រែក អូរ ពាម។ល។) និងទឹកក្រោមដី
- ការបង្កើតយន្តការសមស្របសំរាប់គ្រប់គ្រងធនធានទឹកសាប
- ប្រសិទ្ធិភាពនៃការប្រើប្រាស់ទឹក និងភាពជាដៃគូ
- ការបែងចែក និងចែកចាយទឹកប្រកបដោយសមធម៌
- គ្រោះថ្នាក់ដែលប៉ះពាល់ដល់ប្រភពទឹក និង
- ការថែរក្សា ការពារ និងភាពស្ថិតស្ថេរនៃប្រព័ន្ធទឹក ។

ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ 2006 – 2010 (NSDP) មានគោលដៅស្តារ និងបង្កើតឡើងវិញប្រព័ន្ធធារាសាស្រ្ត ស្រោចស្រព និងប្រព័ន្ធដោះទឹកដែលមានស្រាប់ ជាពិសេសនៅក្នុងតំបន់ដែលមានភាពក្រីក្រខ្លាំង និងនៅតាមតំបន់ព្រំដែន ។ ជម្រុញការវិនិយោគតាមរយៈវិស័យឯកជនលើប្រព័ន្ធធារាសាស្រ្ត ប្រព័ន្ធដោះទឹក និងមូលដ្ឋានដទៃទៀតនៃតម្រូវការទឹកសម្រាប់វិស័យកសិកម្ម និងជម្រុញការគ្រប់គ្រងអាងទន្លេឱ្យបានសមស្រប និងប្រកបដោយប្រសិទ្ធិភាព
ជាមួយគ្នានឹងប្រព័ន្ធបែងចែកទឹកគឺត្រូវបានព្យាករណ៍ត្រឹមត្រូវ ។

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកឆ្នាំ 2007 គាំទ្រឱ្យមានការអនុវត្ត NWRP និង NSDP និងរួមបញ្ចូលមាត្រានានាស្តីពីការផ្តល់ទិន្នន័យ និងព័ត៌មានស្តីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានដទៃទៀតដែលទាក់ទងនឹងទឹក ការអភិវឌ្ឍ និងប្រើប្រាស់ធនធានទឹក សិទ្ធិទទួលបានទឹកសម្រាប់ប្រើប្រាស់តាមគ្រួសារ និងគោលបំណងអភិវឌ្ឍន៍ផ្សេងៗ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក និងភាពស្របច្បាប់លើការប្រើប្រាស់ទឹក ។

គោលនយោបាយជាក់លាក់តាមវិស័យ ច្បាប់ កិច្ចព្រមព្រៀង និងយុទ្ធសាស្រ្តនានា មានពិភាក្សាខាងក្រោមនេះ ។

វិស័យធារាសាស្ត្រ

សារាចរស្តីពីការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធស្រោចស្រពដោយនិរន្តរភាពត្រូវបានអនុម័តនៅឆ្នាំ 2009 ។ សារាចរនេះទទួលស្គាល់គណៈកម្មាធិការអ្នកប្រើប្រាស់ទឹក (FWUG) ថាជាអង្គភាពស្របច្បាប់មួយ ដែលមានសិទ្ធិដាក់ចេញនូវបទបញ្ជាដាក់ទណ្ឌកម្ម មានសិទ្ធបើកគណនីផ្ទាល់ខ្លួននៅធនាគារ អាចខ្ចីប្រាក់ និងចុះកិច្ចសន្យាស្របច្បាប់ ។ គោលនយោបាយនេះក៏រួមបញ្ចូលផងដែរនូវកំណែទម្រង់ដូចតទៅ :

- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនឹងត្រូវធ្វើឡើងនៅ ពេលដែលមានការស្នើសុំរបស់ FWUG ហើយ FWUG នឹងចូលរួមនៅគ្រប់ដំណាក់កាលនៃគំរោងអភិវឌ្ឍទាំងនោះ ដែលរួមមានការធ្វើសេចក្តីសម្រេចចិត្ត និងការសង្កេតការនៅគ្រប់ជំហាននៃគំរោងវិនិយោគ មានដូចជា ការជួសជុល ការវិភាគ/ការវាយតម្លៃ ការកែលម្អ ក៏ដូចជាគំរោងពង្រីកប្រព័ន្ធធារាសាស្ត្របន្ថែម ។
- អ្នកប្រើប្រាស់ទឹកតម្រូវអោយបង់ប្រាក់ជាប្រចាំ សំរាប់ចំណាយក្នុងប្រត្តិបត្តការ និងថែរក្សា ព្រមទាំងបង្កើតមូលនិធិមួយដើម្បីប្រមូលប្រាក់ជួសជុលក្នុងករណីបន្ទាន់ ។
- ប្រព័ន្ធធារាសាស្ត្រនឹងត្រូវបានថែរក្សា និងកែលម្អជាប្រចាំក្រោមកិច្ចសហការគ្នារវាង FWUC និងរាជរដ្ឋាភិបាល ។
- ការផ្គត់ផ្គង់ទឹកនឹងត្រូវចាត់ចែងឡើងដោយ FWUC លក្ខណ្ឌ សមធម៌ និងដែលអាចជឿរទុកចិត្តបាន ហើយ
- ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ទទួលខុសត្រូវផ្នែកបច្ចេកទេស និងការគ្រប់គ្រង តាមដាន និងវាយតម្លៃជាមួយនឹងតម្រូវការគាំទ្រផ្សេងទៀត ។

នៅខែ មិថុនាឆ្នាំ 2000, ក្រសួងធនធានទឹក និងឧតុនិយម（MOWRAM） បានចេញផ្សាយនូវគោលនយោបាយមួយ ស្តីពីនិរន្តរភាពនៃប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ដើម្បីអោយការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដំណើរទៅដោយប្រសិទ្ធភាព និងភាពយូរអង្វែងជាមួយនឹងការពិនិត្យមើលពីកំណើនប្រជាកសិករដែលចូលបានចូលរួម ហើយនឹងឈានទៅរកការកាត់បន្ថយតួនាទីរបស់រាជរដ្ឋាភិបាល ។ គោលនយោបាយនេះក៏មានបំណងស្វែងរកនូវការកសាងសមត្ថភាពមួយរបស់ FWUCs ដើម្បីបង្កើតការយល់ដឹងក្នុងចំណោមប្រជាកសិករ និងលើកទឹកចិត្តដល់ទីភ្នាក់ងារផ្តល់ជំនួយនានា គាំទ្រដល់គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម ។

ការកសាងគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម (PIMD) នៅក្នុងឆ្នាំ 2000 បានពឹងផ្អែកទាំងស្រុងលើសារាចរណែនាំលេខ 1 និងមានបំណងធ្វើអោយកាន់តែប្រសើរនូវការរៀបចំអភិបាលកិច្ច រវាងកែលម្អការចាត់ចែងអភិបាលកិច្ចរវាងសហគមន៍អ្នកប្រើប្រាស់ទឹក （FWUCs） និងរាជរដ្ឋាភិបាល ។ មិនតែប៉ុណ្ណោះត្រូវលើកទឹកចិត្តដល់ប្រជាកសិករអោយទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយខ្លួនពួកគេផ្ទាល់ ។

ក្រសួងធនធានទឹក និងឧតុនិយម（MOWRAM）បានធ្វើការអនុវត្ត PIMD នៅក្នុងខេត្តចំនួន11 ជុំវិញបឹងទន្លេសាប និងនៅតាមដងទន្លេមេគង្គពីចាប់ឆ្នាំ 2001 ដល់ឆ្នាំ 2005 ។

វិស័យជលផល និងវារីវប្បកម្ម

កំណែទម្រង់ជលផលបានចាប់ផ្តើមនៅថ្ងៃទី 24 ខែតុលា ឆ្នាំ 2000 ដើម្បីគាំទ្រដល់សិទ្ធិរបស់ប្រជាពលរដ្ឋនៅជនបទក្នុងការប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព និងកែលម្អអភិបាលកិច្ចនៅក្នុងវិស័យនេះ ។ កំណែទម្រង់នេះមានគោលដៅ :

- ជម្រុញការអភិវឌ្ឍសហគមន៍ ដោយផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមនៅក្នុងការតាក់តែងផែនការកម្មវិធីនានា និងការគ្រប់គ្រងធនធានសហគមន៍ដោយផ្ទាល់
- បង្វែរដែនឡូត៍នេសាទ ដែលចប់អាណត្តិកិច្ចសន្យាទៅជាតំបន់នេសាទសំរាប់សហគមន៍ ដែនអភិរក្សត្រីមេពូជ គោលបំណងរក្សាអោយបាននូវបរិមាណត្រីនៅក្នុងធម្មជាតិ និងការពារប្រភេទត្រីដែលជិតផុតពូជ ។និង
- ពង្រីកដែននេសាទរបស់សហគមន៍ និងជម្រុញការអភិរក្សជីវៈចម្រុះនៅក្នុងទឹក ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃមច្ឆាជាតិ និងកាត់បន្ថយសម្ពាធទៅលើធនធានជលផល ។

កំណែទម្រង់ទាំងបីនេះ ក៏ត្រូវបានចាត់ជាអាទិភាពនៅក្នុង NSDP ផងដែរ (ដូចបានពិភាក្សាខាងលើ) ។

ច្បាប់ជលផលជាតិឆ្នាំ2006 គឺជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងធនធានជលផលនៅកម្ពុជា ហើយច្បាប់ថ្មីបានទទួលសច្ចាប័ននៅថ្ងៃទី 30 ខែមីនា ឆ្នាំ 2006 ។ ច្បាប់ថ្មីនេះមានចែងយ៉ាងច្បាស់ពីនិយមន័យ ដែននេសាទស្ថាប័នរដ្ឋដែលគ្រប់គ្រងធនធានជលផល និងសកម្មភាពនេសាទមួយចំនួនដែលត្រូវហាមឃាត់ ការធ្វើនាវាចរណ៍ ការតាំងទីលំនៅថ្មីនៅក្នុងដែនអភិរក្សព្រមទាំងសកម្មភាពផ្សេងៗទៀត ដែលមានផលប៉ះពាល់អវិជ្ជមានមកលើធនធានជលផល ។ ច្បាប់នេះផ្តល់ជាមូលដ្ឋានធ្វើការយ៉ាងពេញលេញសំរាប់ការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទ ក៏ដូចជា មូលដ្ឋានច្បាប់សំរាប់ការរៀបចំដែននេសាទបំរុងទុក និងការវិនិយោគដែននេសាទដោយអនុវត្តប្រព័ន្ធដេញថ្លៃជាសាធារណៈ ។

ការថែទាំ ការការពារ និងនិរន្តរភាពនៃប្រព័ន្ធផលិតរបស់ទឹករាប់បញ្ចូលទាំងធនធានជលផល ។ ទាំងនេះគឺជាគោលនយោបាយជាអាទិភាពដែលមាននៅក្នុង NWRP ។

អនុក្រឹត្យស្តីពីសហគមន៍នេសាទ ជាត្រីវិស័យក្នុងការកំណត់នីតិវិធី និងបង្កើតរូបមន្តស្របច្បាប់មួយសំរាប់ការគ្រប់គ្រងរួមគ្នានៃសហគមន៍នេសាទទូទាំងប្រទេសកម្ពុជា ។ តួនាទី និងការទទួលខុសត្រូវរបស់សហគមន៍នេសាទ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (MAFF) និងរដ្ឋបាលជលផល មានចែងយ៉ាងច្បាស់នៅក្នុងអនុក្រឹត្យនេះ ។ ដែលក្នុងនោះ MAFF មានសមត្ថកិច្ចគ្រប់គ្រាន់លើការគ្រប់គ្រងសហគមន៍នេសាទ។

អនុក្រឹត្យនេះមានគោលបំណងចំនួនប្រាំចំណុចគឺ:

ក) គ្រប់គ្រងធនធានជលផលទឹកសាបនិងប្រព័ន្ធអេកូឡូស៊ី នៅដែននេសាទក្នុងឡូត៍នេសាទ ដែលបានលុប រឺកាត់បន្ថយសំរាប់នេសាទជាលក្ខណៈគ្រួសារ

ខ) គ្រប់គ្រងធនធានជលផលដោយនិរន្តរភាព និងសមធម៌

គ) បង្កើនការយល់ដឹង និងការទទួលស្គាល់ពីផលប្រយោជន៍របស់ធនធានជលផល តាមរយៈការចូលរួមការពារ និងគ្រប់គ្រង

ឃ) ផ្តល់នូវក្របខ័ណ្ឌច្បាប់ដើម្បីបង្កើតការសហគមន៍នេសាទ និង

ង) កែលម្អបទដ្ឋាននៃការរស់នៅ និងកាត់បន្ថយភាពក្រីក្រ ។

វិស័យវារីអគ្គិសនី និងថាមពល

គោលបំណងនៃយុទ្ធសាស្ត្រលើវិស័យថាមពល របស់ប្រទេសកម្ពុជាឆ្នាំ 1999-2000 មានដូចតទៅ :

- ផ្គត់ផ្គង់អគ្គិសនី អោយបានគ្រប់គ្រាន់នៅទូទាំងប្រទេសកម្ពុជាតាមតំលៃសមរម្យដែលអាចទទួលយកបាន
- ធានាការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាន និងតាមថ្លៃ ដែលសម្រួលដល់ការវិនិយោគនៅកម្ពុជានិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- លើកទឹកចិត្តដល់ការរុករក និងអភិវឌ្ឍន៍ធនធានថាមពលដែលមិនបំផ្លាញបរិស្ថាន និងដែលសង្គមអាចទទួលយកបាន ដែលចាំបាច់សម្រាប់ផ្គត់ផ្គង់ដល់គ្រប់វិស័យនៃសេដ្ឋកិច្ចកម្ពុជា និង
- លើកទឹកចិត្តឱ្យប្រើប្រាស់ថាមពលដោយប្រសិទ្ធិភាព និងកាត់បន្ថយឥទ្ធិពលអវិជ្ជមានចំពោះបរិស្ថាន ដែលបង្កពីការផ្គត់ផ្គង់ និងប្រើប្រាស់ថាមពល។

ច្បាប់អគ្គិសនី ដែលបានប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ 2001 បានចែងអំពីតួនាទីរបស់ស្ថាប័នរដ្ឋាភិបាល ក្នុងការគោរពដល់ផ្នែកអគ្គិសនី ។ នាយកដ្ឋានវារីអគ្គិសនីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) មានភារៈទទួលខុសត្រូវលើការកសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសម្រាប់វិស័យវារីអគ្គសនី ដោយសហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងទីភ្នាក់ងារផ្សេងៗ។

ផ្អែកលើយុទ្ធសាស្ត្រវិស័យថាមពលកម្ពុជាឆ្នាំ 1999-2016 រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តលើគោលនយោបាយអគ្គិសនីកម្មជនបទ តាមរយៈថាមពលកកើតឡើងវិញ (2006) ដែលជាផ្នែកមួយនៃរបៀបវារៈរួមរបស់រាជរដ្ឋាភិបាលលើផ្នែកថាមពល។ គោលនយោបាយនេះមានបំណងបង្កើតក្របខ័ណ្ឌអំណោយផលលំអិតមួយ ដើម្បីទទួលបានបច្ចេកវិទ្យាថាមពលកកើតឡើងវិញ សម្រាប់បង្កើនលទ្ធភាពទទួលបានអគ្គិសនីនៅជនបទ។ ការសិក្សាលើផែនការមេមួយផ្តល់ជាគោលការណ៍ណែនាំសម្រាប់អនុវត្តគម្រោង និងកម្មវិធីនានានៅក្រោមគោលនយោបាយនេះ ។

វិស័យទេសចរណ៍ និងនាវាចរណ៍

គោលនយោបាយ និងច្បាប់ស្តីពីទេសចរណ៍ ស្ថិតនៅជាសេចក្តីព្រាងនៅឡើយ ប៉ុន្តែថ្មីៗនេះ ក្រសួងទេសចរណ៍បានដាក់ច្បាប់ថ្មីជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ។

គោលនយោបាយជាតិស្តីពីទេសចរណ៍ធម្មជាតិ (ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ) ឆ្នាំ 2007 គឺស្ថិតនៅក្នុងដំណើរ

ការសុំការអនុម័តនៅឡើយ ។ សេចក្តីព្រាងគោលនយោបាយនេះផ្តោតលើប្រការនានាដូចតទៅ :

- ផ្តល់វិញ្ញាបនប័ត្រ "បៃតង" ដើម្បីជាការលើកទឹកចិត្តទៅដល់អ្នកទាំងឡាយដែលបាន គោរពតាមគោលការណ៍មិនបំផ្លាញបរិស្ថាន
- លើកទឹកចិត្តដល់ឧស្សាហកម្ម ដើម្បីការពារបរិស្ថាន ក៏ដូចជាការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- លើកកំពស់ការអប់រំអំពីបរិស្ថាន និងការយល់ដឹងនានាដែលពាក់ព័ន្ធជាមួយនឹងសារៈសំខាន់នៃទំនាក់ទំនងរបស់បរិស្ថាន និងវិស័យទេសចរណ៍ ដល់ទាំងប្រទេសសាម៉ី ភ្ញៀវដែលអញ្ជើញមកទស្សនា និង
- បង្កើនថវិការកាន់តែច្រើនឡើងថែមទៀត សំរាប់ការអភិរក្សធនធានធម្មជាតិ តាមរយៈការចូលទស្សនាដោយឥតយកថ្លៃ ពន្ធសម្បទាន និងសកម្មភាពសេដ្ឋកិច្ចដទៃទៀត ។

វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ

នៅឆ្នាំ2003 រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ ក្នុងបំណងផ្តល់សេវាកម្មនៅទូទាំងប្រទេសឱ្យបានមុនឆ្នាំ2025 ។ គោលនយោបាយនេះទទួលស្គាល់អំពីភាពចាំបាច់ក្នុងការចូលរួមរបស់អ្នកពាក់ព័ន្ធនានាក៏ដូចជាវិស័យឯកជន ។ គោលនយោបាយនេះបង្កើតឡើងដោយផ្អែកលើគោលការណ៍បួនៈ

- គុណតម្លៃ និងទំនាក់ទំនងទឹក សង្គម និងសេដ្ឋកិច្ច
- លើកកំពស់អាកប្បកិរិយាដែលមានសុវត្ថិភាព
- សារៈសំខាន់នៃការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានទឹកនៅជនបទ និង
- ការចូលរួមរបស់សហគមន៍ និងការធ្វើសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ។

សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យ បានរៀបចំឡើងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល MIME ទោះជាយ៉ាងណាក៏ដោយសេចក្តីព្រាងនេះ នៅពុំទាន់បានអនុម័តនៅឡើយទេ។ សេចក្តីព្រាងច្បាប់នេះចែងគ្រប់សកម្មភាពដែលទាក់ទងនឹងប្រព័ន្ធផ្គត់ផ្គង់ទឹក និងអនាម័យនៅកម្ពុជា ។

២.២.២ ការចាត់ចែងស្ថាប័នសម្រាប់វិស័យសំខាន់ៗ

ការបង្កើត ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) (1999)

MOWRAM ជាស្ថាប័នគ្រប់គ្រងលើវិស័យធនធានទឹក ។ គោលបំណងរបស់ MOWRAM គឺផ្តល់នូវការគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព និងគ្រប់គ្រងភាពខ្សោយនានា ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក មហន្តរាយលើធនធានទឹក និងធនធានដីត្រូវបានប្របាច់បញ្ចូលគ្នា អោយមានប្រសិទ្ធភាព ដែលត្រូវអនុវត្តនៅក្នុងបរិបទនៃអាងទន្លេ ។

ក្រៅពីនេះ ការចាត់ចែងស្ថាប័ននៅទូទាំងវិស័យសំខាន់ៗ ទាក់ទងនឹងការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ស្ថិតនៅក្រោមអំណាចនៃអង្គភាពផ្សេងៗគ្នា។ តួនាទីរបស់ស្ថាប័ននីមួយៗដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងវិស័យធនធានទឹកមានបង្ហាញ ដូចខាងក្រោម ។

តារាងទី ១. ការចាត់ចែងស្ថាប័ន នៅកម្ពុជា

វិស័យ	ស្ថាប័ន
វិស័យស្រោចស្រព	• នាយកដ្ឋានធារាសាស្រ្ត និងចែកចាយទឹក ទទួលបន្ទុកលើការវិស័យធារាសាស្រ្តនៅកម្ពុជា ។ • ទីភ្នាក់ងារពាក់ព័ន្ធដទៃទៀតសម្រាប់វិស័យនេះគឺ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (MAFF) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD), ក្រសួងបរិស្ថាន (MOE), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) មន្ទីរ និងការិយាល័យធារាសាស្រ្ត នៅថ្នាក់ខេត្ត និងស្រុក ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ (CDC) និង គណៈកម្មការអភិវឌ្ឍន៍ភូមិ (VDC) ។ • ការបង្កើត FWUGs បានចាប់ផ្តើមនៅឆ្នាំ 1999 ។ FWUGs ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង ជួសជុល និងកែលម្អប្រព័ន្ធស្រោចស្រពដែលមានស្រាប់ និងដើម្បីជម្រុញ និងណែនាំការអភិវឌ្ឍប្រព័ន្ធស្រោចស្រព

ថ្មីៗ។ សារាចរលេខ 1 ស្តីពីគោលនយោបាយអនុវត្តសម្រាប់និរន្តរភាពប្រព័ន្ធស្រោចស្រពត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់តួនាទីរបស់ FWUGs ។

វិស័យជលផល	• រដ្ឋបាលជលផល (FiA) នៃ MAFF មានតួនាទីសម្របសម្រួលដល់ការបង្កើតសហគមន៍នេសាទ ។ • ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO) បំពេញបន្ថែមនូវតួនាទីរបស់ FiA ដោយអនុវត្តកំណែទម្រង់គោលនយោបាយនានា កសាងសមត្ថភាពរបស់សហគមន៍នៅទូទាំងប្រទេស ដើម្បីគ្រប់គ្រងសហគមន៍នេសាទថ្មីៗ និងធ្វើការជិតស្និទ្ធជាមួយសង្គមស៊ីវិល។ • វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IRFeDI) ទទួលខុសត្រូវលើការងារស្រាវជ្រាវ និងបង្កើតកម្រងទិន្នន័យជលផល ។ • ខណ្ឌ និងផ្នែករដ្ឋបាលជលផលនៅថ្នាក់ខេត្ត និងស្រុក ប្រតិបត្តិការនៅក្រោម FiA ។ • CDC និង VDC ក៏ពាក់ព័ន្ធនៅក្នុងសកម្មភាពជលផលនៅថ្នាក់ឃុំផងដែរ ។ តួនាទីចំបងរួមមាន ការចូលរួមនៅក្នុងប្រតិបត្តិការរបស់សហគមន៍នេសាទ និងគាំទ្រដល់សហគមន៍នេសាទ ។
វិស័យរ៉ែអគ្គិសនី និងថាមពល	• ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល MIME មានភារៈទទួលខុសត្រូវលើការអភិវឌ្ឍគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសម្រាប់វិស័យថាមពលអគ្គិសនី ក្រោមកិច្ចសហការជាមួយស្ថាប័នអន្តរជាតិ និងស្ថាប័នជាតិ។MIME ក៏សហការជាមួយ MRD, MOE, MOWRAM, MEF, MAFF, គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC), ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា CDC, និងគណៈរដ្ឋមន្ត្រីសម្រាប់សមាហរណកម្មវិស័យនេះផងដែរ។ • អគ្គិសនីកម្ពុជា (EDC) និងអាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ទទួលខុសត្រូវលើវិស័យរ៉ារីអគ្គិសនីនៅកម្ពុជា។
វិស័យទេសចរណ៍ និងនាវាចរណ៍	• ក្រសួងទេចរណ៍ (MoT) ជាក្រសួងនាំមុខក្នុងការគ្រប់គ្រងវិស័យទេសចរណ៍។ • អាជ្ញាធរទេសចរណ៍ជាតិកម្ពុជា (CANTA) នាយកដ្ឋានទេសចរណ៍ និងគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ក៏ជាអង្គភាពមួយយ៉ាងសំខាន់លើការកសាងគោលនយោបាយ និងជាផ្នែកសម្របសម្រួលដ៏សំខាន់ផងដែរ ។ សព្វថ្ងៃនេះ CANTA កំពុងត្រូវបានអភិវឌ្ឍន៍ និងរួមមាននាយកដ្ឋានចំនួនប្រាំបួនទៀតដែលទទួលខុសត្រូវលើទិដ្ឋភាពនានានៃវិស័យទេសចរណ៍ ។
វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ	• ទីភ្នាក់ងារមួយចំនួនរបស់រដ្ឋាភិបាល មានភារៈទទួលខុសត្រូវលើការផ្តល់ គ្រប់គ្រង និងនិយ័តកម្មលើការផ្គត់ផ្គង់ទឹក ។ វិស័យធនធានទឹកទាំងមូល ត្រូវបានបែងចែកជាផ្នែកខុសៗគ្នាជាច្រើន ដែលជាទូទៅភ្នាក់ងារទាំងនោះទទួលខុសត្រូវតាមមុខងារដែលបានបែងចែង ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ជាប្រធានគណៈកម្មាធិការសម្របសម្រួលសម្រាប់ការអភិវឌ្ឍលើការផ្គត់ផ្គង់ទឹក និងអនាម័យ ។ គណៈកម្មាធិការនេះរួមមាន ស្ថាប័នផ្សេងទៀតចំនួន 11 ដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ (MRD), ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM), ក្រសួងសុខាភិបាល (MOH), ក្រសួងបរិស្ថាន (MOE), ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (MAFF), រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងក្រសួងផែនការ ។

អង្គការអាងទន្លេ/ អនុតំបន់	• អនុតំបន់បឹងទន្លេសាបស្ថិតក្រោមការគ្រប់គ្រងនៃអាជ្ញាធរទន្លេសាប ។ អាជ្ញាធរនេះសម្របសម្រួលការអភិវឌ្ឍ គ្រប់គ្រង និងអភិរក្សបឹងនេះ ឋបនីយជីវមណ្ឌលបឹងទន្លេសាប ក្រុមការងារអនុតំបន់ទន្លេសាប (SAWG) ។ SAGW ធ្វើការតាមរយៈកម្មវិធីនៃផែនការអភិវឌ្ឍន៍អាងនេះនៃគណៈកម្មការទន្លេមេគង្គ (MRC) ។ • គណៈកម្មាធិការទន្លេសេសាន ផ្តោតលើបញ្ហាផលប៉ះពាល់នៃទំនប់វារីអគ្គិសនី ចំណែកក្រុមការងារអនុតំបន់ 3S ស្តីពីកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេនៃ MRC ។ ក្រុមសង្គមស៊ីវិលដែលធ្វើការនៅក្នុងតំបន់នេះ រួមមានបណ្តាញការពារទន្លេ 3S សហគមន៍ព្រៃឈើ សហគមន៍នេសាទ FWUGs វេទិកា អង្គការមិនមែនរដ្ឋាភិបាល និងសម្ព័ន្ធភាពទន្លេ ។ ក្រុមទាំងនេះផ្តោតលើបញ្ហាគ្រប់គ្រងធនធានទឹក និងធនធានធម្មជាតិ និងបញ្ហាដែលទាក់ទងជាមួយការអភិវឌ្ឍវារីអគ្គិសនី ។ • ក្រុមការងារអនុតំបន់ស្ទឹងត្រែង-ក្រចេះ ធ្វើការតាមរយៈកម្មវិធី BDP នៃ MRC និងក្រុមសង្គមស៊ីវិល ដូចជាក្រុមសហគមន៍ព្រៃឈើ ក្រុមសហគមន៍នេសាទ FWUGs វេទិកាអង្គការមិនមែនរដ្ឋាភិបាល CEPA, WWF និងសម្ព័ន្ធភាពតំបន់ដីសើម ក៏ធ្វើការនៅក្នុងតំបន់នេះផងដែរ ។ ក្រុមទាំងនេះផ្តោតលើបញ្ហាគ្រប់គ្រងទឹក និងធនធានធម្មជាតិ និងបញ្ហាដែលទាក់ទងនឹងការអភិរក្សសត្វផ្សោត និងការអភិវឌ្ឍវារីអគ្គិសនីផងដែរ ។

អ្នកពាក់ព័ន្ធដទៃទៀត ដែលរួមទាំងទីភ្នាក់ងារផ្តល់ជំនួយ អង្គការជាតិ និងអង្គការអន្តរជាតិ គ្រឹះស្ថានស្រាវជ្រាវ អង្គការសហគមន៍ និងអ្នកដើរតួនៅក្នុងវិស័យឯកជន ក៏ចូលរួមយ៉ាងសកម្មទាក់ទងនឹងកិច្ចការនានានៅទូទាំងវិស័យទាំងអស់ផងដែរ ។

២.៣ ស្ថានភាពនៃវិស័យនានា

២.៣.១ វិស័យធារាសាស្ត្រ

ការស្រោចស្រពនៅកម្ពុជា មានការអភិវឌ្ឍតិចតួចនៅឡើយ ហើយប្រមាណ 80% នៃដីដាំដំណាំពឹងផ្អែកតែលើទឹកភ្លៀងសម្រាប់ការស្រោចស្រព។ ប្រព័ន្ធស្រោចស្រពមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីត្រឹម 30% នៃដំណាំស្រូវប៉ុណ្ណោះ (Veng, 2007) ជាលទ្ធផល ផលិតផលស្រូវជារួមមានកម្រិតទាប។ ការប្រឈមចំបងក្នុងវិស័យស្រោចស្រពរួមមាន :

- កង្វះគ្រឹះស្ថានជនបទដែលរឹងមាំ និងអ្នកផ្តល់សេវាកម្មគាំទ្រ
- ការចូលរួមរបស់កសិករនៅមានកម្រិតនៅក្នុងការកសាងផែនការនិងគ្រប់គ្រងប្រព័ន្ធស្រោចស្រព
- ស្ថានភាពចំពោះមុខច្បាប់នៃ FWUC នៅមានភាពទន់ខ្សោយ
- គ្មានការអនុម័តអំពីសិទ្ធិចំពោះទឹក
- គ្មានការចែកច្បាស់លាស់អំពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋ និងអ្នកប្រើប្រាស់ និង
- ពុំមានការយល់ដឹងនិងចំណេះដឹងលើគោលនយោបាយនិងច្បាប់ ឬមានក្នុងកម្រិតកំណត់ ទាក់ទងនឹងការគ្រប់គ្រងធនធានទឹកក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។

ក្នុងពេលដែលមានការរៀបចំ NSDP ឡើងវិញនៅពេលថ្មីៗនេះ រំវត្តមាន NWRP និងគោលនយោបាយនានា ដែលទាក់ទងនឹងការស្រោចស្រពប្រកបដោយនិរន្តរភាព ជាពិសេសដែលផ្តោតលើការពង្រឹងស្ថានភាពនៃ FWUCs គឺជាជំហានមួយនៅក្នុងទិសដៅត្រឹមត្រូវ ដែលមានសង្គតិភាពកាន់តែច្រើននិងការសម្របសម្រួលក្នុងការគ្រប់គ្រងទឹក និងការកសាងផែនការប្រព័ន្ធស្រោចស្រព។ ដូច្នេះ របៀបវារៈគន្លឹះ ដើម្បីកែលម្អអភិបាលកិច្ចទឹកក្នុងវិស័យស្រោចស្រពគួររួមបញ្ចូល :

- ការចែងបញ្ជាក់អំពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋ និងអ្នកប្រើប្រាស់ (ដែលរួមទាំង ការអនុម័តលើសិទ្ធិប្រើប្រាស់ទឹក) និង
- ការពង្រឹងស្ថានភាពចំពោះមុខច្បាប់នៃ FWUCs ដើម្បីបង្កើតគ្រឹះស្ថានរឹងមាំដែលសម្រួលឱ្យមានការចូលរួមកាន់តែច្រើនថែមទៀតពីសំណាក់កសិករនៅក្នុងការកសាងផែនការ និងគ្រប់គ្រងការស្រោចស្រព។

២.៣.២ វិស័យជលផល និងវារីវប្បកម្ម

ធនធានទឹកសរុប ដែលគាំទ្រដល់ជលផលទឹកសាបនៅកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានវិសាលភាពសរុប 1.867 លានហិកតា ក្នុងនោះដែនទឹកអចិន្ត្រៃយ៍មានទំហំ 567.000 ហិកតា ឬ 30.4% (NIS, 2006)។ ព្រៃលិចទឹកតាមរដូវ វាលស្មៅ វាលស្រែ និងវាលភក់ មានទំហំ 1.3 លានហិកតា ហើយទីជម្រកដទៃទៀតមាន 69.6%។ វិស័យជលផលមានសារៈសំខាន់ណាស់ក្នុងប្រទេសកម្ពុជា ដោយសារវារួមចំណែកយ៉ាងច្រើនចំពោះសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ព្រោះថាធនធានជលផលទឹកសាបដែលសំបូរបែបកើតមាន ជាពិសេសនៅក្នុងប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ និងទន្លេសាប។ ផលត្រីចាប់បានក្នុងមួយឆ្នាំមានកម្រិតខ្ពស់ ជាពិសេសនៅក្នុងរដូវចាប់ត្រីបានបំផុត ចាប់ពីខែវិច្ឆិកា-កុម្ភៈ។ យោងតាមការពិនិត្យដោយ CNMC-BDP លើវិស័យជលផលនៅក្នុងឆ្នាំ 2003 គេបានប៉ាន់ប្រមាណថា ផលនេសាទទឹកសាបមានពី 200.000 ដល់ 430.000 តោនក្នុងមួយឆ្នាំ ដែលមានតម្លៃរហូតដល់ 500 លានដុល្លាអាមេរិក[3]។

ដូចដែលវិភាគលំអិតខាងលើ (សូមអានផ្នែក 2.2: គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងស្ថាប័ន) កិច្ចផ្តួចផ្តើមជលផល ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី 24 ខែតុលា ឆ្នាំ 2000 ដើម្បីគាំទ្រសិទ្ធិរបស់ប្រជាជននៅជនបទ ក្នុងការប្រើប្រាស់ធនធានដោយនិរន្តរភាព និងកែលម្អអភិបាលកិច្ចនៅក្នុងវិស័យនេះ។ ច្បាប់ជលផលថ្មី និង អនុក្រឹត្យសហគមន៍នេសាទ ក៏ផ្តល់នូវក្របខ័ណ្ឌច្បាប់លំអិតមួយសម្រាប់ការបង្កើត និងគ្រប់គ្រងសហគមន៍ជលផលផងដែរ។

នៅក្រោមកំណែទម្រង់នេះ ដែននេសាទទឹកសាបប្រមាណ 538.522 ហិកតា ត្រូវបានកាត់ចេញពីឡូត៍សម្រាប់បង្កើតសហគមន៍នេសាទ។ ការធ្វើបែបនេះបានកាត់បន្ថយទំនាស់ និងការនេសាទ

[3] ទោះជាយ៉ាងណាក៏ដោយ តួលេខនេះអាចទាបជាងតួលេខពិតប្រាកដ ដោយសារការប្រមូលទិន្នន័យមិនមានសុក្រឹត្យ។

ល្មើសច្បាប់ ដែលបានកើនឡើងនៅកន្លែងខ្លះៗ បើទោះជាបញ្ហាថ្មីនៃការគ្រប់គ្រង និងអភិបាលកិច្ចបានកើតឡើងវិញ ដោយសារតែអំពើពុករលួយ ផលចំណូលហិរញ្ញវត្ថុមានកម្រិតទាប កង្វះការសម្របសម្រួលក្នុងចំណោមទីភ្នាក់ងាររបស់រដ្ឋាភិបាល កម្រិតទាបនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងអវត្តមានយន្តការច្បាប់ ដើម្បីធានាឱ្យមានការអនុវត្តក៏ដោយ។ លើសពីនេះ វិស័យជលផលកំពុងប្រឈមនឹងកំណើនហានិភ័យ បណ្តាលពីសំណើអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីទាំងនៅក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសជិតខាង ដែលស្ថិតនៅតំបន់ខ្សែទឹកខាងលើ។

ការលំបាកចំបងៗ ដែលវិស័យជលផលបានប្រឈមរួមមាន :

- សិទ្ធិសមស្របរបស់ជនក្រីក្រកម្ពុជា ក្នុងការធ្វើនេសាទ និងការប្រើប្រាស់ធនធានជលផល
- ត្រួតពិនិត្យការនេសាទល្មើសច្បាប់ និងការធ្វើអាជីវកម្មធនធានតាមរបៀបដែលមានលក្ខណៈបំផ្លាញ
- ភាពទន់ខ្សោយនៃការចាត់ចែងស្ថាប័នសម្រាប់គ្រប់គ្រងឡូត៍នេសាទ និងកម្រិតកំណត់នៃការអនុវត្តច្បាប់ជលផល
- ការរេចរឹលធនធានជលផលដែលរួមទាំងផលប៉ះពាល់ដែលអាចកើតឡើងពីគម្រោងអភិវឌ្ឍថាមពលវារីអគ្គិសនីដែលមានស្រាប់ (និងលើកស្នើថ្មី) នៅតាមដងទន្លេមេគង្គ ទាំងនៅកម្ពុជា និងនៅតំបន់ខ្សែទឹកខាងលើ និង
- វត្តមានធនធានខុសៗគ្នាដែលពឹងផ្អែកលើទឹកជំនន់សមស្របនិងមុខនាទីនៃប្រព័ន្ធអេកូឡូស៊ី។ ចំណុចបួនចុចបីខាងដើម គឺជាបញ្ហាដែលពិតជាទាក់ទងនឹង អភិបាលកិច្ចនៅកម្ពុជា រីឯចំណុចទីបួននិងទីប្រាំទាក់ទងផងដែរទៅនឹងបញ្ហាអភិបាលកិច្ចថ្នាក់តំបន់ ឬ ឆ្លងដែនរវាងប្រទេសនៅជិតខាង។ របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យជលផលនៅកម្ពុជារួមមាន :
- កំណែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា
- ការបង្កើតយន្តការដើម្បីដោះស្រាយអំពើពុករលួយ
- កំណែលម្អការពង្រឹងលើការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានានិង
- កំណែលម្អយន្តការនៅថ្នាក់តំបន់សម្រាប់ដំណើរការធ្វើសេចក្តីសម្រេចអំពីការអភិវឌ្ឍនៅតំបន់ខ្សែទឹកខាងលើដែលនឹងមានឥទ្ធិពលឆ្លងដែន។

២.៣.៣ វិស័យវារីអគ្គិសនី និងថាមពល

បច្ចុប្បន្ននេះ មានតែ 18% នៃគ្រួសារនៅកម្ពុជា ដែលមានលទ្ធភាពប្រើប្រាស់អគ្គិសនី ពោលគឺ 54% នៃគ្រួសារនៅទីក្រុង និង13% នៃគ្រួសារនៅជនបទ។ ការផ្គត់ផ្គង់អគ្គិសនីសព្វថ្ងៃ បានមកពីប្រព័ន្ធផលិតថាមពលតូចៗនៅដាច់ដោយឡែកចំនួន 22 ដែលបានពីដំណុតឥន្ធនៈផូស៊ីល។ ដើម្បីបំពេញកំណើនតម្រូវការ និងកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈដែលនាំចូល ការអភិវឌ្ឍថាមពលវារីអគ្គិសនី ត្រូវបានចាត់ទុកថាជាប្រការចាំបាច់។ ការសិក្សាមួយដែលបានធ្វើឡើងដោយ MRC នៅឆ្នាំ 1995 បានបង្ហាញឱ្យឃើញថា សក្តានុពលថាមពលវារីអគ្គិសនីនៅកម្ពុជាគឺ 10.000 MW ក្នុងនោះ 80% បានមកពីទន្លេមេគង្គ និងដៃនានានៃទន្លេនេះ។ សព្វថ្ងៃនេះ មានគម្រោងថាមពលវារីអគ្គិសនីមួយចំនួនតូចប៉ុណ្ណោះនៅកម្ពុជា ប៉ុន្តែគម្រោងចំនួនច្រើនត្រូវបានលើកស្នើ ហើយវិស័យនេះកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។

ការអភិវឌ្ឍថាមពលវារីអគ្គិសនី គឺជាប្រធានបទចម្រូងចម្រាស់ខ្លាំងមួយនៅក្នុងវិស័យអភិបាលកិច្ចទឹក ដោយសារផលប៉ះពាល់ដែលអាចមានមកលើប្រជាជន និងបរិស្ថាន និងធនធានដែលពាក់ព័ន្ធជាមួយទឹក និងមានមេរៀនជាច្រើនដែលត្រូវរៀនសូត្រ (Middleton and Sam Chanthy, 2008; 3S Rivers Protection Network, 2007; Sam Chamroeun, 2006; NGO Forum, 2005; Australian Mekong Resource Centre, 2002)។ ក្នុងពេលដែលរដ្ឋាភិបាលកម្ពុជាកំពុងជម្រុញការអភិវឌ្ឍថាមពលវារីអគ្គិសនីដោយសព្វថ្ងៃនេះកំពុងស្ថិតនៅដំណាក់កាលដំបូងមួយនៃការអភិវឌ្ឍវត្តមាននៃដំណើរការច្បាស់លាស់ខាងអភិបាលកិច្ច និងការធ្វើសេចក្តីសម្រេច គឺជាប្រការចាំបាច់ ដើម្បីធានាថា រាល់កិច្ចការនិងបញ្ហានានាត្រូវបានរាយការណ៍ និងបានពិចារណា។ នាយកដ្ឋានវារីអគ្គិសនីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល MIME មានភារៈកិច្ចទទួលខុសត្រូវលើការអភិវឌ្ឍគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសម្រាប់វិស័យថាមពលវារីអគ្គិសនីនៅកម្ពុជា។ ក្រសួងបរិស្ថាន MoE បានបង្កើតគោលនយោបាយមួយចំនួន ដែលរួមទាំងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (1996) ដែលតម្រូវឱ្យធ្វើការវាយតម្លៃ EIA លើគ្រប់គម្រោង និងសកម្មភាព

ទាំងគម្រោងឯកជន និងសាធារណៈ ហើយរបាយការណ៍នេះត្រូវតែដាក់ជូនទៅ MOE ដើម្បីពិនិត្យ។ MIME មិនយល់អំពីឧបករណ៍ EIA ទេ ហើយ MOE មានភារៈទទួលខុសត្រូវលើការវាយតម្លៃរបាយការណ៍ EIA ។

របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យថាមពលវារីអគ្គិសនីនៅកម្ពុជា គួររួមបញ្ចូល :

- កសាងគោលនយោបាយ គោលការណ៍ណែនាំ និងក្របខ័ណ្ឌច្បាប់សម្រាប់អភិវឌ្ឍន៍ថាមពលវារីអគ្គិសនី
- បង្កើនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដែលរួមទាំងសហគមន៍ និងវិស័យឯកជន
- បង្កើនព័ត៌មានដែលទាក់ទងនឹងផលប៉ះពាល់នៃការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការគ្រប់គ្រង និងវិធានការដែលលើកស្នើឡើងដើម្បីកាត់បន្ថយហានិភ័យនានា និង
- ផ្តល់ឱកាសសម្រាប់ការពិភាក្សាជាសាធារណៈអំពីបញ្ហា និងវិធានការសំខាន់ៗ។

២.៣.៤ វិស័យទេសចរណ៍ និងនាវាចរណ៍

កម្ពុជាមានបណ្តាញទន្លេទូលំទូលាយ និងបឹង ជាពិសេសនៅក្នុងតំបន់ទំនាបកណ្តាល ដែលអាចធ្វើនាវាចរណ៍យ៉ាងហោចណាស់បានជាច្រើនខែក្នុងមួយឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលរបបទឹក លក្ខណៈរូប និងកំទេចកំណកនៅក្នុងទន្លេ ស្ទឹង និងបឹង អាចរងផលប៉ះពាល់មកលើនាវាចរណ៍ ទេសចរណ៍ និងការដឹកជញ្ជូនតាមផ្លូវទឹក។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយដូចតទៅ :

- លើកកំពស់ការប្រើប្រាស់ផ្លូវទឹក ទាំងផ្លូវទឹកធម្មជាតិ និងសិប្បនិម្មិត សម្រាប់ការដឹកជញ្ជូនធុនធំ ទេសចរណ៍ និងនាវាចរណ៍
- ពិចារណាអំពីឥទ្ធិពលនៃការគ្រប់គ្រងលំហូរនិងកម្រិតកំពស់ទឹកនៅក្នុងទន្លេ ពាមសមុទ្រ បឹង ប្រឡាយ អាងស្តុកទឹក និងសមុទ្រទៅតាមសក្តានុពលនៃការប្រើប្រាស់សម្រាប់នាវាចរណ៍ និងទេសចរណ៍
- ជំរុញការជីកស្តារនៅកន្លែងសំខាន់ៗ ទន្ទឹមនឹងកិច្ចប្រឹងប្រែងដើម្បីការពារ និងអភិរក្សដែនទឹក និងផ្លូវទឹកធម្មជាតិសម្រាប់នាវាចរណ៍ និងទេសចរណ៍។

ទេសចរណ៍ជាវិស័យកំពុងរីកចម្រើនឆាប់រហ័សមួយនៅកម្ពុជា ហើយចំណូលដែលបានមកពីវិស័យនេះបានរួមចំណែកទៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) បានកើនឡើងពី 6,3% នៅឆ្នាំ 2000 ហើយកើនជិតដល់ 16% នៅឆ្នាំ 2007។ អេកូទេសចរណ៍ធម្មជាតិ និងទេសចរណ៍ដែលផ្តល់ប្រយោជន៍ដល់ជនក្រីក្រ កំពុងត្រូវបានជម្រុញយ៉ាងខ្លាំងក្លា ដោយសារ 95% នៃអ្នកក្រីក្រ ដែលរស់នៅជិតទីតាំងតំបន់ធម្មជាតិ ដែលមានសក្តានុពលសម្រាប់ទេសចរណ៍។

វិស័យទេសចរណ៍ដែលផ្តល់ប្រយោជន៍ដល់អ្នកក្រ ប្រកបដោយនិរន្តរភាព មានគោលដៅពង្រឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅមូលដ្ឋានតាមគំរូដែលនឹងជួយកាត់បន្ថយភាពក្រីក្រ បង្កើនតួនាទីនៃលក្ខណៈវិនិច្ឆ័យកាត់បន្ថយភាពក្រីក្រក្នុងការសម្រេចបាននូវការអភិវឌ្ឍទេសចរណ៍នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត និងបង្កើនការយកចិត្តទុកដាក់លើទេចរណ៍និរន្តរភាពឱ្យប្រហាក់ប្រហែលនឹងការយកចិត្តទុកដាក់ចំពោះឧស្សាហកម្មដទៃទៀត នៅក្នុងគោលនយោបាយ និងសកម្មភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលផងដែរ។

សកម្មភាពនានាដែលកំពុងអនុវត្ត ទាក់ទងនឹងកិច្ចផ្តួចផ្តើមខាងទេសចរណ៍ រួមមាន ការសិក្សាមួយអំពីទេចរណ៍ដែលផ្តល់ប្រយោជន៍ដល់ជនក្រីក្រ ដែលអនុវត្តដោយបណ្តាញវិភាគការអភិវឌ្ឍ[4] នៅក្នុងប្រទេសចំនួនប្រាំនៃមហាអនុតំបន់មេគង្គ។ អង្គការអភិវឌ្ឍន៍របស់ប្រទេសហូឡង់ (SNV) ក៏កំពុងរួមចំណែកកាត់បន្ថយភាពក្រីក្រផងដែរ តាមរយៈអេកូទេសចរណ៍ និងនិរន្តរភាពទេសចរណ៍នៅកម្ពុជា។

របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ចខាងនាវាចរណ៍ និងវិស័យទេសចរណ៍ គួរតែរួមបញ្ចូល :

- ការកសាងគោលនយោបាយជាតិអេកូទេសចរណ៍
- ការអនុម័តច្បាប់ស្តីពីទេសចរណ៍
- ការអភិវឌ្ឍស្ថាប័នCNATAជាបន្តនិងកែលម្អការសម្របសម្រួលខាងស្ថាប័ននិងគោលនយោបាយ ការចែងបញ្ជាក់អំពីព្រំដែន

[4] បណ្តាញវិភាគការអភិវឌ្ឍ គឺជាបណ្តាញមួយដែលមានវិទ្យាស្ថានស្រាវជ្រាវចំនួនប្រាំពីរមកពីកម្ពុជា ឡាវ ថៃ និងវៀតណាម ដែលសម្របសម្រួលដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស (CDRI) ក្រោមការគាំទ្រពីមូលនិធិ Rockefeller ។ DAN លើកឡើងនូវកិច្ចផ្តួចផ្តើមស្រាវជ្រាវចំបងៗដែលជាចំណាប់អារម្មណ៍នៅថ្នាក់តំបន់។

នៃការទទួលខុសត្រូវក្នុងចំណោមទីភ្នាក់ងារនៃរាជរដ្ឋាភិបាល

- ពង្រឹងស្ថាប័នសហគមន៍មូលដ្ឋានសម្រាប់គ្រប់គ្រងទេសចរណ៍ និងកែលម្អអំណាចចរចារបស់ពួកគេជាមួយប្រតិបត្តិករទេសចរណ៍ជាលក្ខណៈពាណិជកម្ម និង
- បង្កើតយន្តការចែករម្លែកផលប្រយោជន៍ឱ្យបានច្បាស់លាស់

២.៣.៥ វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ

ទោះបីកម្ពុជាសំបូរដោយធនធានទឹកសាប ក៏ដោយមានតែ 30% នៃគ្រួសារនៅជនបទ ដែលអាចប្រើប្រាស់ទឹកស្អាតចំណែក 12% មានលទ្ធភាពទទួលបានសេវាកម្មអនាម័យប្រសើរជាងមុន។

នៅឆ្នាំ 2003 រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តគោលនយោបាយ វិស័យផ្គត់ផ្គង់ទឹក និងអនាម័យក្នុងបំណងផ្តល់សេវាឱ្យបានទូទាំង នៅមុនឆ្នាំ 2025។ គោលនយោបាយនេះទទួលស្គាល់អំពីតម្រូវការចាំបាច់ឱ្យអ្នកពាក់ព័ន្ធនានាចូលរួម និងការពាក់ព័ន្ធនៃវិស័យឯកជន។ បន្ទាប់ពីមានការអនុម័តគោលនយោបាយនេះ MRD បានផ្តួចផ្តើមដំណើរការបង្កើត និងអនុម័តគោលការណ៍ណែនាំនានាដែលទាក់ទងនឹងការយល់ដឹងអំពីជម្រើស និងការចូលរួមនៃវិស័យឯកជន ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្ររួមសំរាប់អនុវត្តគោលនយោបាយនេះ នៅពុំទាន់បានបង្កើតនៅឡើយទេ។

វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ នៅតែប្រឈមនឹងការលំបាកជាច្រើន ដែលរួមទាំងកង្វះទឹកនៅរដូវប្រាំងក្នុងខេត្ត និងទីកន្លែងខ្លះៗ ការថយចុះនៃគុណភាពទឹក កង្វះសម្ភារៈពិនិត្យ និងប្រព្រឹត្តកម្មសំអាតទឹក ចំណេះដឹងមិនគ្រប់គ្រាន់អំពីបញ្ហាផ្គត់ផ្គង់ទឹក និងអនាម័យ និងកម្រិតទាបនៃការយល់ដឹងនៅជនបទនៃកម្ពុជា។

របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ចនៃវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ គួរតែរាប់បញ្ចូល ៖

- ការបង្កើតយុទ្ធសាស្ត្ររួមសម្រាប់អនុវត្តគោលនយោបាយជាតិវិស័យផ្គត់ផ្គង់ទឹក និងអនាម័យឆ្នាំ 2003
- ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យ
- កែលម្អទំនាក់ទំនងអន្តរក្រសួង
- ការចែងបញ្ជាក់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ WSUGs
- ការបង្កើតយន្តការច្បាស់លាស់ ដំណើរការ និងការលើកទឹកចិត្តសម្រាប់បង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ជាពិសេសក្រុមជនក្រីក្រជាងគេ និង
- បង្កើតឱកាសសម្រាប់បង្កើនការចូលរួមពីវិស័យឯកជន។

២.៤ ការសន្និដ្ឋាន-ឧបសគ្គ និងអនុសាសន៍

២.៤.១ ឧបសគ្គ

មានកត្តាជាច្រើនដែលជាឧបសគ្គក្នុងការអនុវត្តគោលនយោបាយនិងការអនុវត្តច្បាប់និងក្របខ័ណ្ឌច្បាប់នានាដែលទាក់ទងនឹងការគ្រប់គ្រង និងអភិបាលទឹកនៅកម្ពុជាឱ្យមានប្រសិទ្ធិភាព។ ឧបសគ្គទាំងនេះរួមមាន ៖

- ការគួសបញ្ជាក់មិនបានច្បាស់លាស់អំពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវក្នុងចំណោមក្រសួងនានារបស់រដ្ឋាភិបាល
- កម្រិតកំណត់នៃកិច្ចសហការនិងការប្រាស្រ័យឆ្លើយឆ្លងរវាងក្រសួងនានារបស់រដ្ឋាភិបាល
- ការចូលរួមរបស់អ្នកពាក់ព័ន្ធមានកំរិតទាប តម្លាភាព និងការពិគ្រោះយោបល់នៅក្នុងពេលបង្កើតគោលនយោបាយ និងដំណើរការធ្វើសេចក្តីសម្រេចនៅមានកំរិត
- ការយល់ដឹង និងចំណេះដឹងអំពីគោលនយោបាយ និងច្បាប់ពីសំណាក់មន្ត្រីរដ្ឋាភិបាល និងសាធារណជនជាទូទៅនៅខ្សោយនៅឡើយ និង
- កម្រិតកំណត់នៃការអនុវត្ត IWRM និងដំណើរការគ្រប់គ្រងអាងទន្លេ

ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងអំពីបញ្ហាទាំងនេះកំពុងតែកើនឡើង ហើយក្រុមការងារបច្ចេកទេសមួយចំនួន ក៏បានបង្កើតរួចមកហើយដែរ ដើម្បីកែលម្អអភិបាលកិច្ច ដែលរួមបញ្ចូលអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនេះ។ ស្ថានភាពនេះ មានលក្ខណៈអំណោយផលជាបង្គួរសម្រាប់ MWD ដើម្បីផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរលើដំណើរការអភិបាលកិច្ច និងទស្សនៈវិស័យនៅកម្ពុជា។

តារាងទី ២. របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅប្រទេសកម្ពុជា

វិស័យ	របៀបវារៈសំខាន់ៗសម្រាប់កែលម្អអភិបាលកិច្ច
ធារាសាស្ត្រ	• ការចែងបញ្ជាក់អំពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋ និងអ្នកប្រើប្រាស់ (ដែលរួមទាំង ការអនុម័តអំពីសិទ្ធិចំពោះទឹកផងដែរ) • ការពង្រឹងភាពស្របច្បាប់របស់ FWUCs ប្រែក្លាយគណៈកម្មការនេះឱ្យទៅជាស្ថាប័នដ៏រឹងមាំនៅមូលដ្ឋាន • សម្រួលឱ្យកសិករបានចូលរួមកាន់តែច្រើនបន្ថែមទៀតនៅក្នុងការកសាងផែនការនិងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព
ជលផល និងវារីវប្បកម្ម	• កែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា • បង្កើតយន្តការដើម្បីដោះស្រាយអំពើពុករលួយ • កែលម្អការអនុវត្តច្បាប់ និងបទបញ្ជានានា • កែលម្អយន្តការថ្នាក់តំបន់ សម្រាប់ដំណើរការសម្រេចនានាអំពីការអភិវឌ្ឍនៅតំបន់ខ្សែទឹកខាងលើដែលនឹងមានផលប៉ះពាល់ឆ្លងដែន
វារីអគ្គិសនី និងថាមពល	• កសាងគោលនយោបាយ គោលការណ៍ណែនាំ និងក្របខ័ណ្ឌច្បាប់សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនី • បង្កើនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមគ្រឹះស្ថានសំខាន់ៗ និងអ្នកពាក់ព័ន្ធនានា ដែលរួមទាំងសហគមន៍ និងវិស័យឯកជនផងដែរ • បង្កើនព័ត៌មានដែលទាក់ទងនឹងផលប៉ះពាល់អំពីការអភិវឌ្ឍវារីអគ្គិសនី និងដំណើរគ្រប់គ្រង និងវិធានការកាត់បន្ថយហានិភ័យ • ផ្តល់ឱកាសសម្រាប់ការពិភាក្សាជាសាធារណៈអំពីបញ្ហា និងវិធានការសំខាន់ៗ
ផ្គត់ផ្គង់ទឹក និងអនាម័យ	• ការអនុម័តច្បាប់ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យ • ការបង្កើតយុទ្ធសាស្ត្ររួម ដើម្បីអនុវត្តគោលនយោបាយជាតិវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ • កែលម្អទំនាក់ទំនងអន្តរក្រសួង • ចែងបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ WSUGs • ការបង្កើតយន្តការ ដំណើរការ និងការលើកទឹកចិត្តច្បាស់លាស់សម្រាប់បង្កើនការចូលរួមនៃអ្នកពាក់ព័ន្ធនានា ជាពិសេសក្រុមជនក្រីក្រ • ការបង្កើតឱកាសសម្រាប់បង្កើនការពាក់ព័ន្ធនៃវិស័យឯកជន
ទេសចរណ៍ និងនាវាចរណ៍	• ការអនុម័តលើគោលនយោបាយជាតិស្តីពីអេកូទេសចរណ៍ • អនុម័តលើច្បាប់ស្តីពីទេសចរណ៍ • ការអភិវឌ្ឍជាបន្ថែមនូវស្ថាប័ន CANTA, ការកែលម្អស្ថាប័ន និងការសម្របសម្រួលគោលនយោបាយ និងគូសបញ្ជាក់អំពីព្រំដែននៃការទទួលខុសត្រូវក្នុងចំណោមទីភ្នាក់ងារនានានៃរដ្ឋាភិបាល • ពង្រឹងស្ថាប័នសហគមន៍មូលដ្ឋាន សម្រាប់គ្រប់គ្រងទេសចរណ៍ និងកែលម្អអំណាចចរចារបស់ពួកគេជាមួយប្រតិបត្តិករទេសចរណ៍ជាលក្ខណៈពាណិជកម្ម • ការបង្កើតយន្តការបែងចែកផលប្រយោជន៍ឱ្យបានច្បាស់លាស់

២.៤.២ អនុសាសន៍

ការសិក្សាវិភាគស្ថានភាពនេះ បង្ហាញអំពីបញ្ហាសំខាន់ៗមួយចំនួនដែលមានសារៈសំខាន់សម្រាប់កែលម្អអភិបាលទឹកនៅកម្ពុជា *(សូមអានតារាងទី 2 ខាងលើ)* ។

តំរូវអោយមានគោលនយោបាយ និងក្របខ័ណ្ឌច្បាប់បន្ថែមដែលទាក់ទងនឹង IWRM និងការតម្រង់ទិសអង្គការអាងទន្លេ

ការកំណត់អំពីសិទ្ធិលើការប្រើប្រាស់ទឹក និង តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងនាមជាស្ថាប័ននិយ័តកម្មលើវិស័យទឹក និងអ្នកផ្តល់សេវាគាំទ្រដល់ FWUG ។ យើងស្នើឱ្យពិនិត្យមើលប្រធានបទដូចខាងក្រោមនេះ និងពិចារណានៅក្នុងកិច្ចពិគ្រោះយោបល់អំពីទឹកនៅថ្នាក់ជាតិ សម្រាប់ឆ្នាំ 2009-2010:

- IWRM ជាវិធានសម្រាប់អភិវឌ្ឍន៍ទឹកដោយសមធម៌ និងដោយនិរន្តរភាព
- បញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹងការគ្រប់គ្រងធនធានជលផល
- បញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹងការកសាងផែនការ សិទ្ធិ និងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និង
- បញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹងការអភិវឌ្ឍថាមពលវារីអគ្គិសនីនិងការគ្រប់គ្រងផលប៉ះពាល់ ។

៣. ប្រទេសឡាវ

៣.១ ទិដ្ឋភាពរួម

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលមានផ្ទៃដី 236.800 គម^2 និងប្រជាជន 6 លាននាក់ គឺជាប្រទេសក្រីក្រជាងគេមួយនៅអាស៊ីអាគ្នេយ៍។ ប្រមាណ 97%នៃទឹដីជនបទដែលជាតំបន់ភ្នំនៃប្រទេសនេះ ស្ថិតនៅក្នុងអាងរងទឹកភ្លៀងនៃទន្លេមេគង្គក្រោម ដែលហូរកាត់ប្រទេសនេះពីជើងទៅត្បូង។ ធនធានទឹកជាមធ្យមប្រចាំឆ្នាំនៅក្នុងប្រទេសឡាវមាន 272 គម^3 ដែលសមមូលនឹងច្រើនជាង 55,000 ម៉ែត្រគូបក្នុងម្នាក់ៗក្នុងមួយឆ្នាំ ដែលផ្តល់ឱ្យប្រទេសឡាវបរិមាណទឹកក្នុងម្នាក់ៗ កម្រិតខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ទឹកគឺជាធនធានធម្មជាតិសំខាន់មួយដែលដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រទេសឡាវ។

ដូច្នេះរបាយការណ៍នេះប៉ុនប៉ងធ្វើអត្តសញ្ញាណទៅលើ ការចាត់ចែងអភិបាលកិច្ចសំខាន់ៗមួយចំនួនលើវិស័យប្រើប្រាស់ទឹក និងស្វែងរកការយល់ដឹងអំពីរបៀបចាត់ចែងអោយមានប្រសិទ្ធភាពដែលផ្តល់កង្វល់ចំបងៗរបស់ខ្លួនដែលទាក់ទងនឹងទឹក។ ភាពខ្វះខាត និង អាទិភាពនានាសម្រាប់កែលម្អអភិបាលកិច្ចត្រូវបានធ្វើអត្តសញ្ញាណ ហើយប្រការទាំងនេះ MWD អាចជួយចាប់ផ្តើមលើងឡើង និងគូសបញ្ជាក់។

៣.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងស្ថាប័ន

គោលនយោបាយ ច្បាប់ និងការចាត់ចែងស្ថាប័ន ត្រូវបានយោងជាទូទៅថាជាបញ្ហាសំខាន់គន្លឹះលើផ្នែកអភិបាលកិច្ចទឹក ដោយសារបញ្ហាទាំងនេះរួមគ្នា កំណត់អំពីក្របខ័ណ្ឌដែលជាមធ្យោបាយសម្រាប់ប្រទេសនេះក្នុងការគ្រប់គ្រងធនធានទឹករបស់ខ្លួននិងជាយន្តការ សម្រាប់ប្រជាជនធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាលរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចនានាដែលទាក់ទងនឹងទឹក។

៣.២.១ គោលនយោបាយ ច្បាប់ កិច្ចព្រមព្រៀង និងយុទ្ធសាស្ត្រ

ច្បាប់និងគោលនយោបាយនានា ដែលតម្រង់ទិសដល់វិស័យទឹករួមមាន:

ក្របខ័ណ្ឌថ្នាក់តំបន់

ប្រទេសឡាវគឺជាហត្ថលេខីនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ 1995

ក្របខ័ណ្ឌជាក់លាក់សម្រាប់ប្រទេស។

ច្បាប់ស្តីពីទឹក និងធនធានទឹក ឆ្នាំ 1996 គឺជាច្បាប់សំខាន់មួយដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹកក្នុងប្រទេសឡាវ។ ច្បាប់នេះផ្តោតជាសំខាន់លើកិច្ចការពារធនធានទឹក ការកសាងផែនការធនធានទឹក និងទប់ស្កាត់ការបំពុលទឹក។ ច្បាប់នេះគាំទ្រដល់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ទឹក អនុលោមតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ច្បាប់នេះចែងអំពីប្រភេទនានានៃធនធានទឹក និងអំពីការប្រើប្រាស់ទឹកតាមទម្រង់ផ្សេងៗ។

ច្បាប់នេះក៏ចែងលំអិតអំពីផែនការសកម្មភាពអភិវឌ្ឍន៍ទឹកនិងកិច្ចការពារប្រភពទឹកផងដែរ ទន្ទឹមនឹងការកំណត់អំពីសិទ្ធិរបស់អ្នករស់នៅតាមដងទន្លេក៏ដូចជាការទទួលខុសត្រូវ និងសិទ្ធិរបស់ទីភ្នាក់ងារនានាក្នុងការអនុវត្តសកម្មភាពដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ទីភ្នាក់ងាររដ្ឋបាលនានាត្រូវបានចែងឡើង ដោយមានការទទួលខុសត្រូវទប់ស្កាត់ទឹកជំនន់ សំណឹកដី និងការបំពុលទឹក។ បញ្ហាគ្រប់គ្រងទឹកឆ្លងដែនក៏មានចែងផងដែរ។ ច្បាប់នេះចែងមិនបានច្បាស់ឡើយអំពីមាត្រាខ្លះៗស្តីពីការចេញអាជ្ញាប័ណ្ណប្រើប្រាស់ទឹក។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះពុំមានមាត្រាដែលចែងអំពីការចូលរួមរបស់សង្គមស៊ីវិលក្នុងដំណើរការកសាងគោលនយោបាយឡើយ។

ក្រឹត្យច្បាប់ឆ្នាំ 1999 អំពីការអនុវត្តច្បាប់ស្តីពីទឹក និងធនធានទឹក បានកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានទឹក។ ក្រសួងពាក់ព័ន្ធនានាដែលមានចែងនៅក្នុងពេលនោះគឺ ក្រសួងកសិកម្ម និងព្រៃឈើ (MAAF) ក្រសួងគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ និងសំណង់ (MCTPC) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH) ក្រសួងសុខាភិបាលសាធារណៈ (MPH) ក្រសួងពាណិជ្ជកម្ម និងទេសចរណ៍ (MTT)

ទីភ្នាក់ងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន (STEA) គណៈកម្មាធិការជាតិទន្លេមេគង្គឡាវ (LMNC) និង គណៈកម្មាធិការសម្របសម្រួលធនធានទឹក (WRCC)។ ក្រសួង និង ទីភ្នាក់ងារទាំងនេះត្រូវបានគេរំពឹងថានឹងធ្វើការសម្របសម្រួលជាមួយ អាជ្ញាធរមូលដ្ឋាននៅក្នុងការកំណត់អំពីការទទួលខុសត្រូវលំអិត និងព្រំដែននៃសកម្មភាពនៅក្នុងវិស័យទាំងនេះ។ ក្រឹត្យនេះផ្តល់អំណាចដល់ទីភ្នាក់ងារទាំងនេះ ក្នុងការអនុវត្តកិច្ចការនានាដែលមានចែងនៅក្នុងច្បាប់ស្តីពីទឹក និងធនធានទឹក។

នៅឆ្នាំ 2003 រដ្ឋាភិបាលឡាវ បានអនុម័តគាំទ្រលើយុទ្ធសាស្ត្រជាតិស្តីពីកំណើននិងការកាត់បន្ថយភាពក្រីក្រ(NGPES) 2003 ដែលកំណត់អំពីក្របខ័ណ្ឌសម្រាប់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។ យុទ្ធសាស្ត្រនេះចែងអំពីការបង្កើតផែនការសម្រាប់វិស័យនានារបស់ជាតិដើម្បីលើកកំពស់កំណើន និងការកាត់បន្ថយភាពក្រីក្រដោយនិរន្តរភាព ដោយបង្កើតគោលនយោបាយ និងគម្រោងអាទិភាព។ ផែនការតាមវិស័យរបស់ជាតិត្រូវបានចាត់ចែងឡើងជា 8 ផ្នែក :

- ផែនការអភិវឌ្ឍន៍កសិកម្ម/ព្រៃឈើ ដែលផ្តោតលើភាពក្រីក្រ
- ផែនការសកម្មភាពអភិវឌ្ឍន៍ការអប់រំដែលផ្តោតលើភាពក្រីក្រ
- ផែនការអភិវឌ្ឍន៍សុខភាពដែលផ្តោតលើភាពក្រីក្រ
- ផែនការដឹកជញ្ជូន និងការលុបបំបាត់ភាពក្រីក្រ
- ឧស្សាហូបនីយកម្ម និងទំនើបកម្ម
- អាទិភាពអន្តរវិស័យ (ដូចជា យេនឌ័រ និងបរិស្ថាន)
- កម្មវិធីជាតិដែលទាក់ទងនឹងភាពក្រីក្រ (ដូចជា ការគ្រប់គ្រងគ្រឿងញៀន និងមេរោគអេដស៍)
- ការអភិវឌ្ឍជនបទដែលនាំមុខដោយសហគមន៍ ស្រុកក្រីក្រ និងការលុបបំបាត់ភាពក្រីក្រ។

រដ្ឋាភិបាលឡាវ បានបង្កើតចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីសម្រេចយុទ្ធសាស្ត្រជាតិលុបបំបាត់ភាពក្រីក្រ ដោយផ្អែកលើប្រធានបទចំនួនប្រាំពីរ។

១. ការកសាងផែនការតាមបែបផែននៃការចូលរួម ដើម្បីធានាថាមានការពិចារណាអំពីតម្រូវការនិងកាលៈទេសៈនៅមូលដ្ឋាន។ ចំណាត់ការនៅថ្នាក់ភូមិ និងស្រុកគឺ ជាកត្តាជម្រុញឱ្យមានកំណើននៃវិស័យកសិកម្ម។
២. កែប្រែតំបន់ទំនាប ដើម្បីជួយពង្រីកការនាំចេញផលិតផល
៣. ការអភិវឌ្ឍដោយចិរភាពនៅតាមជម្រាលភ្នំ ដែលរួមទាំងការគ្រប់គ្រងបរិស្ថាន។
៤. ការធ្វើឱ្យដំណាំពនេចរមានស្ថិរភាព
៥. ការពង្រីកតំបន់ស្រោចស្រព ការកែលម្អលើប្រព័ន្ធដែលបានអនុវត្តរួចមកហើយ ដើម្បីគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធិភាពនិងការផ្តួចផ្តើមគម្រោងថ្មីៗដើម្បីពង្រីកតំបន់ស្រោចស្រព។
៦. ការអភិវឌ្ឍធនធានមនុស្ស ដើម្បីកែលម្អការកសាងផែនការតាមបែបផែននៃការចូលរួម បច្ចេកទេសផ្សព្វផ្សាយ ក៏ដូចជាការស្វែងយល់អំពីប្រព័ន្ធទីផ្សារ និងតួនាទីនៃវិស័យឯកជនផងដែរ។
៧. បរិយាសកាសអំណោយផលសម្រាប់ការអភិវឌ្ឍជំនួញ ដែលជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។

ជារួម គោលបំណងគន្លឹះនានានៃផែនការនេះ គឺបង្កើនការធ្វើសមាហរណកម្មក្នុងចំណោមវិស័យនានា ក៏ដូចជាលើកទឹកចិត្តឱ្យមានការពិចារណាអំពីឥទ្ធិពលចំពោះបរិស្ថានផងដែរ។

ប្រទេសឡាវរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម(NSEDP) រៀងរាល់ប្រាំឆ្នាំម្តង។ ផែនការចុងក្រោយគឺសម្រាប់ឆ្នាំ2006-2010 និងផ្តោតលើការសម្រេចនូវកម្មវិធីអាទិភាពចំនួន 11 ដូចតទៅ:

- កម្មវិធីសន្តិសុខស្បៀង
- កម្មវិធីអភិវឌ្ឍន៍កសិកម្ម
- កម្មវិធីកសិ-ឧស្សាហកម្ម និងការគ្រប់គ្រងព្រៃឈើ
- កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
- កម្មវិធីលើកកំពស់វិស័យទេសចរណ៍ និងទំនាក់ទំនងជាមួយជីធ្លី
- កម្មវិធីលុបបំបាត់ភាពក្រីក្រ
- កិច្ចសហប្រតិបត្តិការអន្តរជាតិ និងកម្មវិធីសមាហរណកម្មតំបន់
- កម្មវិធីទំនាក់ទំនង និងដឹកជញ្ជូន
- កម្មវិធីយន្តការប្រសិទ្ធិភាពសេដ្ឋកិច្ច
- ការអភិវឌ្ឍធនធានមនុស្ស និងកម្មវិធីវប្បធម៌
- កម្មវិធីកែទម្រង់អភិបាលកិច្ច

ផែនការ NSEDP និងNGPEP ប្រាំឆ្នាំ ព្យាយាមកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍប្រទេសឡាវ និងវិភាគទានជាចំបង

ពីវិស័យទឹក ដែលរួមទាំងការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ថាមពលវារីអគ្គិសនី ការអភិវឌ្ឍកសិកម្ម ជលផល ការផ្គត់ផ្គង់ទឹកនៅទីក្រុង និងជនបទ។ បើទោះជាផែនការរយៈពេលប្រាំឆ្នាំ បានចែងខ្លះៗអំពីចំណុចដៅនានា ដែលទាក់ទងនឹងទឹកក៏ដោយ ក៏ផែនការនេះមិនផ្តល់ជាមូលដ្ឋាន ដើម្បីសម្របសម្រួលការកសាងផែនការអំពីធនធានធម្មជាតិនៅថ្នាក់ជាតិ ឬថ្នាក់អាងទន្លេឡើយ។ គេឃើញអវត្តមានដែលគួរឱ្យកត់សំគាល់នូវគោលនយោបាយទឹក ដែលគាំទ្រដោយរដ្ឋាភិបាលនៅក្នុងរបៀបវារៈជាតិ ដែលកំណត់គោលនយោបាយសំរាប់រដ្ឋាភិបាលក្នុងការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹករបស់ខ្លួន។

វិស័យជលផល និងវារីវប្បកម្ម

រដ្ឋាភិបាលនៃប្រទេសឡាវ កំពុងរៀបចំសេចក្តីព្រាងច្បាប់ជលផល នៅឆ្នាំ 2009 ជាពិសេសសម្រាប់វិស័យជលផល និងវារីវប្បកម្ម។ ក្នុងការគាំទ្រដល់ដំណើរការនេះ អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) ក្រោមកិច្ចសហការជាមួយអង្គការបច្ចេកទេសអន្តរជាតិចំនួនបួន បានបង្កើតឱ្យមាន *ការពិនិត្យមើលក្របខ័ណ្ឌច្បាប់ជលផល និងវារីវប្បកម្មនៅក្នុងប្រទេសឡាវ* ដើម្បីផ្តល់ការណែនាំអំពីការកសាងបទប្បញ្ញត្តិពីសំណាក់រដ្ឋាភិបាលឡាវ។

រហូតមកដល់ពេលនេះ ប្រទេសឡាវ នៅពុំទាន់បានអនុម័តច្បាប់ដោយឡែកស្តីពីជលផល និងវារីវប្បកម្មឡើយ ហើយសព្វថ្ងៃនេះ វិស័យនេះស្ថិតនៅក្រោមការចាត់ចែងតាមច្បាប់ព្រៃឈើឆ្នាំ 1996។ មាត្រា នានាដែលទាក់ទងនឹងជលផល អាចឃើញមាននៅក្នុងច្បាប់កសិកម្ម ឆ្នាំ 1998 និងច្បាប់ព្រហ្មទណ្ឌឆ្នាំ 1990 ផងដែរ។

ច្បាប់នេះនឹងក្លាយជា"ច្បាប់គោល"(តែមិនមែនជា"ច្បាប់លំអិតឡើយ") ដើម្បីអនុញ្ញាតឱ្យបត់បែនបាន និងការគ្រប់គ្រងបែបបទរ៉ាំនិងធានាថា វិធានការនានា និងទម្លាប់នៅមូលដ្ឋានត្រូវបានអនុវត្តស្របតាមភាពជាក់ស្តែងនៅក្នុងមូលដ្ឋាន ដែលទំនងជាអាចអនុវត្តបានដោយប្រសិទ្ធិភាពខ្ពស់ (Cacaud and Latdavong, 2008)។ សេចក្តីព្រាងច្បាប់នេះ ចែកជា 10 ផ្នែក 10 ជំពូក និង 72 មាត្រា ហើយក្រោយរដ្ឋសភាអនុម័ត វានឹងក្លាយជាបរិធានច្បាប់ដែលមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងជលផលនៅក្នុងប្រទេសឡាវ (Pongkhao, 2009)។

ច្បាប់ព្រៃឈើត្រូវបានអនុម័តនៅក្នុងឆ្នាំ 1999 និងកំណត់អំពីគោលការណ៍ បទបញ្ជា និងវិធានការនានាជាមូលដ្ឋាន ដែលទាក់ទងនឹងរដ្ឋបាល ការថែទាំ ការប្រើប្រាស់ធនធានព្រៃឈើ និងដីព្រៃ ការជម្រុញឱ្យមានការស្តារឡើងវិញ ការដាំ និងការសាយភាយធនធានព្រៃឈើនៅក្នុងប្រទេសឡាវ។ ច្បាប់នេះទទួលស្គាល់អំពីសារៈសំខាន់នៃព្រៃឈើសម្រាប់ការពារធនធានទឹក។ ច្បាប់នេះចែងយ៉ាងច្បាស់ថា ក្រសួងកសិកម្ម និងព្រៃឈើ មានភារៈកិច្ចទទួលខុសត្រូវលើរដ្ឋបាលធនធានព្រៃឈើ ក៏ដូចជាដីព្រៃផងដែរ។ ជាមួយការកំណត់ភារៈកិច្ចបែបនេះ ក្រសួងកសិកម្ម និងព្រៃឈើ អាចដើរតួនាទីយ៉ាងសំខាន់លើអភិបាលកិច្ចធនធានទឹក និងទំហំដែនសមត្ថកិច្ចលើការគ្រប់គ្រងធនធានទឹក រវាងច្បាប់ស្តីពីទឹក និងធនធានទឹក និងច្បាប់ស្តីពីព្រៃឈើ ដើម្បីជៀសវាងភាពត្រួតគ្នា និងភាពច្របូកច្របល់រវាងបញ្ហាទឹក និងព្រៃឈើ។

ច្បាប់ការពារបរិស្ថានត្រូវបានអនុម័តនៅឆ្នាំ 1999 ហើយដូចជាច្បាប់ផ្សេងៗទៀតដែរ ច្បាប់ការពារបរិស្ថានចែងអំពីគោលការណ៍ជាមូលដ្ឋាន បទបញ្ជា និងបទប្បញ្ញត្តិនានាលើកិច្ចការពារបរិស្ថាន។ ទឹកត្រូវបានគេទទួលស្គាល់ថាជាផ្នែកដ៏សំខាន់មួយនៃបរិស្ថាន។ ច្បាប់នេះចែងថា ផែនការជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមត្រូវតែមានផ្សំដោយផែនការការពារបរិស្ថាន។ ច្បាប់នេះផ្តល់អំណាចដល់ទីភ្នាក់ងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន ដើម្បីត្រួតពិនិត្យមើលការគ្រប់គ្រង និងការតាមដានបរិស្ថាន ហើយអភិបាលកិច្ចធនធានទឹកក៏ជាផ្នែកមួយនៅក្រោមច្បាប់នេះផងដែរ។

វិស័យវារីអគ្គិសនី និងថាមពល

រដ្ឋាភិបាលឡាវទទួលស្គាល់ថា ការអភិវឌ្ឍវារីអគ្គិសនីត្រូវតែមាននិរន្តរភាព ប្រសិនបើចង់ធានាថា សក្តានុពលនៃការអភិវឌ្ឍវិស័យនេះអាចផ្តល់ផលប្រយោជន៍បានពេញលេញ និងយូរអង្វែងសម្រាប់ប្រទេសឡាវ។ គោលនយោបាយជាតិស្តីពីបរិស្ថាន និងនិរន្តរភាពសង្គមនៃវិស័យវារីអគ្គិសនីឆ្នាំ 2007 បានចែងអះអាងអំពីការដាក់បញ្ចូលគោលការណ៍នានាអំពីនិរន្តរភាពសង្គម និងអេកូឡូស៊ីទៅក្នុងការអភិវឌ្ឍវារីអគ្គិសនីធំៗទាំងអស់និងត្រូវផ្អែកលើគោលការណ៍ចំនួនបីដូចតទៅ :

- សេដ្ឋកិច្ចអាចមាននិរន្តរភាពបាន គឺអាស្រ័យលើការថែរក្សា

មូលដ្ឋានធនធានកកើតឡើងវិញ និងការប្រើប្រាស់ធនធានមិនកកើតឡើងវិញដើម្បីគាំទ្រកត្តាផ្សេងទៀតនៅក្នុងផលិតកម្ម

- និរន្តរភាពសង្គម គឺជាមូលដ្ឋានសម្រាប់គោលការណ៍នានានៃភាពពេញលេញ ការយោគយល់ និងការឯកភាពមតិ និង
- និរន្តរភាពអេកូឡូស៊ី ពឹងផ្អែកលើការជៀសវាងផលប៉ះពាល់មកលើបរិស្ថានដែលមិនអាចជួសជុលបាន ដូចជា ការបាត់បង់ជីវៈចម្រុះ ការប្រមូលផ្តុំសារធាតុបំពុលមិនងាយបែកធាតុ ឬការរំខានចំពោះវដ្តនៃអេកូឡូស៊ី។

គោលនយោបាយនេះអនុវត្តចំពោះទំនប់វារីអគ្គិសនីខ្នាតធំដែលបានសាងសង់នៅក្រោយឆ្នាំ 1990 ដោយចាត់ទុកថា ទំនប់ខ្នាតធំត្រូវមានសមត្ថភាពខ្ពស់ជាង 50 មេហ្គាវ៉ាត់ ឬជន់លិចលើផ្ទៃដីធំជាង 10,000 ហិកតា នៅពេលតំកល់ទឹកក្នុងកម្រិតអតិបរមា។ គោលនយោបាយនេះទាមទារឱ្យរាល់គម្រោងវារីអគ្គិសនីខ្នាតធំនានាដាក់ជូន សម្រាប់ការពិនិត្យនូវរបាយការណ៍ EIA ពេញលេញ និងផែនការគ្រប់គ្រងបរិស្ថាន (EMP) អនុលោមតាមច្បាប់ការពារបរិស្ថានឆ្នាំ 1999 និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ គោលនយោបាយនេះ រួមមានមាត្រានានាដែលទាក់ទងនឹងសហគមន៍ជនរងគ្រោះ ការគ្រប់គ្រងទីជម្រាល និងការអភិរក្ស ការពិគ្រោះយោបល់ ការបើកចំហព័ត៌មាន ការគោរពតាម ផលចំណូល គម្រោងវារីអគ្គិសនីដែលមានស្រាប់ ការចាត់ចែងស្ថាប័ន និងការធ្វើសេចក្តីរាយការណ៍។

ច្បាប់ស្តីពីអគ្គិសនី ត្រូវបានអនុម័តនៅក្នុងឆ្នាំ 1997 និងចែងអំពីការចាត់ចែងគ្រប់គ្រង ការផលិត ការបញ្ជូន និងចែកចាយអគ្គិសនី។ ច្បាប់នេះក៏ចែងផងដែរអំពីវិសាលភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ដែលរួមទាំងធនធានទឹកផង សម្រាប់ផលិតអគ្គិសនីដែលអាចផ្តល់ផលខ្ពស់។

ច្បាប់ស្តីពីអគ្គិសនីបានផ្តល់អំណាចដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្មដើម្បីត្រួតមើលការអភិវឌ្ឍអគ្គិសនី និងកិច្ចការពារបរិស្ថាននៅក្នុងវិស័យនេះ ហើយប្រការនេះនឹងនាំឱ្យវិស័យអគ្គិសនីមានអំណាចគ្របដណ្តប់លើការគ្រប់គ្រងធនធានទឹក។

វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ

សេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រីស្តីពីការគ្រប់គ្រង និងអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកឆ្នាំ 1999ចែងអំពីគោលនយោបាយរបស់រដ្ឋាភិបាលឡាវ ក្នុងការគ្រប់គ្រងវិស័យទឹក។ ច្បាប់នេះចែងអំពីមុខនាទីជាច្រើនសម្រាប់វិស័យនេះ ដែលរួមទាំង បែងចែកទទួលខុសត្រូវលើការងាររដ្ឋបាលវិស័យនេះ ការបង្កើតក្រុមប្រឹក្សានិយ័តកម្មនៃអាជ្ញាធរផ្គត់ផ្គង់ទឹក ការផ្តល់ហិរញ្ញប្បទានសម្រាប់ប្រតិបត្តិការក្នុងវិស័យនេះ និងការបំពេញថ្លៃចំណាយ និងលក្ខខណ្ឌប្រតិបត្តិការនៃក្រុមហ៊ុនផ្គត់ផ្គង់។

៣.២.២ ការចាត់ចែងស្ថាប័ននៅក្នុងវិស័យសំខាន់ៗ

កម្មវិធីជាតិគាំទ្រ IWRM (N-IWRM-SP)

កម្មវិធីជាតិគាំទ្រ IWRM (N-IWRM-P) គឺជាក្របខ័ណ្ឌមួយដែលមាន 10 ផ្នែក ដើម្បីធ្វើឱ្យដៃគូរអភិវឌ្ឍន៍ និងរដ្ឋាភិបាលសំរបសម្រួល និងគាំទ្រ IWRM នៅក្នុងប្រទេសឡាវ។ ផ្នែក 1-10 នឹងត្រូវអនុវត្តនៅក្នុងរដ្ឋបាលធនធានទឹក និងបរិស្ថាន (WREA) និងទីភ្នាក់ងារដទៃទៀត នៅក្រោមការណែនាំរបស់ការិយាល័យសម្របសម្រួល និងគ្រប់គ្រងកម្មវិធី WREA ដែលមានកាតព្វកិច្ចធ្វើសេចក្តីរាយការណ៍ទៅគណៈកម្មាធិការដឹកនាំ N-IWRM-SP។ គណៈកម្មាធិការដឹកនាំនេះ ក៏នឹងមានទំនាក់ទំនងជាមួយក្រុមសម្របសម្រួលម្ចាស់ជំនួយ និងគណៈកម្មាធិការជាតិទន្លេមេគង្គឡាវ LNMC ផងដែរ។

រដ្ឋបាលធនធានទឹក និងបរិស្ថាន

WREA មានឋានានុក្រមស្មើនឹងក្រសួង និងជាទីភ្នាក់ងារមួយដែលស្ថិតនៅចំណុះការិយាល័យនាយករដ្ឋមន្ត្រី។ ការទទួលខុសត្រូវរបស់រដ្ឋបាលនេះ រួមមាន :

- បកស្រាយ និងអនុវត្តគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ បទបញ្ជា និងបទប្បញ្ញត្តិនានា ដែលចេញដោយភាគីនេះ និងរដ្ឋាភិបាល ដែលទាក់ទងនឹងធនធានទឹក បរិស្ថាន ឧតុនិយម និងជលសាស្ត្រ
- ធ្វើសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការរយៈពេលវែង ច្បាប់ និងក្រឹត្យនានា ដែលទាក់ទងនឹងធនធានទឹក បរិស្ថាន ឧតុនិយម និងជលសាស្ត្រ។ ផ្តល់ការណែនាំអំពីការអនុវត្តបទប្បញ្ញត្តិនានាដែលគាំទ្រដោយរដ្ឋាភិបាល
- លើកស្នើ កែប្រែ និងកែលម្អបទបញ្ជា និងបទប្បញ្ញត្តិ ដែលទាក់

ទងនឹងធនធានទឹក បរិស្ថាន និងជលសាស្ត្រ ប្រសិនបើវាមានសង្គត់ភាពជាមួយលក្ខខណ្ឌនៅក្នុងប្រទេសឡាវ

- កសាងផែនការ ដើម្បីគ្រប់គ្រង អភិរក្ស និងស្តារធនធានទឹក និងបរិស្ថានប្រកបដោយនិរន្តរភាព និងដាក់ជូនទៅរដ្ឋាភិបាលដើម្បីសុំការអនុម័តគាំទ្រ ក្នុងគោលបំណងលើកកំពស់ការអប់រំ ការស្រាវជ្រាវវិទ្យាសាស្ត្រនិងបង្កើនការយល់ដឹងជាសាធារណៈ អំពីការអភិរក្សធនធានទឹកនិងបរិស្ថាន។ មុននឹងអនុម័តឯកភាពលើគម្រោងណាមួយ ទីភ្នាក់ងារធនធានទឹក និងបរិស្ថានត្រូវសម្របសម្រួលជាមួយទីភ្នាក់ងារពាក់ព័ន្ធដើម្បីធានាឱ្យមានតុល្យភាពរវាងសំណើគម្រោងអភិវឌ្ឍន៍ និងអភិរក្សធនធានទឹក និងបរិស្ថាន និង
- គ្រប់គ្រង តាមដាន ធ្វើសារពើភ័ណ្ឌ និងចែករំលែកទិន្នន័យ និងព័ត៌មានដែលទាក់ទងនឹងធនធានទឹក បរិស្ថាន ឧតុនិយម និងជលសាស្ត្រនៅទូទាំងប្រទេស។

ក្នុងរដ្ឋបាលនេះមាននាយកដ្ឋានចំនួនប្រាំមួយដូចខាងក្រោម :

- ការិយាល័យ WREA
- នាយកដ្ឋានធនធានទឹក
- នាយកដ្ឋានឧតុនិយម និងជលសាស្ត្រ
- នាយកដ្ឋានបរិស្ថាន
- វិទ្យាស្ថានស្រាវជ្រាវធនធានទឹក និងបរិស្ថាន
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិទន្លេមេគង្គឡាវ។

រដ្ឋបាលនេះ ក៏មានអំណាចដើម្បីបង្កើតការិយាល័យផ្ទាល់ខ្លួននៅថ្នាក់ខេត្ត និងស្រុកផងដែរ។

ការបង្កើត WREA អាចមើលឃើញថាជាកិច្ចប្រឹងប្រែងចំបងមួយរបស់រដ្ឋាភិបាលឡាវ ក្នុងការសម្រួលដល់ការគ្រប់គ្រងទឹកនៅថ្នាក់ជាតិដែលនៅដាច់ពីគ្នា ដោយបង្រួបបង្រួមទីភ្នាក់ងារធនធានទឹក ទៅក្នុងរដ្ឋបាលតែមួយ។ នាយកដ្ឋានធនធានទឹក ត្រូវបានគេរំពឹងថា មានតួនាទីត្រួតពិនិត្យការគ្រប់គ្រងទឹកនៅទូទាំងប្រទេស និងអនុវត្តគោលការណ៍នានានៃ IWRM ទៅក្នុងគោលនយោបាយវិស័យទឹក។

៣.៣ ស្ថានភាពនៅចំពោះមុខច្បាប់នៃវិស័យនានា

ទឹកគឺជាធាតុដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនេះ និងពាក់ព័ន្ធជាមួយវិស័យខុសៗគ្នាជាច្រើន ដែលពឹងផ្អែកលើការប្រើប្រាស់ទឹក និងធនធានដែលពាក់ព័ន្ធនឹងទឹក រួមទាំងកសិកម្មនិងព្រៃឈើ ជលផល វារីអគ្គិសនី និងថាមពល នាវាចរណ៍ និងទេសចរណ៍ និងការផ្គត់ផ្គង់ទឹក និងអនាម័យ។

៣.៣.១ វិស័យធារាសាស្ត្រ

កសិកម្មគឺជាវិស័យសំខាន់បំផុតមួយនៅក្នុងសេដ្ឋកិច្ចនៃប្រទេសឡាវ ដែលរួមចំណែកដល់ 53%នៃ GDP និងផ្តល់ជាផលចំណូលប្រមាណ 83% នៃគ្រួសារដែលមានប្រាក់ចំណូលទាំងអស់។ នៅជនបទ ការដាំដំណាំ គឺជាសកម្មភាពចំបងរបស់ជិត 91% នៃបុរសដែលមានប្រាក់ចំណូល និងច្រើនជាង 94% នៃស្ត្រីដែលមានប្រាក់ចំណូល ដោយមានភាពខុសគ្នាតិចតួចរវាងតំបន់នានា។ ប្រមាណ 5 លានហិកតានៃផ្ទៃដីសរុប 23,68 លានហិកតានៅក្នុងប្រទេសឡាវមានលក្ខណៈសមស្របសម្រាប់ធ្វើកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ មានតែ 17% នៃផ្ទៃដីសមស្រប ដែលតិចជាង 4% នៃផ្ទៃដីសរុបនៃប្រទេសនេះ (រវាង 850,000 និង 900,000 ហិកតា) ដែលបានប្រើប្រាស់សម្រាប់ការដាំដំណាំពិតប្រាកដ។

តាមរយៈកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ផ្ទៃដីស្រោចស្រពត្រូវបានពង្រីកយ៉ាងច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ឆ្នាំ	រដូវវស្សា (ហិកតា)	រដូវប្រាំង (ហិកតា)
1995	150.000	26.000
1996	156.000	28.000
1997	164.000	45.000
1998	216.890	75.000
1999	258.200	124.234
2000	295.535	197.131
2001	300.054	214.131
2002	307.097	214.625
2003	310.171	214.832

តារាងទី ៣.ផ្ទៃដីស្រោចស្រពរវាងឆ្នាំ 1991 –2003, ប្រទេសឡាវ (Source: MRCS, 2004)

បើទោះជាផ្ទៃដីកសិកម្មដែលមានប្រព័ន្ធស្រោចស្រព ត្រូវបានពង្រីកយ៉ាងច្រើន ហើយការអភិវឌ្ឍកសិកម្មស្រោចស្រពត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកម្មវិធីជាតិលុបបំបាត់ភាពក្រីក្រនៅក្នុងឆ្នាំ 2003 (Government of Lao, 2004) ក៏ដោយ គេបានកត់សំគាល់ថា ប្រព័ន្ធស្រោចស្រពខ្លះត្រូវបានទុកចោលក្នុងស្ថានភាពមិនល្អ។ ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពភាគច្រើនធ្វើឡើងតាមរយៈការគាំទ្រមូលនិធិពីប្រាក់កំចី និងជំនួយឥតសំណង ទោះជាយ៉ាងណាក៏ដោយ ក្រោយពេលបានផ្តួចផ្តើមឡើងហើយ គេពុំបានបែកចែកថវិកាសម្រាប់ប្រតិបត្តិការ និងការថែទាំប្រព័ន្ធទាំងនេះឡើយ។ លើសពីនេះ ប្រតិបត្តិការប្រព័ន្ធស្រោចស្រពដោយម៉ាស៊ីនបូមទឹកត្រូវចំណាយខ្ពស់ និងទាមទារឱ្យមានការចំណាយដើមទុនជាក់លាក់ដែល ភាគច្រើនបានទទួលការគាំទ្រហិរញ្ញវត្ថុពីអ្នកប្រើប្រាស់ និងមួយផ្នែកបានពីការគាំទ្ររបស់រដ្ឋាភិបាលនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។ ក្នុងករណីដែលកសិករមិនអាចបង់ថ្លៃអគ្គិសនីបាន ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពត្រូវបានកាត់បន្ថយ។ ដោយទទួលស្គាល់ពីបញ្ហានេះ រដ្ឋាភិបាលបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់លើការស្តារ និងពង្រីកប្រព័ន្ធស្រោចស្រព និងថែងអំពីប្រព័ន្ធស្រោចស្រពខ្នាតតូចសម្រាប់តំបន់ដាច់ស្រយាល នៅក្នុងផែនការជាតិសេដ្ឋកិច្ចសង្គម ឆ្នាំ 2006-2010។

ដូច្នេះ របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យស្រោចស្រពគួរតែផ្តោតលើ :

- ពង្រឹងការចូលរួមរបស់កសិករលើវិធាននៃការកសាងផែនការដែលផ្អែកលើតម្រូវការនៅមូលដ្ឋាននៅក្នុងការអភិវឌ្ឍប្រព័ន្ធស្រោចស្រព និង
- ការបង្កើតយន្តការនានា ដើម្បីបង្កើតផលចំណូលដោយនិរន្តរភាពសម្រាប់ប្រតិបត្តិការ និងការថែទាំ។

៣.៣.២ ជលផល

ជលផល គឺជាផ្នែកសំខាន់មួយនៃវចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមរបស់ប្រទេសឡាវ និងប្រទេសផ្សេងទៀតនៅក្នុងអាងទន្លេមេគង្គក្រោម។ ត្រីត្រូវបានចាត់ទុកថាជាមុខម្ហូបចំបងមួយសំរាប់ប្រជាជននៅក្នុងប្រទេសឡាវ ជាពិសេសសម្រាប់ជនក្រីក្រ។ វារួមចំណែក 42% នៃប្រូតេអ៊ីនពីសាច់សត្វដែលបានបរិភោគ និងរួមចំណែក 7 ទៅ 8% នៃ GDP របស់ប្រទេសឡាវ (MRC, 2004)។ គោលនយោបាយថ្មីៗរបស់រដ្ឋាភិបាល បានព្យាយាមលើកទឹកចិត្តដល់វិស័យនេះ ដើម្បីគាំទ្រដល់ការលុបបំបាត់ភាពក្រីក្រនៅក្នុងទីជនបទក៏ដូចជា ដើម្បីផ្តល់ជាប្រភពអាហារបន្ថែមសម្រាប់អ្នកទីក្រុងផងដែរ។ បញ្ហានៃការនេសាទច្រើនហួសកម្រិត ការរេចរឹលទីជម្រកសម្រាប់ត្រី និងផលប៉ះពាល់នៃវារីអគ្គិសនីមកលើត្រី គឺជាកង្វល់ចំបងមួយ។

របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅក្នុងវិស័យជលផលគួររួមបញ្ចូល :

- អនុម័តសេចក្តីព្រាងច្បាប់ជលផលដែលទទួលស្គាល់អំពីការចាត់ចែងគ្រប់គ្រងជលផលដោយផ្អែកលើសហគមន៍/សហគ្រប់គ្រង និង
- បង្កើតយន្តការនានាដើម្បីអនុញ្ញាតឱ្យសហគមន៍អ្នកនេសាទដែលរងគ្រោះចូលរួមដោយប្រសិទ្ធិភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹក។

៣.៣.៣ វិស័យវារីអគ្គិសនី និងថាមពល

តាមទ្រឹស្តី សក្តានុពលវារីអគ្គិសនី មានប្រមាណ 26.500MW ដោយមិនរាប់បញ្ចូលដងទន្លេមេគង្គ។ ក្នុងតួលេខនេះ ប្រមាណ 18.000MW អាចធ្វើអាជីវកម្មបាន ដោយ 12.500MW មាននៅក្នុងអនុតំបន់អាងទន្លេមេគង្គ ក្រៅពីនេះសក្តានុពលបែបនេះមាននៅក្នុងអាងតូចៗនៃទន្លេមេគង្គ និងអាងក្រៅទន្លេមេគង្គ (MRC, 2004)។ ទោះជាយ៉ាងណាក៏ដោយ តិចជាង 2% នៃសក្តានុពលវារីអគ្គិសនីក្នុងប្រទេសនេះ ត្រូវបានអភិវឌ្ឍន៍នៅក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ។សព្វថ្ងៃនេះសមាមាត្រនៃផលិតកម្មអគ្គិសនីដែលនៅសល់ពីការនាំចេញទៅប្រទេសថៃមិនគ្រប់គ្រាន់សម្រាប់បំពេញ តម្រូវការជាក់ស្តែងនៅក្នុងប្រទេសនេះឡើយ។ មានតែ 58.3% នៃ គ្រួសារទាំងអស់មានលទ្ធភាពប្រើប្រាស់អគ្គិសនី និងការប្រើប្រាស់ ក្នុងស្រុកកំពុងកើនឡើងតាមអត្រា 8 ទៅ 10% ក្នុងមួយឆ្នាំ។

រដ្ឋាភិបាល កំពុងជម្រុញយ៉ាងខ្លាំងក្លានូវការវិនិយោគក្នុងវិស័យនេះ។ ចំនួនការរកស៊ីរួមគ្នា និងគម្រោងថាមពលឯករាជ្យ ត្រូវបាន

រំពឹងថានឹងកើនឡើងនៅក្នុងអនាគតខ្លីខាងមុខនេះ ។ រដ្ឋាភិបាលកំពុងកសាងផែនការដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីចំនួន 42 សម្រាប់បំពេញតម្រូវការក្នុងស្រុក និងគម្រោងចំនួន 31 នៅក្នុងទីជម្រាលសំខាន់ៗនៃប្រទេសនេះ សម្រាប់នាំចេញអគ្គិសនី ដូចជា ទំនប់ ណាំងុម ណាំអ៊ូ សេបាំងហ្វៃ សេកុង និងដងទន្លេមេគង្គ ។ បញ្ហានានានៃការធ្វើចរាចររបស់ត្រី ការគ្រប់គ្រងទីជម្រាល ការប្រែប្រួលលំហូរតាមធម្មជាតិ និងគុណភាពទឹក ការតាំងទីលំនៅរបស់មនុស្ស និងការអភិវឌ្ឍជនបទ មានសារៈសំខាន់ខ្លាំងណាស់ ។

ដូច្នេះ របៀបវារៈនេះ សម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យវារីអគ្គិសនី គួរតែផ្តោតលើ :

- កែលម្អកិច្ចសហប្រតិបត្តិការលើវិធានកសាងផែនការដែលផ្អែកលើ IWRM នៅទូទាំងអាងទន្លេ រវាងក្រសួងថាមពលនិងរ៉ែ (MEM) និង WREA
- ការចាត់ចែងស្ថាប័នសម្រាប់អនុវត្តវិធាន SEA នៅក្នុង MEM/ WREA
- ការពង្រឹងដំណើរការសម្រាប់ពិនិត្យលើសំណើនានា និងកិច្ចសន្យាផ្តល់សម្បទាន ក៏ដូចជា ការគ្រប់គ្រង និងការតាមដានសម្បទាននានា នៅក្នុងនាយកដ្ឋានអភិវឌ្ឍន៍និងបង្កើនថាមពល (DEDP)/ MEM,
- ការពង្រឹងសមត្ថភាព និងប្រសិទ្ធិភាពនៃការិយាល័យ WREA EIA សម្រាប់ពិនិត្យគម្រោងជាច្រើននៅក្នុងរយៈពេល5ឆ្នាំខាងមុខ ។
- ការធានាឱ្យអនុវត្តគោលនយោបាយជាតិស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមនៃវិស័យវារីអគ្គិសនីនៅក្នុងប្រទេសឡាវ ជាពិសេសមាត្រានានា ដែលទាក់ទងនឹងការបើកចំហព័ត៌មាន និងការពិគ្រោះយោបល់ ។

៣.៣.៤ ទេសចរណ៍ និងនាវាចរណ៍

នៅក្នុងទសវត្សរ៍កន្លងទៅ វិស័យទេសចរណ៍នៃប្រទេសឡាវ មានកំណើនគួរឱ្យកត់សំគាល់ ។ រវាងឆ្នាំ 2006 និង 2007 ចំនួនភ្ញៀវទេសចរបានកើនឡើង 34% ហើយវិស័យនេះបានរួមចំណែកប្រមាណ 8% នៃ GDP ។ បើទោះជាលំបាកក្នុងការគណនា ផលចំណូលពីសកម្មភាពទេសចរណ៍ដែលទាក់ទងនឹងទឹកក៏ដោយ កំណើនការយកចិត្តទុកដាក់ទៅលើសកម្មភាពទេសចរណ៍ដែលផ្អែកលើ ធនធានធម្មជាតិអាចជាប្រការសមស្រប ។ តាំងពីឆ្នាំ 1993មក រដ្ឋាភិបាលឡាវបានធ្វើអត្តសញ្ញាណ និងកំណត់ទីតាំងចំនួន 20 កន្លែង សម្រាប់ជាតំបន់ការពារធម្មជាតិរបស់ជាតិ (UN, 1999) ហើយរហូតដល់ឆ្នាំ 2007 អាជ្ញាធរជាតិទេសចរណ៍នៃប្រទេសឡាវបានធ្វើអត្តសញ្ញាណ ទីតាំងអេកូទេសចរណ៍ចំនួន 849 កន្លែង ។ គម្រោងអេកូទេសចរណ៍ ណាមហា ជាញឹកញាប់ត្រូវបានគេគូសបញ្ជាក់ថា ជាឧទាហរណ៍នៃគម្រោងអេកូទេសចរណ៍មួយ ដែលជួយក្នុងការអភិរក្សទីជម្រាល ណាមហា និងការអភិវឌ្ឍជនបទតាមរយៈការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។ នៅខែកក្កដា ឆ្នាំ 2009 ប្រទេសឡាវ បានធ្វើជាម្ចាស់ផ្ទះសម្រាប់សន្និសីទអេកូទេសចរណ៍ពិភពលោក ។

ទន្លេមេគង្គ និងដៃនានានៃទន្លេនេះ បង្កើតជាបណ្តាញដឹកជញ្ជូននៅទូទាំងប្រទេសឡាវ និងផ្តល់នូវមធ្យោបាយដ៏ងាយស្រួលសម្រាប់ការដឹកជញ្ជូនទំនិញ ផលិតផល និងប្រជាពលរដ្ឋ ។ ទោះជាយ៉ាងណាក៏ដោយ នាវាចរណ៍នៅក្នុងដៃទន្លេមេគង្គអាចមិនប្រព្រឹត្តទៅដោយងាយស្រួលឡើយ ហើយបរិមាណទំនិញដែលដឹកជញ្ជូនមានភាពខុសគ្នារវាងត្រឹមតែ 0,5 និង 3,5 តោន/ទូក ។ បើប្រៀបធៀបនាវាដឹកជញ្ជូននៅក្នុងដងទន្លេមេគង្គ អាចមានចំណុះប្រែប្រួលក្នុងរវាង 60 និង 200 តោន (MRC, 2004) ។ ការដឹកជញ្ជូនពីទន្លេមេគង្គក្នុងប្រទេសឡាវទៅសមុទ្រ ត្រូវរារាំងដោយល្បាក់ខោន ដែលមិនអាចឆ្លងកាត់បាន ហើយការធ្វើនាវាចរណ៍នៅក្នុងរដូវប្រាំងមិនអាចធ្វើបានឡើយ នៅក្នុងផ្នែកជាច្រើននៃប្រទេសនេះ ។ ទោះជាយ៉ាងណាក៏ដោយ ការដឹកជញ្ជូនតាមទន្លេមានភាពទាក់ទាញនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ហើយកម្មវិធីកែលម្អនាវាចរណ៍ដែលគាំទ្រដោយប្រទេសចិនបាននាំឱ្យមានកំណែលម្អនាវាចរតាមទន្លេមេគង្គក្នុងភាគខាងជើងនៃប្រទេសនេះ ។ ការប្រើប្រាស់គ្រឿងផ្ទុះដើម្បីបំបែកថ្ម និងរបាំងទឹកជ្រូរ បាននាំឱ្យមានផលវិបាកអវិជ្ជមានខាងបរិស្ថាន ដែលធ្វើឱ្យប្រែប្រួលរូបសណ្ឋាននៃទន្លេ និងកាត់បន្ថយទីជម្រកសម្រាប់ពងកូន និងកន្លែងជ្រកពួនសំខាន់ៗសម្រាប់ត្រី ។

ដូច្នេះ របៀបវារៈសំខាន់ៗសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យទេសចរណ៍ និងនាវាចរណ៍គួរតែរាប់បញ្ចូល :

- ការពង្រឹងស្ថាប័នដែលផ្អែកលើសហគមន៍មូលដ្ឋានសម្រាប់គ្រប់គ្រងទេសចរណ៍ និងកែលម្អអំណាចចរចារបស់ពួកគេ ជាមួយប្រតិបត្តិការទេសចរណ៍ជាលក្ខណៈពាណិជ្ជកម្ម
- ការបង្កើតយន្តការច្បាស់លាស់សម្រាប់ការចែកផល និងប្រព័ន្ធចេញវិញ្ញាបនប័ត្រ និង
- ការបង្កើតយន្តការនានាសម្រាប់ការពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះ នៅក្នុងប្រព័ន្ធសម្រាប់កែលម្អនាវាចរណ៍។

៣.៣.៥ ការផ្គត់ផ្គង់ទឹក និងអនាម័យ

ប្រភពចំបងនៃការផ្គត់ផ្គង់ទឹកនៅទីក្រុងក្នុងប្រទេសឡាវគឺទន្លេមេគង្គ និងដៃនៃទន្លេនេះ ដែលមានច្រើនជាង 80% នៃទឹកដែលផ្គត់ផ្គង់សរុបចំណែកបរិមាណក្រៅពីនេះមានប្រភពមកពី ទឹកក្រោមដី ទឹកជ្រោះ និងស្ទឹងតូចៗផងដែរ។ បើទោះជាគេអាចសំអាត និងផលិតទឹកប្រមាណ 193,488 ម៉ែត្រគូប នៃទឹកហូបជារៀងរាល់ថ្ងៃក៏ដោយ ផលិតផលជាក់ស្តែងប្រចាំថ្ងៃមានត្រឹមតែ 157,340 ម៉ែត្រ គូបប៉ុណ្ណោះ ដែលផ្គត់ផ្គង់ដល់ប្រមាណ 50% នៃប្រជាជននៅទីក្រុង។ សិទ្ធិទទួលបានសេវាអនាម័យមានភាពខុសគ្នា។ ទោះបីនៅ ក្នុងរដ្ឋធានីវៀងច័ន្ទ ប្រជាជនប្រមាណ 75% នៃប្រជាជនសរុបបានទទួលសេវាអនាម័យក៏ដោយ មានតែប្រជាជន 13% ប៉ុណ្ណោះដែល បានទទួលសេវាអនាម័យនៅក្នុងខេត្តផុងសាលី។

រដ្ឋាភិបាលមានគោលដៅផ្តល់ឱ្យ 80%នៃប្រជាជននៅទីក្រុងនូវសេវាកម្មទឹក និងអនាម័យរហូតដល់ឆ្នាំ 2020 (WASA, 2004)។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋាភិបាលបានស្វែងរកជំនួយហិរញ្ញវត្ថុដែលរួមទាំងការចូលរួមនៃវិស័យឯកជនផងដែរ។ រដ្ឋាភិបាលកំពុងលើកកំពស់គោលការណ៍សាងសង់ធ្វើជាម្ចាស់ដាក់ឱ្យប្រតិបត្តិការនូវប្រព័ន្ធផ្គត់ផ្គង់ទឹកខ្នាតតូច។ ឧទាហរណ៍ចំនួនពីរនៃការផ្តល់កិច្ចសន្យាបាននឹងកំពុងប្រតិបត្តិការចាប់តាំងពីខែ មេសា ឆ្នាំ 2006 មក (WB, 2008)។

របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច ក្នុងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ គួររាប់បញ្ចូល :

- ការបង្កើត WSUGs
- ការបង្កើតយន្តការ ដំណើរការ និងការលើកទឹកចិត្តច្បាស់លាស់សម្រាប់បង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនានា ជាពិសេសក្រុមប្រជាជនក្រីក្របំផុត និង
- ការបង្កើតឱកាសសម្រាប់បង្កើនការចូលរួមនៃវិស័យឯកជន។

៣.៤ សេចក្តីសន្និដ្ឋាន ឧបសគ្គ និងអនុសាសន៍

សព្វថ្ងៃនេះ ប្រទេសឡាវស្ថិតនៅក្នុងក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនៅក្នុងពិភពលោក ប៉ុន្តែត្រូវបានគេមើលឃើញថា មានអនាគតល្អ ដោយសារវត្តមានធនធានធម្មជាតិជាច្រើន ដែលរួមទាំងធនធានទឹក និងការប្តេជ្ញាខ្ពស់ខាងគោលនយោបាយ និងកំណែទម្រង់សេដ្ឋកិច្ច។ ដោយពិចារណាអំពីសារៈសំខាន់នៃវិស័យកសិកម្ម និងភាពប្រកួតប្រជែងខាងវារីអគ្គិសនីនៅក្នុងតំបន់នេះ ប្រភពទឹកមានសារៈសំខាន់ណាស់សម្រាប់យុទ្ធសាស្រ្តអភិវឌ្ឍន៍នៃប្រទេសឡាវ។

៣.៤.១ ឧបសគ្គ

មានបញ្ហាគន្លឹះមួយចំនួនដែលសព្វថ្ងៃនេះកើតមាននៅក្នុងប្រទេសឡាវ ដែលបង្កជាឧបសគ្គចំពោះការអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវការគ្រប់គ្រង និងអភិបាលកិច្ចបានល្អលើផ្នែកទឹក។ ឧបសគ្គទាំងនោះរួមមាន :

- បើទោះជាមាន WREA ហើយក៏ដោយ ការគ្រប់គ្រងនិងកសាងផែនការធនធានទឹក ស្ថិតនៅដាច់តែឯង និងមិនបានធ្វើសមាហរណកម្មឡើយ
- ពុំមានការអនុម័តគោលនយោបាយ និងយុទ្ធសាស្រ្តសម្រាប់ទឹកឡើយនៅថ្នាក់ជាតិ
- មានសង្កត់ភាពតិចតួច ក្នុងការបម្លែងគោលនយោបាយទឹកឱ្យទៅជាច្បាប់
- គ្មានការកំណត់បានច្បាស់លាស់អំពីការទទួលខុសត្រូវសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ឡើយ
- ភាពត្រួតគ្នាខាងស្ថាប័នក្នុងការអភិវឌ្ឍ និងគ្រប់គ្រងទឹក
- ក្របខ័ណ្ឌបទប្បញ្ញត្តិ និងច្បាប់នៅពុំទាន់ឆ្លុះបញ្ចាំងនៅក្នុងការកែប្រែខាងស្ថាប័ននៅឡើយទេ
- ខ្វះយន្តការដើម្បីលើកកំពស់ការចូលរួមពីវិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងសកម្មភាពអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក
- ភាពច្របូកច្របល់នៃគោលនយោបាយ/ក្របខ័ណ្ឌយុទ្ធសាស្រ្ត

ស្តីពីទឹក

- សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកប្រើប្រាស់ ក៏ដូចជា របស់អ្នកផ្គត់ផ្គង់ទឹក នៅពុំទាន់បានចែងនៅឡើយទេ
- ពុំមានចែងក្នុងច្បាប់ អំពីការដាក់ទណ្ឌកម្មឡើយ
- ពុំទាន់ទទួលស្គាល់បានសមស្របអំពីគោលការណ៍IWRMឡើយ
- គ្មានកម្មវិធីអប់រំអំពីការទទួលខុសត្រូវរបស់សហគមន៍លើការគ្រប់គ្រងធនធានទឹកឡើយ ។

បើទោះជាប្រទេសឡាវ បានផ្តោតការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ខ្លួនមកលើការប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងកម្មវិធីលុបបំបាត់ភាពក្រីក្ររបស់ខ្លួនក៏ដោយ ហើយក្នុងចំណោមធនធានដែលមាន ធនធានទឹកត្រូវបានចាត់ទុកថាមានសក្តានុពលយ៉ាងច្រើន ដើម្បីរួមចំណែកទៅក្នុងការអភិវឌ្ឍជាតិ។ ទោះជាយ៉ាងណាក៏ដោយ ការចាត់ចែងខាងស្ថាប័នសម្រាប់គ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសឡាវ ច្រើនតែធ្វើឡើងជាវិស័យមួយដាច់ដោយឡែក១ និងមានការទទួលស្គាល់មិនឯកភាពគ្នាឡើយ អំពីតំរូវការដើម្បីគ្រប់គ្រងធនធានបែបនេះ តាមបែបសមាហរណកម្ម។

៣.៤.២ អនុសាសន៍

ដោយផ្អែកលើលទ្ធផលពីការសិក្សានេះ ផ្នែកមួយចំនួនដែលត្រូវការឱ្យមានការកែលម្អអភិបាលកិច្ច នៅក្នុងវិស័យខុស១គ្នាដែលទាក់ទងនឹងទឹក ត្រូវបានធ្វើអត្តសញ្ញាណ (*សូមអានតារាងខាងក្រោម*)។

ជារួម មានការលើកស្នើថា MWD គួរតែផ្តោតលើការគាំទ្រដល់កំណែទម្រង់សព្វថ្ងៃនេះនៅក្នុងវិស័យទឹក នូវដំណើរការរបស់ប្រទេសនេះ ដើម្បីកែលម្អអភិបាលកិច្ចទឹក ដែលកំពុងស្ថិតនៅក្រោមការពិភាក្សា។ គោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់ទឹកដែលចែងអំពីទិសដៅដើម្បីអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងការទទួលស្គាល់គោលការណ៍នានានៃការគ្រប់គ្រងទឹកតាមបែបចំរុះ គួរតែជាវិស័យអាទិភាពដំបូងសម្រាប់ការពិភាក្សាអំពី MWD នៅក្នុងប្រទេសឡាវ។

វិស័យ	របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ច
ធារាសាស្ត្រ	• បង្កើនការចូលរួមរបស់កសិករនៅក្នុងវិធាននៃការកសាងផែនការដែលផ្អែកលើតម្រូវការនៅមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រព័ន្ធស្រោចស្រព • បង្កើតយន្តការនានាដើម្បីរកផលចំណូលដោយនិរន្តរភាពសម្រាប់ប្រតិបត្តិការ និងការថែទាំ។
ជលផល និងវារីវប្បកម្ម	• ការអនុម័តសេចក្តីព្រាងច្បាប់ជលផល ដែលទទួលស្គាល់អំពីការចាត់ចែងគ្រប់គ្រងជលផល ដោយផ្អែកលើសហគមន៍/សហគ្រប់គ្រង
វារីអគ្គិសនី និងថាមពល	• ការកែលម្អកិច្ចសហប្រតិបត្តិការលើវិធានកសាងផែនការដោយផ្អែកលើ IWRM នៅទូទាំងអាងទន្លេ រវាង MEM និង WREA • ការបង្កើតស្ថាប័នសម្រាប់អនុវត្តវិធាន SEA នៅក្នុង MEM/WREA • ការពង្រឹងដំណើរការសម្រាប់ពិនិត្យសំណើនានា និងកិច្ចសន្យាផ្តល់សម្បទាន ក៏ដូចជា ការគ្រប់គ្រង និងការតាមដានគម្រោងសម្បទានក្នុងនាយកដ្ឋានអភិវឌ្ឍន៍ និងថាមពល (DEDP)/ក្រសួងថាមពល និងរ៉ែ (MEM) • ការពង្រឹងសមត្ថភាព និងប្រសិទ្ធិភាពនៃការិយាល័យ EIA នៃ WREA ដែលនឹងត្រូវធ្វើការជាមួយកំណើនជាច្រើននៃចំនួនគម្រោងនៅក្នុងរយៈពេល 5 ឆ្នាំខាងមុខ • ការធានាថា គោលនយោបាយជាតិស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមនៃវិស័យវារីអគ្គិសនីក្នុងប្រទេសឡាវ ត្រូវបានអនុវត្ត ជាពិសេស មាត្រានានាដែលទាក់ទងនឹងការបើកចំហព័ត៌មាន និងការពិគ្រោះយោបល់។

ទេសចរណ៍ និងនាវាចរណ៍	• ការបង្កើតយន្តការនានាសម្រាប់ពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះអំពីប្រព័ន្ធកែលម្អនាវាចរណ៍ • ការពង្រឹងស្ថាប័នដែលផ្អែកលើសហគមន៍នៅមូលដ្ឋាន សម្រាប់គ្រប់គ្រងទេសចរណ៍ និងកែលម្អអំណាចចរចារបស់ពួកគេ ជាមួយប្រតិបត្តិករទេសចរណ៍ជាលក្ខណៈពាណិជ្ជកម្ម • ការបង្កើតយន្តការច្បាស់លាស់សម្រាប់ការចែកផល និងប្រព័ន្ធចេញវិញ្ញាបនប័ត្រ
ការផ្គត់ផ្គង់ទឹក និងអនាម័យ	• ការបង្កើត WSUGs • ការបង្កើតយន្តការ ដំណើរការ និងការលើកទឹកចិត្តច្បាស់លាស់ សម្រាប់បង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធ នានា ជាពិសេស ក្រុមជនក្រីក្រជាងគេ • ការបង្កើតឱកាសសម្រាប់បង្កើនការពាក់ព័ន្ធនៃវិស័យឯកជន។

តារាងទី ៤. របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅប្រទេសឡាវ

៤. ប្រទេសវៀតណាម

៤.១ ទិដ្ឋភាពរួម

ដោយមានផ្ទៃដីទំហំ 331,690 គម² និងប្រជាជនប្រមាណ 84 លាននាក់[5] ភាគច្រើននៃផ្ទៃប្រទេសដែលជាទីជនបទនៃប្រទេសវៀតណាម មានប្រជាពលរដ្ឋរស់នៅកុះករជាងគេទី 13 នៅលើពិភពលោក ដោយមានដង់ស៊ីតេជាមធ្យម 250 នាក់/គម²។ ទឹកនៅលើផ្ទៃដីប្រចាំឆ្នាំមានប្រហែល 830-840 ពាន់លានម³ (ប្រមាណ 3,840 ម³ ក្នុងម្នាក់ៗ) ក្នុងនោះប្រមាណ 320-325 លានម³ បានកើតឡើងនៅក្នុងប្រទេស ហើយផ្នែកដែលនៅសល់បានមកពីប្រទេសនានានៅជិតខាង។ អាងទន្លេទាំងប្រាំ ពឹងផ្អែកលើលំហូរទឹកមកពីប្រទេសដទៃ :

- ទន្លេមេគង្គ ដែលមានជិត 92% នៃលំហូរទឹកជាមធ្យមប្រចាំឆ្នាំ បានមកពីប្រទេសចំនួនប្រាំនៅខ្សែទឹកខាងលើ
- ទន្លេថៃប៊ិញ-រ៉េត ដែលមានជិត 40% នៃទឹកហូរប្រចាំឆ្នាំ បានមកពីប្រទេសចិន
- អាងម៉ា ដែលមានទឹក 30% មានប្រភពមកពីប្រទេសឡាវ
- អាងកា ដែលទឹក 22% បានមកពីប្រទេសឡាវ
- អាងដុងណៃ ដែលជិត 17% បានមកពីប្រទេសកម្ពុជា។

ប្រភពទឹកក្រោមដីមានសក្តានុពលបន្ថែមប្រមាណ1500ម³/វិនាទី ទោះជាយ៉ាងណាក៏ដោយ របាយទឹកមានមិនស្មើគ្នាឡើយ ទាំងតាមទីកន្លែង និងពេលវេលា។ ប្រមាណ 75 ទៅ 80% នៃទឹកលើផ្ទៃដីប្រចាំឆ្នាំ បានប្រមូលផ្តុំនៅក្នុងរយៈពេលបី-បួនខែនៃរដូវវស្សា។ ជាផលវិបាក កន្លែងជាច្រើននៅក្នុងប្រទេសបានរងគ្រោះដោយសារកង្វះទឹកប្រចាំរដូវ និងគ្រោះរាំងស្ងួតនៅក្នុងរដូវប្រាំង និងទឹកជំនន់ ឬ ជាំទឹកនៅរដូវវស្សា។

តម្រូវការធនធានទឹកលើផ្ទៃដី និងការទាញយកទឹកពីក្រោមដី កំពុងកើនឡើងយ៉ាងឆាប់រហ័ស ដើម្បីបំពេញតម្រូវការសម្រាប់ការពង្រីកសេដ្ឋកិច្ច និងកំណើនចំនួនប្រជាជន។ សព្វថ្ងៃនេះ អ្នកក្រុងចំនួន 8.5 លាននាក់ ពុំមានសេវាកម្មទឹកស្អាត និង 41 លាននាក់ (ពាក់កណ្តាលនៃចំនួនប្រជាជនសរុប) ពុំបានទទួលទឹកដែលស្របតាមស្តង់ដារទឹកស្អាតនៃក្រសួងសុខាភិបាល (MoH)ឡើយ។ ប្រព័ន្ធស្រោចស្រពពុំមានប្រសិទ្ធិភាព ហើយហេដ្ឋារចនាសម្ព័ន្ធមានអាយុចំណាស់ និងទ្រុឌទ្រោម ហើយគុណភាពទឹកកាន់តែក្រខ្វក់ ជាពិសេស នៅជិតទីក្រុង និងមណ្ឌលឧស្សាហកម្ម។ រហូតដល់ ឆ្នាំ 2025 ចំនួនប្រជាជននឹងកើនឡើងដល់ 100 លាននាក់ ការអភិវឌ្ឍវារីអគ្គិសនីនឹងកើនឡើងច្រើនជាងបីដងពី 10,000 MW នៅឆ្នាំ 2010 ដល់ច្រើនជាង 33, 000 MW ហើយវត្តមានទឹកលើផ្ទៃដីជាមធ្យមប្រចាំឆ្នាំក្នុងម្នាក់ៗ នឹងត្រូវថយចុះមកត្រឹមប្រមាណ 2,830ម³។ ជារួម វិស័យទឹកនៅប្រទេសវៀតណាមបានប្រឈម នឹងការលំបាកជាខ្លាំង។

ដូច្នេះ របាយការណ៍នេះ ប៉ុនប៉ងធ្វើអត្តសញ្ញាណការចាត់ចែងសំខាន់ៗខាងអភិបាលកិច្ចនៅក្នុងវិស័យប្រើប្រាស់ទឹកចំបងៗមួយចំនួន និងប្រឹងប្រែងដើម្បីស្វែងយល់អំពីរបៀបចាត់ចែងទាំងនេះឱ្យមានប្រសិទ្ធិភាព ក្នុងការធ្វើឱ្យប្រទេសនេះអាចដោះស្រាយកង្វល់ចំបងៗរបស់ខ្លួនដែលទាក់ទងនឹងទឹក។ កង្វះចន្លោះ និងអាទិភាពសម្រាប់កែលម្អអភិបាលកិច្ចត្រូវបានធ្វើអត្តសញ្ញាណ ហើយបញ្ហាទាំងនេះមួយចំនួន ដែលជាមូលដ្ឋានសម្រាប់ការចាប់ផ្តើម MWD ត្រូវបានគូសបញ្ជាក់។

៤.២ គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងការចាត់ចែងស្ថាប័ន

៤.២.១ គោលនយោបាយ ច្បាប់ យុទ្ធសាស្ត្រ និងកិច្ចព្រមព្រៀងសំខាន់ៗ

ក្របខ័ណ្ឌថ្នាក់តំបន់

វៀតណាមក៏ជាហត្ថលេខីនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ 1995 ផងដែរ។

ក្របខ័ណ្ឌជាក់លាក់សម្រាប់ប្រទេស

ច្បាប់ការពារបរិស្ថានឆ្នាំ 1993 បានឱ្យនិយមន័យសិទ្ធិគ្រប់គ្រង និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលទាក់ទងនឹងតំបន់ដីសើម។ ច្បាប់នេះចែងអំពីការចាត់ចែងគ្រប់គ្រង ដែលរួមទាំងទីភ្នាក់ងារគ្រប់គ្រង ទីភ្នាក់ងារការពារបរិស្ថាន និងទីភ្នាក់ងាររដ្ឋបាល

[5] For the year 2008.

មូលដ្ឋានផងដែរ ។ ទិដ្ឋភាពសំខាន់បំផុតមួយនៃច្បាប់នេះ គឺជាការដាក់លក្ខខណ្ឌសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ច្បាប់ថ្មីស្តីពីកិច្ចការពារបរិស្ថានឆ្នាំ 2005 បានដាក់ជាផ្លូវការឱ្យស្របច្បាប់ជាលើកដំបូងនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងច្បាប់វៀតណាម និងពង្រឹងមូលដ្ឋានគ្រឹះសំរាប់ការចូលរួមនៅមូលដ្ឋាន ទាំងនៅក្នុងដំណើរការ EIA និង SEA ។

ច្បាប់ស្តីពីធនធានទឹក (LWR) ឆ្នាំ 1998 ផ្តល់ជាមូលដ្ឋានសម្រាប់ :

- ការបង្កើតគោលនយោបាយ គោលការណ៍ និងក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់កសាងផែនការ ការធ្វើអាជីវកម្ម ការប្រើប្រាស់ ការអភិរក្ស កិច្ចការពារ និយ័តកម្ម និងការគ្រប់គ្រងធនធានទឹកទាំងអស់សម្រាប់ការអភិវឌ្ឍទូលំទូលាយ តាមបែបសមាហរណកម្ម និងដោយនិរន្តរភាព
- កំណត់អំពីសិទ្ធិ និងការតព្វកិច្ចរបស់រដ្ឋាភិបាល អ្នកប្រើប្រាស់ទឹក និងសាធារណជន នៅក្នុងការប្រើប្រាស់ និងការពារធនធានទឹក និងការងារអ៊ីដ្រូលិក និង
- ចែងអំពីសមត្ថកិច្ច និងការទទួលខុសត្រូវខាងរដ្ឋបាល ដើម្បីអនុវត្តច្បាប់នេះ ដែលរួមទាំងកិច្ចសហប្រតិបត្តិការ ការប្រាស្រ័យឆ្លើយឆ្លង និងការសម្របសម្រួលរវាងក្រសួង និងទីភ្នាក់ងារនានានៃរដ្ឋាភិបាល ថ្នាក់ខេត្ត អ្នកប្រើប្រាស់ទឹក និងសាធារណៈជន ។

ច្បាប់នេះចែងអំពីការបង្កើតក្រុមប្រឹក្សាជាតិធនធានទឹក និងអង្គការអាងទន្លេនៅក្នុងអាងទន្លេសំខាន់ៗ ។ ច្បាប់នេះមានគោលបំណងបង្កើនភាពចុះសម្រុងគ្នានៃការគ្រប់គ្រងទឹក ដែលផ្តល់នូវយន្តការមួយសម្រាប់ការកសាងផែនការ ការប្រើប្រាស់ និងកិច្ចការពារធនធានទឹកតាមរយៈការចេញអាជ្ញាប័ណ្ណដល់អ្នកប្រើប្រាស់ទឹក និងផ្តល់លិខិតអនុញ្ញាតសម្រាប់ការបញ្ចេញសំណល់រាវ ។ ច្បាប់នេះក៏ផ្តល់ជាមធ្យោបាយសម្រាប់តាមដាន វាយតម្លៃ និងពង្រឹងការអនុវត្តច្បាប់ផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពុំមានការចែងអំពីសិទ្ធិចំពោះទឹក និងអំពីកិច្ចការពារបរិស្ថានឡើយ ដែលនាំឱ្យការគ្រប់គ្រងគុណភាពទឹកពុំមានប្រសិទ្ធិភាព ។ ច្បាប់នេះត្រូវការចាំបាច់ឱ្យមានការពិនិត្យកែសម្រួលឡើងវិញ ។

យុទ្ធសាស្ត្រជាតិធនធានទឹកឆ្ពោះទៅឆ្នាំ 2020 មានគោលដៅពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើការគ្រប់គ្រងធនធានទឹកតាមរយៈកម្មវិធីពហុភាគី និងទ្វេភាគី ដោយពង្រឹងភាពជាដៃគូជាមួយទីភ្នាក់ងារផ្តល់ជំនួយ និងអង្គការអន្តរជាតិ NGOs នានា ។ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសសមាជិកនៃគណៈកម្មាធិការទន្លេមេគង្គ MRC ក៏បានលើកស្ទើផងដែរ ទន្ទឹមនឹងការផ្តួចផ្តើមឱ្យមានកិច្ចសហប្រតិបត្តិការសម្រាប់អាងទន្លេរ៉េត និងអាងទន្លេដទៃទៀត ។ រដ្ឋាភិបាលក៏បានគ្រោង ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងវេទិកាប្រចាំតំបន់ និងអន្តរជាតិផងដែរ ដោយសង្កត់ធ្ងន់លើការផ្លាស់ប្តូរព័ត៌មាន ចែករំលែកបទពិសោធន៍ និងការចូលរួមនៅក្នុងសិក្ខាសាលាអនុសញ្ញា ។ល ។

យុទ្ធសាស្ត្រជាតិសម្រាប់ការពារបរិស្ថាន (NSEP) គឺជាក្របខ័ណ្ឌគ្រប់គ្រងបរិស្ថានមួយសម្រាប់ឆ្នាំ2001-2010 ។ យុទ្ធសាស្ត្របានផ្អែកលើដំណើរការពិគ្រោះយោបល់ទូលំទូលាយអស់រយៈពេលបីឆ្នាំ និងពាក់ព័ន្ធជាមួយក្រសួងជាច្រើន អាជ្ញាធរខេត្ត និងអង្គការពហុភាគីនិងអ្នកពាក់ព័ន្ធដទៃទៀត ។ យុទ្ធសាស្ត្រនេះលើកទឹកចិត្តឱ្យមានការបន្តអភិវឌ្ឍន៍ស្ថាប័ន និងការកសាងសមត្ថភាព និង ការធ្វើសមាហរណកម្មកិច្ចការបរិស្ថានទៅក្នុងចរន្តនៃការកសាងផែនការសេដ្ឋកិច្ច និងការធ្វើសេចក្តីសម្រេច ។

គោលដៅរួមនៃ NSEP គឺការពារ និងកែលម្អបរិស្ថាន ដើម្បីពង្រឹងគុណភាពនៃការរស់នៅ និងសុខភាពរបស់ប្រជាជន និងដើម្បីធានាការអភិវឌ្ឍប្រទេសឱ្យមានចីរភាព ។ ប្រការនេះរាប់បញ្ចូល ការដោះស្រាយបញ្ហាបំពុល ការពារ អភិរក្ស និងធានាឱ្យមានការប្រើប្រាស់ធនធានធម្មជាតិ និងជីវៈចម្រុះដោយនិរន្តរភាព និងកែលម្អគុណភាពបរិស្ថាននៅក្នុងទីក្រុង ជនបទ និងតំបន់ឧស្សាហកម្ម (Vietnam Environment Protection Agency, 2001) ។

រដ្ឋាភិបាលវៀតណាមបានអនុម័តលើគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដោយចីរភាព (របៀបវារៈទី 21 របស់វៀតណាម) នៅប្រទេសវៀតណាមក្នុងឆ្នាំ 2004 ។ ផែនការនេះនឹងត្រូវអនុវត្តក្នុងរយៈពេលប្រាំឆ្នាំ (2005-2010) ។ របៀបវារៈនេះ ធ្វើអត្តសញ្ញាណវិស័យជាអាទិភាពចំនួន 19 សម្រាប់ការ

អភិវឌ្ឍដោយចីរភាព ដែលបែងចែកជាបីក្រុម ៖

- សេដ្ឋកិច្ច
- សង្គម និង
- បរិស្ថាន ។

ដើម្បីគាំទ្រការជម្រុញគោលនយោបាយ និងការផ្សព្វផ្សាយ និងអនុវត្តរបៀបវារៈនេះ ឯកសារណែនាំមួយត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យការអភិវឌ្ឍមានចីរភាពនៅក្នុងប្រទេសវៀតណាម ។

យុទ្ធសាស្ត្រជាតិផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទ (NRWSS) ឆ្នាំ 2000-2020 ត្រូវបានរៀបរៀងឡើងដោយក្រសួងសំណង់ ក្រោមកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដោយមានការគាំទ្រពីជំនួយអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (ដានីដា) និងបានអនុម័តដោយក្រសួងនេះនៅក្នុងខែសីហា ឆ្នាំ 2000 ។

យុទ្ធសាស្ត្រ NRWSS រួមជាមួយយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជនបទ ប៉ុនប៉ងសម្រេចបាននូវគោលបំណងដូចតទៅ ៖

- កែលម្អសុខភាពរបស់ប្រជាពលរដ្ឋនៅជនបទ
- កែលម្អលក្ខខណ្ឌនៃការរស់នៅ និង
- កាត់បន្ថយការបំពុលបរិស្ថានពីលាមកមនុស្ស និងសត្វ ។

យុទ្ធសាស្ត្រនេះអធិប្បាយអំពីគោលបំណងគន្លឹះ និងកាលវិភាគដើម្បីសម្រេចបានលទ្ធផលទាំងនោះនៅក្នុងរយៈពេលរហូតដល់ឆ្នាំ 2020 ដែលរួមទាំងផែនការសកម្មភាពលំអិតសម្រាប់រយៈពេលរហូតដល់ឆ្នាំ2005 ។ សមាសភាគសំខាន់ៗនៃយុទ្ធសាស្ត្រនេះ គឺការអនុវត្ត ការអប់រំ និងសកម្មភាពប្រាស្រ័យឆ្លើយឆ្លង និងសម្រួលឱ្យអ្នកពាក់ព័ន្ធនានា បានចូលរួមកាន់តែច្រើនជាងមុន។ យុទ្ធសាស្ត្រនេះ ក៏ផ្តល់ផងដែរនូវទិសដៅស្តីពីតួនាទីនៃរដ្ឋាភិបាលនៅក្នុងវិស័យនេះ។

៤.២.២ ការចាត់ចែងខាងស្ថាប័ន

ការចាត់ចែងខាងស្ថាប័នសម្រាប់ការគ្រប់គ្រងទឹកនៅប្រទេសវៀតណាម ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ទីភ្នាក់ងារខុសៗគ្នា។ ស្ថាប័នគន្លឹះដែលបានពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក មានបង្ហាញជូនដូចខាងក្រោមនេះ។

តារាងទី ៥. ការចាត់ចែងខាងស្ថាប័ន នៅប្រទេសវៀតណាម

ទីភ្នាក់ងារ	មុខនាទី
ក្រុមប្រឹក្សាជាតិគ្រប់គ្រងធនធានទឹក	• ឧបនាយករដ្ឋមន្ត្រី គឺជាប្រធាននៃស្ថាប័នកំពូលបំផុតសម្រាប់វិស័យទឹក
អង្គការអាងទន្លេ (RBOs)	• បានទទួលស្គាល់ដោយច្បាប់ស្តីពីធនធានទឹក ថាជាយន្តការមួយសម្រាប់ការកសាងផែនការ និងគ្រប់គ្រងទឹក និងធនធានដែលពាក់ព័ន្ធនៅក្នុងអាងទន្លេមួយ • ទទួលខុសត្រូវលើការកសាងផែនការសមាហរណកម្មអាងទន្លេ ទន្ទឹមនឹងការគិតគូរ អំពីអ្នកប្រើប្រាស់ និងការប្រើប្រាស់ទឹកនៅក្នុងវិស័យខុសៗគ្នា • ការសម្របសម្រួលក្រសួង ទីភ្នាក់ងារ និងសកម្មភាពទាក់ទងនឹងទឹកនៅថ្នាក់ខេត្ត • សម្របសម្រួលការគ្រប់គ្រង និងការតាមដានធនធានទឹក • ណែនាំរដ្ឋាភិបាលលើដំណោះស្រាយទំនាស់នានាដែលទាក់ទងនឹងទឹកនៅក្នុងអាងទន្លេ
ក្រសួងធនធានធម្មជាតិ និងបរិស្ថាន (MONRE) បានបង្កើតនៅឆ្នាំ **2002**	• ណែនាំនិងចាត់ចែងការអនុវត្តឯកសារច្បាប់ និងគោលនយោបាយនានាស្តីពីធនធានទឹក • ណែនាំ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ធ្វើនិទស្សន៍អំពីធនធានទឹកនិងកម្មវិធីទូទៅនានា ស្តីពីការទប់ស្កាត់នូវភាពរេចរឹល និងការបាត់បង់ធនធានទឹក • ណែនាំ និងវាយតម្លៃអំពីការអនុវត្តបទប្បញ្ញត្តិនានាស្តីពីការបូមយកទឹក • កសាង គ្រប់គ្រង និងធ្វើអាជីវកម្មបណ្តាញមួយសម្រាប់តាមដាននិងវាស់ធនធានទឹក • ប៉ាន់ប្រមាណអំពីនិទស្សន៍លើការប្រើប្រាស់ទឹកតាមវិស័យ គម្រោងស្តីពីការបង្វែរទឹករវាងអាងទន្លេ ដែលរៀបចំឡើងដោយរដ្ឋាភិបាល វិស័យនានា និង/ខេត្តនានា

	• ណែនាំនិងវាយតម្លៃលើការចេញ និងការដកហូតអាជ្ញាប័ណ្ណស្តីពីធនធានទឹក ដូចដែលកំណត់នៅក្នុងឯកសារច្បាប់នានា • ការអនុវត្តវិធីនានាដើម្បីទប់ស្កាត់ការបំពុលធនធានទឹក ស្តារឡើងវិញនូវធនធាន ទឹកដែលក្រខ្វក់/បាត់បង់
ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ (MARD)	• ណែនាំលើការអនុវត្តយុទ្ធសាស្ត្រនានា ការនិទស្សន៍អំពីការស្រោចស្រព យុទ្ធសាស្ត្រនានាស្តីពីការទប់ស្កាត់ និងកាត់បន្ថយគ្រោះធម្មជាតិ • ធ្វើនិទស្សន៍អំពីការស្រោចស្រពសម្រាប់តំបន់/អាងទន្លេទឹកនានាដើម្បីបម្រើដល់ផលិតកម្ម កសិកម្ម • ផ្តល់ការអនុម័តលើការកសាងផែនការសាងសង់ទំនប់ និងការស្រោចស្រព • ផ្សព្វផ្សាយជាសាធារណៈ ដឹកនាំ ណែនាំ តាមដាន ប៉ាន់ប្រមាណ ធ្វើសំយោគ និងសង្ខេបរបាយការណ៍នានាស្តីពីការអនុវត្តតាមនិទស្សន៍ ផែនការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពដែលបានអនុម័ត • លើកស្នើវិធីអនុវត្តសម្រាប់គ្រឿងគរសម្ភារៈ និងមធ្យោបាយនានាដើម្បីទប់ស្កាត់និង ជួសជុល ការខូចខាតនានា ដែលបង្កដោយទឹកជំនន់ គ្រោះរាំងស្ងួត ភាពជាំទឹក បរាជ័យនៃការងារស្រោចស្រព និងផលប៉ះពាល់នៃទឹក ការណែនាំលើការបង្វែរទឹកជំនន់ ការពន្យាពេលមកដល់នៃទឹកជំនន់ ការជម្លៀសប្រជាជន • ទទួលខុសត្រូវលើភូមិសិប្បកម្ម ការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ។
ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម (MOTI)	• MOTI ទទួលខុសត្រូវលើវារីអគ្គិសនី ក្នុងចំណោមមុខនាទី និងការអនុវត្តដទៃទៀត ក៏ដូចជាប្រតិបត្តិការប្រព័ន្ធវារីអគ្គិសនីផងដែរ។
ក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (MOST)	• បានបង្កើតតាមរយៈការអនុម័តច្បាប់ស្តីពីកិច្ចការពារបរិស្ថាន ឆ្នាំ 1993 ក្រសួង MOST បង្កើតស្តង់ដារគុណភាពទឹក អនុវត្តការស្រាវជ្រាវ និងគ្រប់គ្រងបរិស្ថានតាមរយៈដំណើរការ EIA។
ក្រសួងសំណង់ (MOC)	• ការផ្គត់ផ្គង់ទឹក ការដោះទឹក និងអនាម័យនៅទីក្រុង • កំណត់បទប្បញ្ញត្តិ បង្កើតគំរូប្លង់ និងសាងសង់មធ្យោបាយផ្គត់ផ្គង់ទឹក និងអនាម័យ តាមរយៈក្រុមហ៊ុន បង្កើតគំរូប្លង់ និងសាងសង់។
ក្រសួងដឹកជញ្ជូន (MOT)	• ទទួលខុសត្រូវលើការទប់ស្កាត់ និងការពារការបំពុលប្រភពទឹក ដោយសារនាវាចរណ៍សមុទ្រ • ការគ្រប់គ្រងការងារ និងកំពង់ផែសមុទ្រ។
នាយកដ្ឋានកសិកម្ម និងអភិវឌ្ឍន៍ជនបទ (DARD)	• ក្នុងពេលដែល MARD រៀបចំគោលនយោបាយ បទបញ្ជា និងនីតិវិធីនានា DARD គឺជាអ្នកប្រតិបត្តិការប្រព័ន្ធអ៊ីដ្រូលិក • DARDs ភាគច្រើនគ្រប់គ្រងលើសហគ្រាសស្វយ័តមួយចំនួន ដែលអភិវឌ្ឍន៍ និងគ្រប់គ្រង ធនធានទឹក សម្រាប់គណៈកម្មាធិការប្រជាជនខេត្ត (PPC) ។
មន្ទីរកសិកម្ម និងអភិវឌ្ឍន៍ជនបទខេត្ត (PARDS)	• PARDS គ្រប់គ្រងលើសកម្មភាពធនធានទឹកនៅថ្នាក់ខេត្ត និងបង្កើតផែនការគ្រប់គ្រងទឹកនៅថ្នាក់ខេត្ត
ក្រុមហ៊ុនគ្រប់គ្រងការស្រោចស្រព និងការដោះទឹក (IDMCs)	• 128 IDMCs, (ភាគច្រើនជាសហគ្រាសរដ្ឋ បើទោះសហគ្រាសខ្លះគឺជាក្រុមហ៊ុនរដ្ឋទាំងស្រុង ឬជាក្រុមហ៊ុនដែលមានភាគហ៊ុនរួមក៏ដោយ) ប្រតិបត្តិការប្រព័ន្ធចែកចាយទឹក និងគ្រប់គ្រងប្រតិបត្តិការ និងការថែរក្សា មានតាមលំដាប់ថ្នាក់រហូតដល់ចំណុចដែលទឹកត្រូវបានប្រគល់ទៅដល់ស្រុកមួយ។ • ទំនាក់ទំនងជាមួយកសិករ ដែលគេហៅថា "ស្ថានីយ៍ស្រុក" ផ្តោតលើការគ្រប់គ្រងកិច្ចសន្យានានា

	វវាង IDMC និងសហករណ៍កសិករ ឬ ក្រុមនានានៅថ្នាក់ឃុំ ដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹក និងការបង់ប្រាក់សម្រាប់ទឹកដែលបានផ្គត់ផ្គង់។ • គេឃើញមានកំណើននិន្នាការនៃការផ្ទេរដីដែលស្ថិតក្រោមប្រព័ន្ធស្រោចស្រពទៅ IDMCs។ គេបានប៉ាន់ប្រមាណថា ច្រើនជាង 65% នៃដីផ្លូវដែលមានប្រព័ន្ធស្រោចស្រពក្នុងប្រទេសវៀតណាម សព្វថ្ងៃនេះ ស្ថិតក្រោមការគ្រប់គ្រងតាមវិធីនេះ។
អង្គការអ្នកប្រើប្រាស់ទឹក (WUOs)	• ក្នុងករណីដែល IDMCs មួយចំនួន គ្រប់គ្រងប្រព័ន្ធស្រោចស្រពទាំងមូល ចាប់ពីប្រភពទឹក រហូតដល់ប្រឡាយនៅក្នុងកសិដ្ឋាន ប្រឡាយនៅលំដាប់ទីពីរ និងប្រឡាយតូចៗទាំងនេះ ស្ថិតក្រោមការគ្រប់គ្រងដោយអង្គការអ្នកប្រើប្រាស់ទឹក។ ក្នុងករណីខ្លះ ប្រព័ន្ធស្រោចស្រពទាំងមូលស្ថិតក្រោមការគ្រប់គ្រងដោយ WUOs។

៤.៣ ស្ថានភាពនៃវិស័យនានា

៤.៣.១ វិស័យស្រោចស្រព

សព្វថ្ងៃនេះ ប្រមាណ 82% នៃការប្រើប្រាស់ទឹកសរុប គឺការស្រោចស្រព។ វៀតណាមមានប្រព័ន្ធស្រោចស្រពខ្នាតធំចំនួន 75 ទំនប់ខ្នាតធំ និងមធ្យមចំនួន 800 ហើយអាងទឹកច្រើនជាង 3,500 ដែលមានសមត្ថភាពលើសពីមួយលានម៉ែត្រគូប ទ្វារទឹកខ្នាតធំចំនួន 5,000 ស្ថានីយ៍បូមទឹកច្រើនជាង 2,000 និងស្ថានីយ៍ផ្គត់ផ្គង់ផ្គង់ទឹកខ្នាតតូចជាច្រើនពាន់កន្លែងទៀត។ ដីទំហំប្រមាណ 3,3 លានហិកតាស្ថិតក្រោមការស្រោចស្រពទាំងស្រុង ចំណែកដីច្រើនជាងមួយលានហិកតាស្ថិតក្រោមការស្រោចស្រពខ្លះៗ ដែលរួមគ្នាមានសមត្ថភាពស្រោចស្រពលើផ្ទៃដីធំជាង 80%នៃដីដាំដំណាំនៅក្នុងប្រទេស។ ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពយ៉ាងខ្លាំងក្លាក្នុងរយៈពេលជាច្រើនឆ្នាំមកនេះបានជួយធានាសន្តិសុខស្បៀង និងបានធ្វើឱ្យប្រទេសវៀតណាមក្លាយជាប្រទេសនាំមុខលើពិភពលោក ក្នុងការអ្នកនាំចេញស្រូវ។ ជាទូទៅ ការផ្គត់ផ្គង់ទឹកមិនគិតថ្លៃទេ (ដែលចាត់ទុកជាសេវាកម្មសង្គមដល់សហគមន៍នៅជនបទ)។ ប្រព័ន្ធស្រោចស្រពកាន់តែលែងសូវមានប្រសិទ្ធិភាព នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធកាន់តែមានអាយុចំណាស់ ហើយគេមានថវិកាក្នុងកម្រិតកំណត់ សម្រាប់ការថែទាំ និងជួសជុល។

ការលំបាកចំបងៗដែលវិស័យស្រោចស្រពកំពុងប្រឈមគឺ :

- ក្របខ័ណ្ឌស្ថាប័ន ច្បាប់ និងគោលនយោបាយ ប្រឈមនឹងកង្វះចន្លោះ និងភាពត្រួតគ្នា កង្វះសង្គត់ភាព និងភាពដូចគ្នា ដែលបង្កើតជាភាពមិនប្រាកដប្រជានៃអាណត្តិ និងមុខនាទីភាពមិនច្បាស់លាស់នៃការគ្រប់គ្រងធនធានទឹក ការស្រោចស្រព ការដោះទឹក និងជម្រុញឱ្យមានភាពអសកម្ម និងទំនាស់អំពីតំបន់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័ននានា។
- ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព បានប្រព្រឹត្តទៅតាមតម្រូវការនៅមូលដ្ឋាន តាមរយៈវិធាន"បញ្ជា និងត្រួតពិនិត្យ" ដែលបានបង្កើតឡើងដើម្បីបំពេញតាមតម្រូវការនៃប្រព័ន្ធស្រោចស្រពស្រូវ។ កសិករមានសិទ្ធិតិចតួចក្នុងការបញ្ចេញយោបល់លើការគ្រប់គ្រងប្រព័ន្ធ ហើយការបង្កើនមុខដំណាំគឺជាការលំបាក
- ការអនុវត្តគំរូ PIM ត្រូវរាំងស្ទះ ដោយសារភាពយឺតយ៉ាវនៃការអនុវត្ត ការលើកទឹកចិត្តតិចតួចដើម្បីឱ្យកសិករចូលរួម ដោយសារទឹកត្រូវបានផ្តល់ដោយឥតគិតថ្លៃ
- ការប្រាស្រ័យឆ្លើយឆ្លង និងការសម្របសម្រួលលើ IDMCs នៅមានកម្រិតកំណត់ រវាងក្រុមប្រឹក្សានាយក ការគ្រប់គ្រងបច្ចេកទេស/ទឹក និងនាយកដ្ឋានហិរញ្ញវត្ថុ/រដ្ឋបាល និងស្ថានីយ៍នៅតាមមូលដ្ឋាន។

ដូច្នេះរបៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យស្រោចស្រព គួរតែរួមបញ្ចូល :

- ការពិនិត្យ និងកែទម្រង់ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលរួមទាំង ការគូសបញ្ជាក់អំពីអាណត្តិ និងមុខនាទីរបស់ទីភ្នាក់ងារខុសៗគ្នា
- កែលម្អដំណើរការសម្របសម្រួល និងការប្រាស្រ័យឆ្លើយឆ្លងអំពី IDMCs និង
- ការទទួលយកកាន់តែច្រើនឡើងនូវវិធាន PIM ដោយផ្អែកលើមេរៀនដែលបានពីគំរូប្រកបដោយជោគជ័យ និងផ្តល់ការ

លើកទឹកចិត្តដល់កសិករដើម្បីឱ្យចូលរួមពាក់ព័ន្ធ។

៤.៣.២ វិស័យជលផល និងវារីវប្បកម្ម

វិស័យជលផលក្នុងប្រទេសវៀតណាម បាននឹងកំពុងកើនឡើងយ៉ាងខ្លាំង ហើយរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តខ្លាំងក្លា ដោយចាត់ទុកជាមធ្យោបាយកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រ។ វិស័យនេះផ្តល់ប្រមាណពាក់កណ្តាលនៃប្រភពប្រូតេអ៊ីនពីជាតិសាច់នៅក្នុងអាហាររបស់ប្រជាជន។ ប្រាក់ចំណូលសរុបបានធ្វើឱ្យវិស័យនេះក្លាយជាវិស័យនាំចេញសំខាន់បំផុតទីបី។ ប្រជាជនច្រើនជាងបីលាននាក់ ធ្វើការដោយផ្ទាល់ និងជិត 10% នៃចំនួនប្រជាជន បានទទួលប្រាក់ចំណូលចំបងរបស់ខ្លួនពីវិស័យជលផល។

វារីវប្បកម្ម បានកើនឡើងយ៉ាងច្រើននៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ដែលជាមធ្យមមានច្រើនជាង 12% នៃកំណើនប្រចាំឆ្នាំចាប់តាំងពីឆ្នាំ 1990 មក ដែលរួមចំណែកដល់ច្រើនជាង 40% នៃផលិតផលជលផលសរុប ដោយមានតម្លៃ 15,400 ពាន់លានដុងនៅក្នុងឆ្នាំ 2003 (Kellogg Brown and Root Pty Ltd, 2008)។

ការប្រឈមខ្លះៗដែលទាក់ទងនឹងវិស័យជលផល និងវារីវប្បកម្ម រួមមាន :

- ដំណើរការដែលគ្មានប្រសិទ្ធិភាពនៃសហគ្រាសជលផលរដ្ឋ ដែលផ្តល់ផលចំណូលតិចតួចធៀបនឹងការវិនិយោគរបស់ខ្លួន
- ដំណើរការខាងបរិស្ថាន ជាពិសេស ការគ្រប់គ្រងសំណល់រាវមានភាពទន់ខ្សោយជាខ្លាំង
- ព័ត៌មាន ការស្រាវជ្រាវ និងការកសាងសមត្ថភាពមិនទាន់គ្រប់គ្រាន់
- កង្វះការយល់ដឹងអំពីការគ្រប់គ្រងបរិស្ថាន និងការអភិរក្សធនធានជលផល
- ការបណ្តុះបណ្តាលវិជ្ជាជីវៈដែលនៅមានកម្រិតកំណត់ និងកង្វះកម្មករជំនាញនៅថ្នាក់មូលដ្ឋាន និង
- ភាពទន់ខ្សោយនៃសេវាកម្មផ្សព្វផ្សាយអំពីវិស័យវារីវប្បកម្ម។

ដូច្នេះរបៀបវារៈសំខាន់ៗសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យជលផល និងវារីវប្បកម្មគឺ កែទម្រង់សហគ្រាសជលផលរដ្ឋ។

៤.៣.៣ វិស័យវារីអគ្គិសនី

ពីឆ្នាំ 1995 ដល់ 2005 សមត្ថភាពសម្រាប់ផលិតអគ្គិសនី បានកើនឡើងជិតបីដង ដោយមានអត្រាកំណើនជាមធ្យម 12.7% ក្នុងមួយឆ្នាំៗ ប៉ុន្តែនៅតែមិនទាន់អាចបំពេញតម្រូវការនៅឡើយទេ។ នៅមុនឆ្នាំ 2010 វារីអគ្គិសនីនឹងផ្តល់ 42% នៃសមត្ថភាពសរុបលើការផលិតថាមពលជាតិ។ អាងទន្លេសំខាន់ៗបំផុតចំនួនបី ដែលមានសមត្ថភាពផលិតវារីអគ្គិសនីគឺអាងទន្លេរ៉េត-ថៃប៊ីង ដុងណៃ និងសេសាន។

ការប្រឈមខ្លះៗ ដែលទាក់ទងនឹងវិស័យវារីអគ្គិសនីរួមមានៈ

- ការកសាងផែនការ និងការសំរបសំរួលក្នុងកម្រិតអប្បបរមារវាងវិស័យវារីអគ្គិសនី និងវិស័យដទៃទៀត។ ប្រការនេះនាំឱ្យមានផលប៉ះពាល់ដែលមិនបានគ្រោងទុក បណ្តាលមកពីការអភិវឌ្ឍន៍វារីអគ្គិសនី មកលើវិស័យដទៃទៀត និងសកម្មភាពនានា និងផ្ទុយមកវិញ។
- អវត្តមានយន្តការពិគ្រោះយោបល់ផ្លូវការ ដើម្បីឱ្យមានការចូលរួមដោយប្រសិទ្ធិភាពពីសង្គមស៊ីវិល
- ការពិចារណាតិចតួចអំពីសក្តានុពលនៃពហុប្រើប្រាស់អាងទឹក ដែលតម្រូវឱ្យមានការវិនិយោគជាច្រើនលើវិស័យសាធារណៈ
- ការយល់ដឹងក្នុងកម្រិតកំណត់អំពីផលប៉ះពាល់ពីវារីអគ្គិសនី ក៏ដូចជា ជម្រើសការកាត់បន្ថយផលប៉ះពាល់។

ចំណុចពីខាងដើមពិតជាពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ច។ លើសពីនេះ ថ្មីៗនេះវៀតណាមបានប្រឈមនឹងបញ្ហាខ្លះៗនៃការអភិវឌ្ឍវារីអគ្គិសនីមកលើទន្លេអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះប្រទេសវៀតណាម កម្ពុជា និងឡាវ បានបង្កើតវេទិកាមួយដើម្បីពិភាក្សាអំពីបញ្ហាអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ជាពិសេស ការអភិវឌ្ឍវារីអគ្គិសនី នៅក្នុងតំបន់ជាប់ព្រំប្រទល់។ ចិនក៏កំពុងកសាងផែនការគម្រោងវារីអគ្គិសនីជាច្រើននៅក្នុងអាងរងទឹកភ្លៀងនៃទន្លេរ៉េតផងដែរ ប៉ុន្តែការពិគ្រោះយោបល់ជាមួយប្រទេសវៀតណាមអំពីសំណើទាំងនេះ ឬ ផលប៉ះពាល់នៃទំនប់ទាំងនោះមានកម្រិតទាប។ ដើម្បីឈានទៅមុខ គេចាំបាច់ឱ្យមានបរិយាកាសខាងផ្លូវច្បាប់រឹងមាំ ដោយមានដំណើរការច្បាស់លាស់ ការប្រាស្រ័យឆ្លើយឆ្លងបានល្អ និងបទបញ្ជាដែលអនុវត្តចំពោះទាំងប្រតិបត្តិករជាស្ថាប័នរដ្ឋាភិបាល

និងមិនមែនរដ្ឋាភិបាល។

ដូច្នេះ របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ចក្នុងវិស័យវារីអគ្គិសនី គួរតែរាប់បញ្ចូល ៖

- កែលម្អការកសាងផែនការពហុវិស័យដោយសហការគ្នា (នៅកម្រិតអាងទាំងមូល និងគោលការណ៍ IWRM)
- ការបង្កើតស្តង់ដារ និងកែលម្អលើការអនុវត្តក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEAs) និងការវាយតម្លៃផលប៉ះពាល់សរុប (CIAs) និង
- ការបង្កើតយន្តការពិគ្រោះយោបល់ផ្លូវការដើម្បីឱ្យមានការចូលរួមដោយប្រសិទ្ធិភាពពីសំណាក់អ្នកពាក់ព័ន្ធនានា ទាំងនៅក្នុងប្រទេសនិងឆ្លងដែន នៅពេលដែលទំនប់ក្នុងប្រទេសវៀតណាមបង្កផលប៉ះពាល់មកលើប្រទេសជិតខាង ឬ ទំនប់ក្នុងប្រទេសជិតខាង បង្កផលប៉ះពាល់មកលើប្រទេសវៀតណាម។

៤.៣.៤ វិស័យទេសចរណ៍ និងនាវាចរណ៍

ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកសាប មានប្រមាណ 20% នៃទំនិញសរុបដែលដឹកជញ្ជូននៅក្នុងប្រទេសវៀតណាម និងបានកើនឡើង 7% នៅក្នុងរវាងឆ្នាំ 2001 និង 2006។ នៅឆ្នាំ 2006 ប្រមាណ 13% នៃការដឹកជញ្ជូនអ្នកដំណើរសរុបបានកើតមានតាមផ្លូវទឹកសាប។ តម្លៃសរុបនៃការដឹកជញ្ជូនតាមផ្លូវទឹកសាបមានជិត 7,730 ពាន់លានដុង នៅក្នុងឆ្នាំ 2004។ ការប្រឈមខ្លះៗដែលទាក់ទងនឹងវិស័យដឹកជញ្ជូន និងនាវាចរណ៍ រួមមាន ៖

- កម្រិតកំណត់ក្នុងការកសាងផែនការ ឬសម្របសម្រួល រវាងវិស័យនាវាចរណ៍ និងវិស័យដទៃទៀត
- តម្រូវការឱ្យមានគោលនយោបាយ និងការងារបច្ចេកទេសបន្ថែម ដែលត្រូវអនុវត្ត ដើម្បីកែលម្អការដឹកជញ្ជូនតាមផ្លូវទឹកសាបជាមួយប្រទេសកម្ពុជា ឡាវ និងចិន
- កង្វះក្របខ័ណ្ឌច្បាប់លំអិតសម្រាប់ការគ្រប់គ្រងនាវាចរណ៍ផ្លូវទឹកសាប
- ភាពទន់ខ្សោយនៃយន្តការចូលរួម និងវត្ថុមានមិនគ្រប់គ្រាន់ក្នុងការប្រាស្រ័យឆ្លើយឆ្លង និងប្រព័ន្ធឆ្លើយតបទៅនឹងការព្រមាន
- កង្វះការយល់ដឹងអំពីបញ្ហានាវាចរណ៍នៅក្នុងវិស័យរដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់ខេត្ត
- កម្រិតកំណត់នៃការយល់ដឹងអំពីបរិយាកាសខាងផ្លូវច្បាប់ក្នុងចំណោមប្រតិបត្តិករនាវា និងក្រុមហ៊ុននាវាចរណ៍ និង
- ផលប៉ះពាល់អវិជ្ជមាននៃនាវាចរណ៍ ទាក់ទងនឹងការដាក់កំហិត និងសុវត្ថិភាព ដោយសារការអភិវឌ្ឍវារីវប្បកម្ម។

ចំណុចបួនខាងដើមក្នុងចំណោមការប្រឈមទាំងនេះ តំណាងឱ្យបញ្ហាអភិបាលកិច្ចសំខាន់ៗ។ ដូច្នេះ របៀបវារៈសំខាន់ៗសម្រាប់កែលម្អអភិបាលកិច្ចក្នុងវិស័យនាវាចរណ៍គួររាប់បញ្ចូល ៖

- កសាងក្របខ័ណ្ឌច្បាប់លំអិត
- កសាងគោលនយោបាយប្រចាំតំបន់ ដើម្បីគាំទ្រឱ្យមាននាវាចរណ៍ឆ្លងដែន រវាងវៀតណាម កម្ពុជា និងចិន ហើយនិង
- កែលម្អយន្តការនៃការចូលរួម។

៤.៣.៥ វិស័យផ្គត់ផ្គង់ទឹក និងអនាម័យ

ប្រមាណ 62% នៃប្រជាជននៅទីក្រុងមានទឹកស្អាតប្រើប្រាស់។ នៅឆ្នាំ 2005 ការផ្គត់ផ្គង់ទឹកជាមធ្យមនៅតាមទីក្រុងមានប្រមាណ 80-90លីត្រក្នុងម្នាក់ៗ/ថ្ងៃ នៅក្នុងទីក្រុងតូចៗ និង120-130 លីត្រ នៅក្នុងទីក្រុងធំៗ។ រវាងឆ្នាំ 1991 និង 2005 រដ្ឋាភិបាលបានវិនិយោគ 18,567 ពាន់លានដុង លើប្រព័ន្ធផ្គត់ផ្គង់ទឹក ក្នុងនោះភាគហ៊ុនវិនិយោគពីបរទេសមាន 15,020 ពាន់លានដុង។
ការវិនិយោគនេះបានបង្កើនសមត្ថភាពផ្គត់ផ្គង់ទឹកបាន 1,250,000ម^3/ ថ្ងៃ។

វិសាលភាពជាតិនៃការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ត្រូវបានប៉ាន់ប្រមាណថាមាន 66% ហើយបង្គន់អនាម័យមាន 50%។ គ្រួសារភាគច្រើននៅជនបទប្រើប្រាស់អណ្តូងជីកតាមប្រពៃណីសម្រាប់ជាប្រភពទឹកស្អាតជាបឋមរបស់ខ្លួន ជាពិសេសគ្រួសារនានាដែលមានប្រាក់ចំណូលទាប។ អណ្តូងខួងគឺជាគំរូដែលមានប្រើប្រាស់ទូទៅជាងគេទីពីរ ដែលគ្រួសារនៅជនបទប្រមាណ 22% ប្រើប្រាស់។ មានតែ 4ទៅ6% នៃប្រជាជននៅជនបទ មានទឹកម៉ាស៊ីនសម្រាប់ប្រើប្រាស់។ គ្រួសារប្រហែល 12% ប្រើប្រាស់ទឹកលើផ្ទៃដីដែលពុំមានវិធានការការពារ សម្រាប់ផឹក និងចំអិនអាហារ គ្រួសារចំនួន 11 ទៅ 19% ពឹងផ្អែកលើទឹកភ្លៀងសម្រាប់ការប្រើប្រាស់ផ្ទាល់ ចំណែកគ្រួសារតិចជាង 1% ទិញទឹកស្អាត។ គ្រួសារនៅជនបទនៃប្រទេសវៀតណាមកំពុងទទួលសេវាកាន់តែកើនឡើងពីវិស័យឯកជន ដែលជា

សហគ្រាសខ្នាតតូច និងតូចបំផុតជាច្រើនពាន់។ សហគ្រាសទាំងនេះ មានរាប់ចាប់ពីបុគ្គលនានា ដែលដំណើរការសហគ្រាសមិនផ្លូវការ ដោយខ្លួនឯងផ្ទាល់ ដែលខួងអណ្តូង និងតម្លើងស្នប់ រហូតដល់សហគ្រាសនានា ដែលដឹកទឹកលក់ និង ក្រុមហ៊ុនផ្គត់ផ្គង់ទឹកតូចៗ ដែលផ្តល់ទឹកម៉ាស៊ីនដល់គ្រួសារនានា។

រដ្ឋាភិបាលបានផ្តួចផ្តើមឱ្យមានកម្មវិធីចំណុចដៅនៃការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទជំហានទីពីរ (RWSS NTP II) សម្រាប់ឆ្នាំ 2006-2010។ គេរំពឹងថាមុនដំណាច់ឆ្នាំ 2010 :

- 85% នៃប្រជាពលរដ្ឋនៅជនបទ អាចប្រើប្រាស់ទឹកស្អាត 60 លីត្រក្នុងម្នាក់ៗ/ថ្ងៃ។
- គ្រួសារនៅជនបទចំនួន 70% អាចនឹងកែបង្គន់ស្អាតជាងមុន
- 70% នៃកន្លែងចិញ្ចឹមសត្វអាចនឹងកែលម្អអនាម័យ និង
- 100% នៃសាលារៀន គ្លីនិក គណៈកម្មាធិការប្រជាជនឃុំ និងកន្លែងសាធារណៈនៅទីជនបទអាចមានសិទ្ធិទទួលបានទឹកស្អាត និងកែលម្អបង្គន់របស់ខ្លួន។

ក្នុងពេលដែលសម្រេចបាននូវការរីកចម្រើននៅក្នុងវិស័យនេះ គេនៅឃើញមានការប្រឈមនានានៅឡើយ ដែលរួមមាន :

- ភាពទន់ខ្សោយនៃការសម្របសម្រួលរវាងស្ថាប័នខុសៗគ្នាដែលពាក់ព័ន្ធនៅក្នុងវិស័យនេះ ជាពិសេស នៅថ្នាក់ខេត្ត
- សហគ្រាសផ្គត់ផ្គង់ទឹក និងដោះទឹក កំពុងជួបឧបសគ្គដោយសារគោលនយោបាយមិនអំណោយផល និងគ្មានសង្គតិភាព និងការចាត់ចែងខាងស្ថាប័នមិនច្បាស់លាស់។ ប្រការទាំងនេះ គឺជាឧបសគ្គចំពោះការលើកកំពស់សមត្ថភាពផ្គត់ផ្គង់គុណភាពទឹក គុណភាពនៃសេវាកម្ម និងស្វ័យភាពខាងហិរញ្ញវត្ថុរបស់សហគ្រាស។
- ការចូលរួមរបស់សហគមន៍ក្នុងកម្រិតកំណត់
- កម្រិតកំណត់នៃនិរន្តរភាពហិរញ្ញវត្ថុនៃប្រព័ន្ធទឹក ដោយការកំណត់ថ្លៃទឹកមានអត្រាទាបពេក
- គ្មានការលើកទឹកចិត្តដើម្បីប្រមូលយកសំណល់រាវ ដោយសារក្រុមហ៊ុនផ្គត់ផ្គង់ទឹក បានទារយកថ្លៃទឹកសំអុយក្នុងកម្រិតអប្បបរមា ដោយបានបង្វែរទៅខេត្ត ឬក្រុងនានា និងមិនមែនទៅក្រុមហ៊ុននានាដែលជាអ្នកផ្តល់សេវា និង
- កង្វះកម្មករដែលមានជំនាញខ្ពស់ ដើម្បីប្រតិបត្តិការដោយប្រើប្រាស់បច្ចេកទេសជាន់ខ្ពស់។

ក្នុងចំណោមចំណុចទាំងនេះ របៀបវារៈសំខាន់សម្រាប់កែលម្អអភិបាលកិច្ចលើការផ្គត់ផ្គង់ទឹក និងអនាម័យគួរតែរាប់បញ្ចូល :

- បង្កើនសង្គតិភាពខាងគោលនយោបាយសម្រាប់សហគ្រាសផ្គត់ផ្គង់ទឹក និងការដោះទឹក
- កែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា និង
- បង្កើតយន្តការនានាសម្រាប់ការចូលរួមរបស់សហគមន៍។

៤.៣.៦ វិស័យឧស្សាហកម្ម និងភូមិសិប្បកម្ម

នៅឆ្នាំ 2006 សកម្មភាពឧស្សាហកម្ម មានច្រើនជាង 41% នៃ GDP របស់ជាតិ ហើយគេរំពឹងថានឹងកើនឡើងដល់ 45% រហូតដល់ឆ្នាំ2010។ ក្នុងរយៈពេល 7ឆ្នាំកន្លងមក វិស័យឧស្សាហកម្មសម្រេចបានកំណើនប្រចាំឆ្នាំជាមធ្យម 17,3% ដោយមាន GDP កើនឡើងទ្វេដងនៅក្នុងអំឡុងឆ្នាំ 2002 ដល់ 2006។ សកម្មភាពឧស្សាហកម្មកំពុងប្រមូលផ្តុំនៅក្នុងអាងទន្លេរ៉ែត-ថៃប៊ីងនៃតំបន់បារីយ៉ា ខេត្តវ៉ុងតាវ និងអាងទន្លេដុងណៃ ដែលរួមជាមួយគ្នាមានជិត 80%នៃតម្លៃសរុបផលិតផលឧស្សាហកម្ម (Kellogg Brown and Root Pty Ltd, 2008)។ ឧស្សាហកម្មប្រើប្រាស់ទឹកសរុបប្រមាណ 3,760ម^3 ក្នុងមួយឆ្នាំ ដែលរហូតដល់ឆ្នាំ 2015 ត្រូវបានរំពឹងថានឹងកើនឡើងពីរដង។ ការបញ្ចេញចោលសំណល់ពីឧស្សាហកម្ម គឺជាបញ្ហាចំបងមួយដែលបង្កឱ្យមានការបំពុលប្រភពទឹកធ្ងន់ធ្ងរ។ មានតែ 70% នៃសំណល់រាវដែលបានឆ្លងកាត់ប្រព្រឹត្តកម្មសំអាត ហើយអាចថយចុះមកត្រឹមតែ 31% នៅពេលដែលមានការប្រើប្រាស់ត្រឹមមួយភាគរយនៃផ្ទៃដីសម្រាប់ការធ្វើប្រព្រឹត្តកម្មសំណល់រាវ។

ឧស្សាហកម្មភូមិសិប្បកម្មបានឆ្លងកាត់កំណើនគួរឱ្យកត់សំគាល់ ជាពិសេសនៅក្នុងអាងទន្លេរ៉ែត-ថៃប៊ីង។ ភូមិសិប្បកម្ម ជាកន្លែងដែលមានហានិភ័យខ្ពស់ចំពោះសុខភាព និងរងឥទ្ធិពលពីការបំពុល ជាពិសេសនៅក្នុងឧស្សាហកម្មខ្នាតតូច ដោយគ្មានបច្ចេកវិទ្យាត្រួតពិនិត្យការបំពុល កិច្ចការពារកម្មករ ឬការប្រព្រឹត្តកម្មសំណល់រាវ។ គ្រួសារនៅក្នុងភូមិស្ទើរតែទាំងអស់ប្រើប្រាស់ផ្ទះ និងសួន របស់ខ្លួនជាកន្លែងផលិតកម្ម ដោយបញ្ចេញសំណល់ដោយផ្ទាល់ទៅក្នុងទីជុំវិញផ្ទះ និងទន្លេ។ ប្រការនេះមានឥទ្ធិពលដោយផ្ទាល់ មិនត្រឹមតែ

មកលើប្រភពទឹកលើដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្រោមដីផងដែរ ដែលធ្វើឱ្យមានឥទ្ធិពលមកលើប្រភពទឹកផឹក។ ការបំពុលទឹកពីភូមិសិប្បកម្ម គឺជាបញ្ហាធ្ងន់ធ្ងរ និងកំពុងកើនឡើង ចំណែកងការប្រើប្រាស់ទឹកច្រើនហួសហេតុ ជាពិសេស ពីសំណាក់ភូមិកែច្នៃស្បៀង មានឥទ្ធិពលយ៉ាងច្រើនមកលើប្រភពធនធានទឹក ដែលមានក្នុងកម្រិតកំណត់។ ការប្រឈមដទៃទៀត ដែលទាក់ទងនឹងឧស្សាហកម្ម និងវិស័យភូមិសិប្បកម្ម រួមមាន :

- កំណើនតម្រូវការទឹក
- ការកើនឡើងនៃសំណល់រាវយ៉ាងច្រើន និងកំណើនកម្រិតពុល ក៏ដូចជា ភាពស្មុគស្មាញនៃការបំពុល មានឥទ្ធិពលចំពោះទឹកលើដី ក៏ដូចជា ប្រភពទឹកក្រោមដីផងដែរ
- កំណើនបន្ទុកមកលើតម្រូវការទឹកក្នុងមណ្ឌលឧស្សាហកម្ម ដោយសារកំណើនការប្រមូលផ្តុំនៃចំនួនប្រជាជន
- ភាពទន់ខ្សោយនៃការគ្រប់គ្រងសំណល់រាវ និងការតាមដាន ដោយពុំមានទិន្នន័យគ្រប់គ្រាន់
- កង្វះបុគ្គលជំនាញ មូលនិធិមិនគ្រប់គ្រាន់ និងការសំរបសំរួលរវាងវិស័យខុសៗគ្នានៅទន់ខ្សោយ និង
- ដំណើរការនៃកិច្ចការពារបរិស្ថាន ពុំមានគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាកំណើនដល់កំពូលនៃការអភិវឌ្ឍ(សូម្បីតែការចែងអំពីការយកកម្រៃសម្រាប់ការពារបរិស្ថាន ការអនុវត្តនៅទន់ខ្សោយនៅឡើយ)។

ក្នុងចំណោមការប្រឈមទាំងនេះ របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ចទឹកនៅក្នុងវិស័យភូមិសិប្បកម្ម គួរតែរួមបញ្ចូលការកែលម្អដំណើរការនៃកិច្ចការពារបរិស្ថាន ជាពិសេស នៅក្នុងការកំណត់ និងការប្រមូលកម្រៃសម្រាប់ការពារបរិស្ថាន។

៤.៤ ការសន្និដ្ឋាន ឧបសគ្គ និងអនុសាសន៍

៤.៤.១ ឧបសគ្គ

បញ្ហាដែលវិស័យទឹកប្រឈម នៅក្នុងប្រទេសវៀតណាមមានចាប់ពីអវត្តមានទិន្នន័យ រហូតដល់ភាពទន់ខ្សោយខាងនិរន្តរភាពហិរញ្ញវត្ថុ អវត្តមានសិទ្ធិចំពោះទឹក និងការបំពុលទឹកធ្ងន់ធ្ងរ។ គេពុំមានចែងអំពីសិទ្ធិចំពោះទឹកឡើយ ហើយបើទោះជាការចេញអាជ្ញាប័ណ្ណ កំពុងតែឈានទៅអនុវត្តក៏ដោយ គេពុំបានផ្តោតការយកចិត្តទុកដាក់ចំទិសដៅ និងពុំមានប្រសិទ្ធិភាពឡើយ។ មាត្រាដែលចែងអំពីកិច្ចការពារបរិស្ថាននៅខ្វះខាតធ្ងន់ធ្ងរ ដោយសារពុំមានការទទួលស្គាល់ថា ទឹកជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីឡើយ។

គេនៅមានការយល់ដឹងកម្រិតទាបអំពីបញ្ហាទឹក នៅទូទាំងរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ក៏ដូចជាក្នុងចំណោមសហគមន៍ផងដែរ។ ការចូលរួមរបស់សហគមន៍ នៅក្នុងគ្រប់វិស័យនៅមានកម្រិត។ និយាយដោយខ្លី អភិបាលកិច្ចក្នុងវិស័យទឹកសព្វថ្ងៃនេះ ច្រើនតែនិយមវិធានបែបប្រពៃណីជាងវិធាន IWRM។

វិស័យទឹកច្រើនតែគ្របដណ្តប់ដោយក្របខ័ណ្ឌគោលនយោបាយ និងស្ថាប័នដែលនៅដាច់ពីគ្នា ដោយមានគោលនយោបាយជាច្រើន ដែលមានឥទ្ធិពលមកលើវិស័យនេះ និងប្រវត្តិនៃភាពទន់ខ្សោយលើការសម្របសម្រួលក្នុងចំណោមក្រសួងនានា ដូចជា MARD, MRNRE MoC, និង MoH។ លើសពីនេះ ការបន្សុីគ្នាជាមួយគោលនយោបាយធំទូលាយនៅថ្នាក់លើ ការអភិវឌ្ឍសេដ្ឋកិច្ច និងគោលនយោបាយកែទម្រង់ស្ថាប័ននៅពុំទាន់គ្រប់គ្រាន់ឡើយ។ ជាផលវិបាក ការអភិវឌ្ឍលើការងារគ្រប់គ្រងទឹក ជានិច្ចជាកាលមិនបានផ្តល់ផលសម្រាប់រយៈពេលវែងឡើយ។

ទោះជាយ៉ាងណាក៏ដោយ មានការវិនិយោគទ្រង់ទ្រាយធំលើសេវាកម្មទឹក និងនៅក្នុងវិស័យជាច្រើន ដូចជា ការស្រោចស្រព កិច្ចការពារពីទឹកជំនន់ ការអភិវឌ្ឍវារីអគ្គិសនី និងការផ្គត់ផ្គង់ទឹក និងអនាម័យ។ គេមានកិច្ចផ្តួចផ្តើមកែទម្រង់ ដែលរួមទាំងការបង្កើតអង្គការអាងទន្លេ ការណែនាំអំពីការគ្រប់គ្រងការស្រោចស្រពតាមបែបផែននៃការចូលរួម និងអភិវឌ្ឍន៍យុទ្ធសាស្ត្រទឹកនៅថ្នាក់ខេត្ត។ ប៉ុន្តែទំហំនៃកិច្ចប្រឹងប្រែងទាំងនេះមានកម្រិតកំណត់ ហើយឥទ្ធិពលរបស់វាក៏នៅពុំទាន់ស្តែងឱ្យឃើញជាទ្រង់ទ្រាយធំនៅឡើយទេ។

ការប្រឈមចំបងនៃខាងអភិបាលកិច្ចនៅប្រទេសវៀតណាមគឺ

- ក្របខ័ណ្ឌច្បាប់មានភាពត្រួតគ្នា លក្ខន្តិកៈច្រើនរាប់មិនអស់ និងជាញឹកញាប់គ្មានភាពជាក់ស្តែង ដែលធ្វើឱ្យលំបាកអនុវត្ត
- ក្របខ័ណ្ឌច្បាប់ចែកដាច់គ្នាតាមវិស័យ ដែលមិនអើពើអំពីគោលការណ៍ IWRM
- ភាពទន់ខ្សោយនៃការសម្របសម្រួលរវាងក្រសួងនិងទីភ្នាក់ងារ

នានា ដែលនាំឱ្យមានភាពត្រួតគ្នា និងភាពមិនច្បាស់លាស់ក្នុងការកំណត់តួនាទី និងការទទួលខុសត្រូវនៃទីភ្នាក់ងារពាក់ព័ន្ធ និងការអនុវត្តដែលគ្មានប្រសិទ្ធិភាព

- RBOs មិនមានចំណាប់អារម្មណ៍លើអំណាចណាមួយឡើយ ហើយដើរតួត្រឹមតែជាទីភ្នាក់ងារសម្របសម្រួលប៉ុណ្ណោះ
- ពុំមានយន្តការឯកភាពគ្នា ឬសម្របសម្រួល ដើម្បីប្រមូល គ្រប់គ្រង និងចែករំលែកព័ត៌មានរវាងទីភ្នាក់ងារនានាដោយប្រសិទ្ធិភាពឡើយ
- ដោយសារតួនាទីរបស់រដ្ឋាភិបាលមានការផ្លាស់ប្តូរយឺតៗពីជាអ្នកអភិវឌ្ឍន៍និងប្រតិបត្តិការ ទៅជាអ្នកកសាងផែនការ និងនិយ័តករវិញនោះ ទីភ្នាក់ងាររដ្ឋាភិបាលនឹងត្រូវការឱ្យមានជំនាញមួយបែបថ្មី។ គេត្រូវការឱ្យមានការកសាងសមត្ថភាពជាបន្ទាន់ និងអាចត្រូវការឱ្យបែងចែកធនធានមនុស្សឡើងវិញផងដែរ។
- ការយល់ដឹងអំពីបញ្ហាអភិបាលកិច្ចទឹកនៅមានកម្រិតទាបក្នុងចំណោមក្រសួង អាជ្ញាធរ និងមន្ទីរនានានៅថ្នាក់ខេត្ត។ ទីភ្នាក់ងារទាំងនេះខ្លួនឯងមានការយល់ដឹងតិចតួច ឬបានទទួលការបណ្តុះបណ្តាលតិចតួចអំពីការបែងចែក ការអភិវឌ្ឍ និងការគ្រប់គ្រងធនធាន និង
- ថវិកាសំរាប់ប្រតិបត្តិការ និងការថែទាំមិនមានការបែងចែកគ្រប់គ្រាន់ ហើយការយកចិត្តទុកដាក់បានផ្តោតតែលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជាងលើការគ្រប់គ្រង និងអភិបាលកិច្ច។ លើសពីនេះ ការវិនិយោគមិនបានផ្តោតចំទិសដៅឡើយ។

៤.៤.២ អនុសាសន៍

ជារួមបញ្ហាសំខាន់ៗនៃវិស័យទឹកក្នុងប្រទេសវៀតណាមដែលលើកស្នើឡើងសម្រាប់ផ្តោតលើ MWD មានដូចតទៅ :

- ការបំពុលទន្លេ : មានការលើកស្នើថា ការបំពុលដែលបង្កដោយភូមិសិប្បកម្ម គួរតែជ្រើសយកសម្រាប់ការវាយតម្លៃស៊ីជម្រៅ និងដំណើរការពិភាក្សា ដោយផ្តោតលើអនុសាសន៍ជាក់ស្តែងសម្រាប់វិធានការកាត់បន្ថយ
- វិមជ្ឈការ : MWD អាចជួយបាន តាមរយៈការតស៊ូមតិការអភិវឌ្ឍគោលនយោបាយ និងបរិធានខាងស្ថាប័ន ដើម្បីគូសបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវ សិទ្ធិនិងតួនាទីនៃអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់នៅកម្រិតខុសៗគ្នា ចាប់ពីថ្នាក់កណ្តាលមកថ្នាក់ក្រោមបំផុត
- ការប្រើប្រាស់ទឹកដោយសមធម៌ : ជាមួយកំណើនតម្រូវការទឹកក្នុងវិស័យខុសៗគ្នានៃសេដ្ឋកិច្ច ទំនាស់អំពីការបែងចែកទឹកពិតជាមិនអាចជៀសវាងបានឡើយ។ MWD ជាមួយដំណើរការពិគ្រោះយោបល់ជាមួយពហុភាគីអ្នកពាក់ព័ន្ធ អាចជួយសម្រួល និងសម្របសម្រួលឱ្យមានការចរចានានា
- ការផ្គត់ផ្គង់ទឹក និងអនាម័យ : តាមរយៈដំណើរការពិគ្រោះយោបល់ MWD អាចជួយបញ្ជ្រាបបញ្ហាអនាម័យ និងកៀងគរឱ្យមានការចូលរួម និងការវិនិយោគពីវិស័យឯកជននៅក្នុងវិស័យរងនេះ
- ការលើកកំពស់ IWRM: តាមរយៈការសិក្សាករណីនានា ការពិគ្រោះយោបល់ និងដំណើរការជាបន្ត MWD អាចរួមចំណែកនៅក្នុងការអនុវត្តយន្តការលើកទឹកចិត្ត និងវិធាន IWRM ឱ្យដែលមានប្រសិទ្ធិភាព

របៀបវារៈគន្លឹះដែលបានធ្វើអត្តសញ្ញាណសម្រាប់កែលម្អអភិបាលកិច្ចនៅក្នុងវិស័យខុសៗគ្នាដែលទាក់ទងនឹងទឹកដែលបានអង្កេតមានចែងនៅក្នុងតារាងខាងក្រោមនេះ។

តារាងទី ៦.របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច នៅប្រទេសវៀតណាម

វិស័យ	របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ច
វារីអគ្គិសនី	• កែលម្អការកសាងផែនការសហការពហុវិស័យ (នៅទូទាំងអាង និងគោលការណ៍ IWRM) • ការបង្កើតយន្តការពិគ្រោះយោបល់ផ្លូវការសម្រាប់ការចូលរួមដោយប្រសិទ្ធិភាពនៃអ្នកពាក់ព័ន្ធនានាទាំងនៅក្នុង

	ប្រទេស និងឆ្លងព្រំដែន នៅពេលដែលទំនប់នៃប្រទេសវៀតណាម បង្កផលប៉ះពាល់មកលើប្រទេសជិតខាង និងច្រាស់មកវិញ
ការស្រោចស្រព	• ពិនិត្យមើល និងកែទម្រង់ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលរួមទាំងការបញ្ជាក់អំពីអាណត្តិ និងមុខនាទីរបស់ទីភ្នាក់ងារខុសៗគ្នា • កែលម្អការសម្របសម្រួល និងដំណើរការប្រាស្រ័យឆ្លើយឆ្លងនៃ IDMCs • ការទទួលយកកាន់តែទូលាយនូវវិធាន PIM ដោយផ្អែកលើគំរូដែលមានជោគជ័យ
ជលផល និងវារីវប្បកម្ម	• កែទម្រង់សហគ្រាសជលផលរដ្ឋ
ទេសចរណ៍ និងនាវាចរណ៍	• ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ទូលំទូលាយ • ការអភិវឌ្ឍគោលនយោបាយថ្នាក់តំបន់ដើម្បីគាំទ្រដល់នាវាចរណ៍ឆ្លងដែន រវាងវៀតណាម កម្ពុជា និងចិន • កែលម្អយន្តការនៃការចូលរួម
ការផ្គត់ផ្គង់ទឹក និងអនាម័យ	• បង្កើនសង្គត់ភាពនៃគោលនយោបាយសម្រាប់សហគ្រាសផ្គត់ផ្គង់ទឹក និងការដោះទឹក • កែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា • បង្កើតយន្តការសម្រាប់ការពាក់ព័ន្ធរបស់សហគមន៍
ឧស្សាហកម្មនិងភូមិសិប្បកម្ម	• កែលម្អដំណើរការការពារបរិស្ថាន ជាពិសេស ការកំណត់ និងប្រមូលកម្រៃការពារបរិស្ថាន

៥. អនុសាសន៍ និងការសន្និដ្ឋាន

៥.១ បញ្ហាគន្លឹះ

ជារួម ការសិក្សាវិភាគស្ថានភាពនៅកម្ពុជា ឡាវ និងវៀតណាម បង្ហាញឱ្យឃើញច្បាស់ថា ប្រទេសទាំងបីមានការប្រឈមមួយចំនួនលើអភិបាលកិច្ចទឹកដែលត្រូវដោះស្រាយសម្រាប់ការគ្រប់គ្រងដោយនិរន្តរភាព។ លើសពីនេះ ដូចជាប្រទេសដទៃទៀតដែរ ប្រទេសទាំងនេះកំពុងរងគ្រោះពីបញ្ហាអភិវឌ្ឍន៍តាមធម្មតា ដូចជា សម្ពាធយ៉ាងច្រើនមកលើប្រភពទឹកដែលមានក្នុងកម្រិតកំណត់ ដែលបង្កដោយកំណើនតម្រូវការនៃវិស័យនានា ការបំពុលដែលបង្កដោយឧស្សាហូបនីយកម្ម និងការអភិវឌ្ឍទីក្រុង គ្រោះថ្នាក់ដែលបង្កដោយការប្រែប្រួលអាកាសធាតុ និងតម្រូវការជាបន្ទាន់ដើម្បីផ្តល់សេវាកម្មទឹកសម្រាប់ប្រជាពលរដ្ឋដែលមានចំនួនកាន់តែកើនឡើង។

បញ្ហាសាមញ្ញ និងបញ្ហាគន្លឹះ ដែលបានធ្វើការកំណត់សំគាល់ពីការសិក្សានៅប្រទេសទាំងបី គឺមានលំអិតនៅតារាងខាងក្រោម:

តារាងទី ៧. តារាងសង្ខេប - របៀបវារៈសម្រាប់កែលម្អអភិបាលកិច្ច

វិស័យ	របៀបវារៈគន្លឹះសម្រាប់កែលម្អអភិបាលកិច្ច
កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងឆ្លងដែន	• ការបង្កើតយន្តការពិគ្រោះយោបល់ផ្លូវការ សម្រាប់ការចូលរួមដោយប្រសិទ្ធិភាពពីអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចឆ្លងដែន នៅពេលដែលទំនប់ និងការអភិវឌ្ឍដទៃទៀតនៅតំបន់ខ្សែទឹកខាងលើមានផលប៉ះពាល់មកលើធនធានទឹក ជលផល និងការចិញ្ចឹមជីវិតរបស់ប្រទេសជិតខាង។ ប្រព័ន្ធទន្លេបែបនេះ រួមមាន : ♦ ទន្លេមេគង្គ : ទំនប់ដែលមានស្រាប់ និងដែលគ្រោងសាងសង់ក្នុងប្រទេសចិន បង្កផលប៉ះពាល់មកលើប្រទេសទាំងអស់នៅតំបន់ខ្សែទឹកខាងក្រោម ទំនប់ដែលគ្រោងសាងសង់ក្នុងប្រទេសឡាវមានផលប៉ះពាល់មកលើប្រទេសកម្ពុជា និងវៀតណាម ទំនប់ដែលគ្រោងសាងសង់នៅកម្ពុជា មានផលប៉ះពាល់មកលើប្រទេសវៀតណាម ♦ ទន្លេរ៉ែត : ទំនប់ដែលកំពុងសាងសង់/គ្រោងក្នុងប្រទេសចិន មានផលប៉ះពាល់មកលើប្រទេសវៀតណាម ♦ ទន្លេមេគង្គ : ទំនប់ដែលគ្រោងសង់ក្នុងប្រទេសឡាវ មានផលប៉ះពាល់មកលើប្រទេសកម្ពុជា និង ♦ ទន្លេស្រែពក និងសេសាន : ទំនប់ដែលមានសព្វថ្ងៃ និងដែលគ្រោងក្នុងប្រទេសវៀតណាម មានផលប៉ះពាល់មកលើប្រទេសកម្ពុជា • ការអភិវឌ្ឍគោលនយោបាយថ្នាក់តំបន់សម្រាប់នាវាចរណ៍ឆ្លងដែន រវាងវៀតណាម-កម្ពុជា និងចិន-ឡាវ (ទន្លេមេគង្គ) ចិន-វៀតណាម (ទន្លេរ៉ែត)
ការកសាងផែនការអាងទន្លេទាំងមូល និងវិធាន IWRM/IRBM	• កំណើនការយកចិត្តទុកដាក់លើកំណែលម្អគោលនយោបាយ និងការអនុវត្ត SEA។ ជាពិសេស កែលម្អនៅក្នុងប្រទេសវៀតណាម លើការកសាងផែនការសហប្រតិបត្តិការពហុវិស័យនៅកម្រិតអាងទន្លេ ដោយផ្អែកលើគោលការណ៍នានានៃ IWRM គឺជាប្រការចាំបាច់។ ចំណែកនៅប្រទេសឡាវ ប្រការចាំបាច់គឺត្រូវធ្វើឱ្យមានកំណែលម្អនូវកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារនានានៃរដ្ឋាភិបាល ជាពិសេស WREA និង MEM
វារីអគ្គិសនី	• ការបង្កើតយន្តការដែលមានតម្លាភាព និងស្ថាប័នប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាឱ្យមានការអភិវឌ្ឍ សមស្របនៃវិស័យវារីអគ្គិសនី។ ដោយឡែកសម្រាប់ប្រទេសនីមួយៗ : ♦ វៀតណាម - ការបង្កើតយន្តការពិគ្រោះយោបល់ផ្លូវការសម្រាប់ការចូលរួមនៃអ្នកពាក់ព័ន្ធនានាឱ្យមានប្រសិទ្ធិភាព និងការបង្កើតស្តង់ដារ និងការកែលម្អទម្លាប់អនុវត្ត ដែលទាក់ទងនឹង SEAs និង CIAs នៅក្នុងវិស័យវារីអគ្គិសនី ♦ ឡាវ - ពង្រឹងការពិនិត្យមើលសំណើនានា និងកិច្ចសន្យាសម្បទាន ការគ្រប់គ្រង និងតាមដានដំណើរការផ្តល់សម្បទាននៅក្នុង DEDP/MEM ពង្រឹងការិយាល័យ EIA អំពី MREA និងធានាថា គោលនយោបាយ

	ជាតិ និងនិរន្តរភាពបរិស្ថាន និងសង្គមនៃវិស័យវារីអគ្គិសនីនៅប្រទេសឡាវ ត្រូវបានអនុវត្តពេញលេញ ជាពិសេស មាត្រានានាដែលទាក់ទងនឹងការបើកចំហព័ត៌មាន និងការពិគ្រោះយោបល់ និង ♦ កម្ពុជា - កសាងគោលនយោបាយ គោលការណ៍ណែនាំ និងក្របខ័ណ្ឌច្បាប់សម្រាប់អភិវឌ្ឍន៏វារីអគ្គិសនី កំណើនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័ន/អ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមទាំងសហគមន៏/វិស័យឯកជន កំណើនព័ត៌មាន ដែលទាក់ទងនឹងផលប៉ះពាល់នៃការអភិវឌ្ឍវារីអគ្គិសនី និង សំណើគ្រប់គ្រង និងវិធានការនានា ដើម្បីកាត់បន្ថយហានិភ័យ និងផ្តល់ឱកាសកាន់តែច្រើនសម្រាប់ការពិភាក្សាជាសាធារណៈ
ការស្រោចស្រព	• ការពិនិត្យ ការបញ្ជាក់និងការពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ជាពិសេស សម្រាប់ប្រទេសនីមួយៗ : ♦ ប្រទេសវៀតណាម — ពិនិត្យមើល និងកែទម្រង់ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលរួមទាំងការគូសបញ្ជាក់អំពីអាណត្តិ និងមុខនាទីនៃទីភ្នាក់ងារខុសៗគ្នា ការកែលម្អលើការសម្របសម្រួល IDMC និងដំណើរការប្រាស្រ័យទាក់ទង និងការលើកទឹកចិត្តឱ្យមានការទទួលយកកាន់តែច្រើនឡើងនូវវិធាននានានៃ PIM ដោយផ្អែកលើមេរៀនពីគំរូដែលមានជោគជ័យ ♦ ប្រទេសឡាវ - ពង្រឹងការពាក់ព័ន្ធរបស់កសិករនៅក្នុងការកសាងផែនការដែលផ្អែកលើតម្រូវការនៅមូលដ្ឋាននៅក្នុងការអភិវឌ្ឍវារីអគ្គិសនី និងការបង្កើតយន្តការនានា ដើម្បីបង្កើនផលចំណូលដោយ និរន្តរភាពសម្រាប់ប្រតិបត្តិការ និងការថែទាំ និង ♦ កម្ពុជា - ការចែងបញ្ជាក់អំពីសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងអ្នកប្រើប្រាស់ (ដែលរួមទាំងការអនុម័តឯកភាពអំពីសិទ្ធិចំពោះទឹក) ពង្រឹងស្ថានភាពចំពោះមុខច្បាប់នៃ FWUGs និងសម្រួលឱ្យមានការចូលរួមកាន់តែច្រើនឡើងពីកសិករនៅក្នុងការកសាងផែនការនិងការគ្រប់គ្រងការស្រោចស្រព
ជលផល និងវារីវប្បកម្ម	របៀបវារៈគន្លឹះសម្រាប់ប្រទេសនីមួយៗ : • វៀតណាម - កែទម្រង់សហគ្រាសជលផលរដ្ឋ • ឡាវ - ការអនុម័តសេចក្តីព្រាងច្បាប់ជលផល ដែលទទួលស្គាល់អំពីការចាត់ចែងដោយផ្អែកលើសហគមន៏/សហគ្រប់គ្រងសម្រាប់ការគ្រប់គ្រងជលផល និង • កម្ពុជា - កែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា ការកែលម្អលើការអនុវត្តច្បាប់ និងការដោះស្រាយអំពើពុករលួយ ។
នាវាចរណ៍ និង ទេសចរណ៍	របៀបវារៈគន្លឹះសម្រាប់ប្រទេសនីមួយៗ : • វៀតណាម - រៀបចំក្របខ័ណ្ឌច្បាប់ទូលំទូលាយ និងកែលម្អយន្តការនៃការចូលរួមដើម្បីអភិវឌ្ឍនាវាចរណ៍ • ឡាវ - ការបង្កើតយន្តការសម្រាប់ពិគ្រោះយោបល់ជាមួយសហគមន៏រងគ្រោះ អំពីប្រព័ន្ធកែលម្អនាវាចរណ៍ • កម្ពុជា - កែលម្អការសម្របសម្រួលស្ថាប័ន និងគោលនយោបាយ ការគូសបញ្ជាក់អំពីព្រំដែននៃការទទួលខុសត្រូវក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល ពង្រឹងស្ថាប័នសហគមន៏មូលដ្ឋានសម្រាប់ការគ្រប់គ្រងទេសចរណ៏ និងពង្រឹងអំណាចចរចាជាមួយប្រតិបត្តិករទេសចរណ៏ជាលក្ខណៈពាណិជ្ជកម្ម និងការបង្កើតយន្តការចែកផលឱ្យច្បាស់លាស់ ។
ការផ្គត់ផ្គង់ទឹក និងអនាម័យ	របៀបវារៈគន្លឹះសម្រាប់ប្រទេសនីមួយៗ : • វៀតណាម — បង្កើនសង្គត់ភាពនៃគោលនយោបាយសម្រាប់សហគ្រាសផ្គត់ផ្គង់ទឹក និងដោះទឹក កែលម្អការសម្របសម្រួលរវាងទីភ្នាក់ងារខុសៗគ្នា និងបង្កើតយន្តការល្អជាងមុនសម្រាប់បង្កើនការពាក់ព័ន្ធនៃសហគមន៏ • ឡាវ - ការបង្កើត WSUGs ការបង្កើតយន្តការ ដំណើរការនានា និងការលើកទឹកចិត្តច្បាស់លាស់ សម្រាប់ការ

ចូលរួមរបស់អ្នកពាក់ព័ន្ធនានាឱ្យបានច្រើនជាងមុន ជាពិសេស ក្រុមក្រីក្រជាងគេ និងការបង្កើតឱកាសសម្រាប់ការពាក់ព័ន្ធកាន់តែច្រើនឡើងនៃវិស័យឯកជន និង

- កម្ពុជា - កែលម្អទំនាក់ទំនងអន្តរក្រសួង ការគូសបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (WSUGs) ការបង្កើតយន្តការ ដំណើរការ និងការលើកទឹកចិត្តច្បាស់លាស់ សម្រាប់ការចូលរួមនៃអ្នកពាក់ព័ន្ធកាន់តែច្រើនជាងមុន ជាពិសេស ក្រុមអ្នកក្រីក្រជាងគេ និងការបង្កើតឱកាសសម្រាប់ការពាក់ព័ន្ធកាន់តែច្រើនឡើងនៃវិស័យឯកជន។

ឧស្សាហកម្ម និងភូមិសិប្បកម្ម	របៀបវារៈគន្លឹះសម្រាប់ប្រទេសវៀតណាម : • កែលម្អដំណើរការកិច្ចការពារបរិស្ថាន ជាពិសេស ការបង្កើត និងប្រមូលកម្រៃសម្រាប់ការពារបរិស្ថាន។

ការសន្និដ្ឋានទូទៅសំខាន់បំផុតមានដូចតទៅ:

១. ការគ្រប់គ្រងធនធានទឹក នាំមុខដោយតម្រូវការតាមវិស័យ និងពុំមានភាពចម្រុះ

គោលការណ៍នានានៃការគ្រប់គ្រងចម្រុះធនធានទឹក (IWRM) បានការទទួលស្គាល់ និងដាក់ឱ្យអនុវត្តនៅពេលថ្មីៗនេះ និងមានការអនុវត្តត្រឹមកម្រិតកំណត់ប៉ុណ្ណោះមកទល់សព្វថ្ងៃនេះ។

- អង្គការអាងទន្លេត្រូវបានបង្កើតឡើងសម្រាប់ទន្លេមួយចំនួនតូចនៅក្នុងប្រទេសទាំងបី ហើយបទពិសោធន៍ និងប្រសិទ្ធិភាពរបស់ពួកគេមកទល់ពេលនេះនៅមានកម្រិតកំណត់នៅឡើយ។
- ការវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន (SEAs) ទើបតែបានចាប់ផ្តើមប្រើប្រាស់ ជាឧបករណ៍សម្រាប់គាំទ្រឱ្យមានការកសាងផែនការចម្រុះកាន់តែច្រើនឡើងនៅក្នុងអាងទន្លេ។ ស្តង់ដារសម្រាប់ SEAs ត្រូវតែបង្កើតឡើង និងកែលម្អការអនុវត្ត

២. ក្នុងពេលដែលកំណែលម្អគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ត្រូវបានផ្តួចផ្តើមឡើងនៅក្នុងវិស័យជាច្រើន គេឃើញមានគម្លាតដែលត្រូវការដោះស្រាយ ហើយនៅក្នុងគ្រប់ករណីទាំងអស់ដំណើរការបម្លែងច្បាប់នានាទៅជាសកម្មភាពទើបតែបានចាប់ផ្តើមហើយទាមទារឱ្យមានការកែលម្អជាបន្ថែម។

- ប្រទេសឡាវ ពុំមានគោលការណ៍រួមនៃគោលនយោបាយជាតិស្តីពីទឹកឡើយ ដែលកំណត់អំពីថាតើរដ្ឋាភិបាលចង់អភិវឌ្ឍន៍ និងគ្រប់គ្រងទឹកបែបណា
- ប្រទេសវៀតណាមពុំមានគោលនយោបាយច្បាស់លាស់សម្រាប់ទិដ្ឋភាពជាច្រើននៃការគ្រប់គ្រងទឹក ដូចជា ការលៃលក/ការបែងចែកទឹកនៅក្នុងពេលរាំងស្ងួត លំហូរបរិស្ថាន និងទន្លេដែលមិនទាន់រងការខូចខាត។ ផ្ទុយទៅវិញ នៅប្រទេសកម្ពុជាមានគោលនយោបាយជាតិទូលំទូលាយអំពីធនធានទឹកឆ្នាំ 2004 ប៉ុន្តែច្បាប់នេះ នៅតែមានកង្វះចន្លោះ ដែលទាមទារឱ្យមានការកែលម្អ។
- វៀតណាម និងឡាវ សុទ្ធតែមានច្បាប់ស្តីពីធនធានទឹក (1998 នៅវៀតណាម និងឆ្នាំ 1999 នៅឡាវ) ដែលត្រូវការឱ្យមានការកែសម្រួល និងធ្វើបច្ចុប្បន្នភាព ចំណែកកម្ពុជាមានច្បាប់ទំនើបជាងស្តីពីការគ្រប់គ្រងទឹក (2007) ដែលមានលក្ខណៈទូលំទូលាយជាង។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសទាំងបីគ្មានច្បាប់ណាមួយ ដែលចែងច្បាស់លាស់អំពីសិទ្ធិរបស់អ្នកប្រើប្រាស់ទឹកឡើយ។
- ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីត្រូវកែលម្អនៅក្នុងប្រទេសទាំងបី។ នៅក្នុងគ្រប់ករណីទាំងអស់ ការបើកចំហព័ត៌មាន និងការផ្សព្វផ្សាយពត៌មាន និងការចូលរួមនៃអ្នកពាក់ព័ន្ធ ដែលរងគ្រោះនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច សុទ្ធតែត្រូវឱ្យមានការកែលម្អ។
- បើទោះកម្ពុជាមានគោលនយោបាយជាតិវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ (2004) ក៏ដោយ ប្រទេសនេះនៅត្រូវការឱ្យបង្កើតយុទ្ធសាស្ត្ររួម ដើម្បីអនុវត្តគោលនយោបាយ ហើយនៅត្រូវអនុម័តច្បាប់ស្តីពីការផ្គត់ផ្គង់ទឹក និងអនាម័យ។
- ច្បាប់ជលផល(2006) និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ នៅកម្ពុជាផ្តល់ជាមូលដ្ឋានដ៏ល្អ សម្រាប់ដោះស្រាយបញ្ហាគ្រប់គ្រង

ជលផលទឹកសាប ចំណែកប្រទេសឡាវមានសេចក្ដីព្រាងច្បាប់ជលផល(2009)កំពុងស្ថិតក្រោមការពិចារណា។ ច្បាប់ជលផលនៅប្រទេសឡាវនឹងផ្ដល់ជាលើកដំបូងនូវមូលដ្ឋានច្បាប់សម្រាប់ការចាត់ចែងសហគ្រប់គ្រងរវាងសហគមន៍ និងទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន។ នៅវៀតណាម សហគ្រាសជលផលរដ្ឋកំពុងត្រូវការកែទម្រង់ជាបន្ទាន់។

៣. ក្នុងវិស័យរងជាច្រើនដែលទាក់ទងនឹងទឹក តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង និងទីភ្នាក់ងារនានា នៅពុំទាន់មានចែងច្បាស់លាស់ ដែលនាំឱ្យគ្មានការកំណត់អំពីគណនេយ្យភាព និងគ្មានភាពច្បាស់លាស់ចំពោះទីភ្នាក់ងារណាមួយឡើយ។ ការសម្របសម្រួលរវាងក្រសួង និងទីភ្នាក់ងារនានា ក៏នៅខ្វះខាតផងដែរ ដូច្នេះការអនុវត្តគោលនយោបាយ ប្រព័ន្ធនិងកម្មវិធី គឺពុំមានប្រសិទ្ធិភាព។

- ការសម្របសម្រួលរវាងទីភ្នាក់ងាររដ្ឋាភិបាល និងអ្នកដើរតួដទៃទៀត ដូចជា NGOs ទីភ្នាក់ងារផ្ដល់ជំនួយ វិស័យឯកជន និងសហគមន៍ នៅខ្វះខាតនៅឡើយ
- គេនៅពុំទាន់មានការប្រមូលនិងការគ្រប់គ្រងទិន្នន័យគ្រប់គ្រាន់នៅឡើយទេ ចំណែកការចែករំលែកព័ត៌មាន ក៏ដូចជា ការផ្លាស់ប្ដូរព័ត៌មាន គឺជាដំណើរការសាំញ៉ាំ និងស្មុគស្មាញ។ ប្រការនេះកាន់តែសាំញ៉ាំដោយសារកង្វះបុគ្គលិកជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ និងតម្រូវការជាបន្ទាន់ឱ្យមានការកសាងសមត្ថភាពជាពិសេសនៅក្នុងប្រទេសឡាវ និងកម្ពុជា។

៤. ការចូលរួមរបស់សហគមន៍ និងអ្នកពាក់ព័ន្ធនៅមានកម្រិតកំណត់ ហើយជាទូទៅមានការយល់ដឹងទាប ដែលទាក់ទងនឹងការគ្រប់គ្រងទឹក និងបញ្ហាអភិបាលទឹក ក្នុងចំណោមទាំងសហគមន៍ និងមន្ត្រីរដ្ឋាភិបាល

- នៅក្នុងវិស័យស្រោចស្រពនៅកម្ពុជា គេត្រូវពង្រឹងគណៈកម្មាការកសិករប្រើប្រាស់ទឹក (FWUC) ដើម្បីកែលម្អការចូលរួមរបស់កសិករ ចំណែកការសម្របសម្រួល និងការប្រាស្រ័យឆ្លើយឆ្លងរវាងក្រុមហ៊ុនស្រោចស្រព និងគ្រប់គ្រងការដោះទឹកនៅប្រទេសវៀតណាមនៅត្រូវការឱ្យកែលម្អ និងត្រូវផ្ដល់ការលើកទឹកចិត្ត ដើម្បីឱ្យអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងការស្រោចស្រពតាមបែបផែននៃការចូលរួម (PIM) ជាបន្ថែមទៀត។ នៅប្រទេសឡាវ គេត្រូវតែរកឃើញផងដែរនូវវិធីដើម្បីធ្វើឱ្យកសិករបានចូលរួមនៅក្នុងការកសាងផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ។
- ក្នុងការផ្គត់ផ្គង់ទឹក និងអនាម័យ ប្រទេសកម្ពុជាត្រូវបញ្ជាក់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (WSUG) ចំណែកក្រុមប្រហែលគ្នានេះ ត្រូវតែបង្កើតឡើងនៅក្នុងប្រទេសឡាវ។ នៅប្រទេសវៀតណាម យន្តការសម្រាប់បង្កើនការចូលរួមរបស់សហគមន៍ លើការផ្គត់ផ្គង់ទឹក និងអនាម័យ ក៏ត្រូវតែបង្កើតឡើងផងដែរ
- ក្នុងផ្នែកវារីអគ្គិសនី យន្តការនានាដើម្បីធ្វើឱ្យសហគមន៍អ្នករងគ្រោះពាក់ព័ន្ធនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេច ជាពិសេសទាក់ទងនឹងគម្រោងនានា ដែលមានផលប៉ះពាល់ឆ្លងដែនមកលើសហគមន៍នៅខ្សែទឹកខាងក្រោម។
- ក្នុងផ្នែកនាវាចរណ៍ និងទេសចរណ៍ ត្រូវបង្កើតយន្តការនានាសម្រាប់ពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះតាមរយៈប្រព័ន្ធកែលម្អនាវាចរណ៍ និងត្រូវកែលម្អការបែងចែកផលផងដែរ។

៥.២ អនុសាសន៍សម្រាប់ *MWD*

ការលំបាកទាក់ទងនឹងទឹកដែលកំពុងប្រឈមចំពោះប្រទេសកម្ពុជា ឡាវ និងវៀតណាមមានភាពខុសគ្នា ប៉ុន្តែទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។ ការដោះស្រាយបញ្ហាលំបាកទាំងនេះ ទាមទារមិនត្រឹមតែឱ្យមានការកែលម្អដំណើរការធ្វើសេចក្ដីសម្រេចរវាងអ្នកដើរតួខុសៗគ្នានៅក្នុងរដ្ឋ និងក្រៅរដ្ឋនៅក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការកែលម្អលំហូរព័ត៌មាននៅក្នុងតំបន់មេគង្គទាំងមូលផងដែរ និងត្រូវធានាថា ការសម្រេចនានានៃប្រទេសនីមួយៗ បានពិចារណានូវការអភិវឌ្ឍទូទាំងតំបន់ឱ្យបានទូលំទូលាយ។

ផ្អែកលើរបាយការណ៍ស្ថានភាពពីប្រទេសនីមួយៗ ទីប្រឹក្សាជាតិ បានលើកអនុសាសន៍ដំបូងដូចតទៅ សម្រាប់បញ្ហានានាដែល MWD គួរតែអនុវត្តនៅក្នុងឆ្នាំ 2009 និង 2010:

ចំពោះកម្ពុជា MWD គួរផ្ដោតលើ IWRM ជាវិធានរួមមួយ

សម្រាប់ការអភិវឌ្ឍទឹកដោយសមធម៌ និងនិរន្តរភាព និងធ្វើការងារកាន់តែល្អិតអំពីបញ្ហាអភិបាលកិច្ច ដែលទាក់ទងនឹង :

- ការគ្រប់គ្រងធនធានជលផល
- ការអភិវឌ្ឍវារីអគ្គិសនី និងការគ្រប់គ្រងផលប៉ះពាល់ និង
- ការកសាងផែនការ និងគ្រប់គ្រងការស្រោចស្រព

ចំពោះប្រទេសឡាវ មានការលើកស្នើថា MWD គួរផ្តោតការយកចិត្តទុកដាក់ជារួមលើការគាំទ្រដល់កំណែទម្រង់សព្វថ្ងៃ នៅក្នុងវិស័យទឹក ដែលដំណើរការកែលម្អអភិបាលកិច្ចទឹក កំពុងស្ថិតក្រោមការពិចារណា។ ការពិភាក្សាអំពីគោលនយោបាយទឹក និងយុទ្ធសាស្ត្រជាតិ ដែលកំណត់អំពីទិសដៅសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក និងការទទួលស្គាល់គោលការណ៍នានាអំពីការគ្រប់គ្រងចម្រុះធនធានទឹកគួរតែជាអាទិភាពដំបូង។

ចំពោះប្រទេសវៀតណាម បញ្ហាសំខាន់ៗជាអាទិភាពដែលបានលើកស្នើនៅក្នុង MWD គឺ :

- ការបំពុល - ដែលបង្កដោយសកម្មភាពសិប្បកម្មនៅក្នុងភូមិនានា គួរត្រូវបានជ្រើសរើសសំរាប់ការវាយតម្លៃដោយស៊ីជម្រៅ ហើយដំណើរការពិគ្រោះយោបល់ គួរផ្តោតលើអនុសាសន៍ជាក់ស្តែងដើម្បីលើកវិធានការកាត់បន្ថយ
- វិមជ្ឈការ - MWD គួរតែជួយកំណត់បានច្បាស់លាស់នូវការទទួលខុសត្រូវ សិទ្ធិ តួនាទីរបស់អាជ្ញាធរ និងអ្នកពាក់ព័ន្ធនានានៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់កណ្តាល ដល់ថ្នាក់ក្រោមបំផុត
- ការប្រើប្រាស់ទឹកដោយសមធម៌ - MWD អាចជួយសម្រួល និងសម្របសម្រួលឱ្យមានការចរចា ដើម្បីដោះស្រាយទំនាស់នៃការប្រើប្រាស់ទឹកនៅក្នុងវិស័យជាក់លាក់នានា
- ការផ្គត់ផ្គង់ទឹក និងអនាម័យ - MWD អាចជួយបញ្ជ្រាបបញ្ហាអនាម័យ និងក្បៀងគរឱ្យមានការចូលរួម និងការវិនិយោគពីវិស័យឯកជននៅក្នុងវិស័យរងនេះ និង
- លើកកំពស់ IWRM – តាមរយៈការកំណត់ករណីសិក្សា ការពិគ្រោះយោបល់និងដំណើរការជាបន្ត MWD អាចជម្រុញការអនុវត្តវិធាន IWRM ដែលមានលក្ខណៈច្នៃប្រឌិត និងប្រកបដោយប្រសិទ្ធិភាព។

អនុសាសន៍ដំបូងរបស់ទីប្រឹក្សា ត្រូវបានពិភាក្សាជាបន្ថែមនៅក្នុងការប្រជុំនៃអ្នកពាក់ព័ន្ធនានានៅក្រុងហេ (វៀតណាម)ក្នុងខែធ្នូ ឆ្នាំ2008 នៅ ប៉ាក់សេ (ឡាវ) ខែមករា ឆ្នាំ2009 និងសៀមរាប (កម្ពុជា) ខែកុម្ភៈ ឆ្នាំ2009។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងនេះ បានគាំទ្រដល់អនុសាសន៍របស់ទីប្រឹក្សា។ នៅក្នុងករណីប្រទេសឡាវ អ្នកពាក់ព័ន្ធនានាបានធ្វើអត្តសញ្ញាណតម្រូវការដើម្បីបញ្ចូលការស្រោចស្រព និងវារីអគ្គិសនីនៅក្នុងការយកចិត្តទុកដាក់ជារួម លើកំណែទម្រង់វិស័យទឹក។

វារីអគ្គិសនី និងជាពិសេស ទិដ្ឋភាពអភិបាលកិច្ចទឹក ដែលទាក់ទងនឹងផលប៉ះពាល់ឆ្លងដែនត្រូវបានធ្វើអត្តសញ្ញាណជាអាទិភាពមួយនៅក្នុងរបាយការណ៍របស់ទីប្រឹក្សាពីកម្ពុជា ហើយដូចមានកត់សំគាល់នៅក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅក្នុងប្រទេសឡាវ។ សព្វថ្ងៃនេះ គម្រោងវារីអគ្គិសនីដែលបានលើកស្នើដើម្បីសាងសង់នៅលើដងទន្លេមេគង្គ បានទទួលការយកចិត្តទុកដាក់ជាពិសេស ពីសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ហើយនៅទូទាំងឆមាសទីពីរឆ្នាំ 2009 និងដើមឆ្នាំ 2010 គណៈកម្មការទន្លេមេគង្គកំពុងធ្វើការសិក្សា SEA នៃវារីអគ្គិសនីនៅលើដងទន្លេ។ ការអនុវត្ត SEA តាមរយៈជំនួយពីទីប្រឹក្សាជំនាញនឹងផ្តល់ផងដែរនូវឱកាសសំរាប់ជួយកសាងសមត្ថភាពរបស់ទីភ្នាក់ងាររបស់ជាតិនៅក្នុង ការអនុវត្ត SEAs។ វិធានល្អបំផុតសម្រាប់ MWD គឺត្រូវចូលរួមនៅក្នុងដំណើរការនេះ និងផ្តល់គំនិត/បន្ថែមតម្លៃទៅក្នុងដំណើរការនេះស្របពេលនឹងការរៀនសូត្រពីបទពិសោធន៍អំពី SEA ជាជាងធ្វើការសិក្សាវារីអគ្គិសនីដាច់ដោយឡែក។ មេរៀនទទួលបានពី SEA នេះ អាចយកទៅអនុវត្តនៅក្នុងទន្លេអន្តរជាតិធំៗផ្សេងទៀតនៅក្នុងតំបន់មេគង្គ ដែលរួមទាំងទន្លេរ៉ែត និងអាងទន្លេទូសាល់វីន ផងដែរ។

នៅក្នុងប្រទេសទាំងបី ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា បានជួយជ្រើសរើសបញ្ហាអាទិភាពចំបងចំនួនពីរសម្រាប់ ប្រទេសនីមួយៗនៅក្នុងឆ្នាំ 2009។ ផ្អែកលើអនុសាសន៍ពីការសិក្សាវិភាគស្ថានភាពក្នុងប្រទេសទាំងបី និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងបីលើកសកម្មភាពគន្លឹះនានាដែលបានលើកស្នើឱ្យ អនុវត្តនៅក្រោម MWDសម្រាប់ឆ្នាំ 2009 និង 2010 មានដូចតទៅ:

- ការពិនិត្យមើលការអនុវត្តវិធាន IWRM នៅក្នុងការអភិវឌ្ឍ និងអនុវត្តកម្មវិធី និងសកម្មភាពគម្រោងនៅជុំវិញបឹងទន្លេសាប នៅប្រទេសកម្ពុជា និងតួនាទីរបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួលសកម្មភាពនានា និងការពាក់ព័ន្ធរបស់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន ដោយបន្តការពិគ្រោះយោបល់អំពីវិធាន IWRM នៅក្នុងការគ្រប់គ្រងបឹងទន្លេសាប។
- ការវាយតំលៃបញ្ហាគ្រប់គ្រងធនធានជលផល ក្នុងចំណោមសហគមន៍មូលដ្ឋាន នៅជុំវិញបឹងទន្លេសាប ដោយបន្តការពិគ្រោះយោបល់ជាមួយប្រជានេសាទ ដើម្បីឱ្យមានការកែលម្អការគ្រប់គ្រងជលផល
- ករណីសិក្សាលំអិតស្តីពីការស្រោចស្រពនៅក្នុងប្រទេសឡាវ ដោយផ្តោតលើអាងទន្លេណាំខាន់ បន្តការពិគ្រោះយោបល់នៅថ្នាក់ជាតិស្តីពីការស្រោចស្រពនៅក្នុងប្រទេសឡាវ
- ការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃវិស័យកសិកម្ម នៅវៀតណាម ស្តីពីគុណភាពទឹក និងការពិគ្រោះយោបល់នៅថ្នាក់ជាតិស្តីពីអនុសាសន៍សម្រាប់កំណែលម្អអភិបាលកិច្ច និងកាត់បន្ថយការបំពុល និង
- សិក្ខាសាលាមួយជាមួយ"សហគមន៍ជាម្ចាស់ចំណេះដឹង"ដើម្បីអភិវឌ្ឍន៍"ចំណេះដឹងថ្មីៗ"និងអនុសាសន៍ខាងគោលនយោបាយស្តីពីវិមជ្ឈការ និងអភិបាលកិច្ចនៅក្នុងដែនដីសណ្តមេគង្គ ដោយបន្តការប្រជុំពិគ្រោះយោបល់អំពីគោលនយោបាយ ដើម្បីលើកទឹកចិត្តឱ្យមានការទទួលយកអនុសាសន៍នានា។

ស្របនឹងការពិភាក្សាខាងលើអង្គការIUCN បានធ្វើអត្តសញ្ញាណសកម្មភាពជាអាទិភាពសម្រាប់ MWD នៅឆ្នាំ 2009 :

- ការបោះពុម្ពផ្សាយសៀវភៅរូបថតអំពីតំបន់ ស៊ីផាន់ដុន ជាភាសាអង់គ្លេស ឡាវ និងថៃ និងការពិគ្រោះយោបល់អំពីគោលនយោបាយ ស្តីពីសក្តានុពលសម្រាប់កំណត់ជាតំបន់រ៉ាមសារ បេតិកភណ្ឌពិភពលោក ឬ កម្មវិធីមនុស្ស និងជីវមណ្ឌលសម្រាប់តំបន់នេះ
- ពិនិត្យមើលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៃប្រទេសកម្ពុជា ដើម្បីគូសបញ្ជាក់ពីមេរៀនដែលទទួលបានជោគជ័យ ដែលអាចអនុវត្តនៅកន្លែងដទៃ
- ករណីសិក្សាថ្នាក់តំបន់ស្តីពីការស្រោចស្រព នៅប្រទេសថៃ វៀតណាម កម្ពុជា និងឡាវ ហើយនិង
- ការរៀបចំបោះពុម្ពផ្សាយស្តីពីការគ្រប់គ្រង និងអភិបាលកិច្ចតំបន់ដីសើមនៅក្នុងអាងទន្លេមេគង្គ ដោយមានជំពូកនានារួមវិភាគទានពីអ្នកនិពន្ធនានា។

នៅក្នុងផែនការការងារសម្រាប់ឆ្នាំ 2009 និង 2010, MWD នឹងបន្តសម្រួលឱ្យមានការពិគ្រោះយោបល់កាន់តែច្រើនឡើងថែមទៀតរវាងដៃគូខុសគ្នានៅក្នុងរដ្ឋ និងក្រៅរដ្ឋ ដោយចូលរួមមកពីប្រទេសក្នុងទន្លេមេគង្គ ក្នុងពេលដែលពួកគេធ្វើការឈានទៅរកការកែលម្អការគ្រប់គ្រងទឹក និងដំណើរការអភិបាលកិច្ច ដោយគិតបញ្ចូលអំពីការបន្តកំណើនសេដ្ឋកិច្ច ទន្ទឹមនឹងការរក្សាគុណតម្លៃខាងអេកូឡូស៊ីនៃប្រព័ន្ធទន្លេ និងធនធានក្នុងទឹក។

ទីបញ្ចប់ បើពិនិត្យមើលឱ្យហួសពីតារាងដែលបង្ហាញយ៉ាងច្រើនរួចមកហើយអំពីសកម្មភាពជាអាទិភាពនៃ MWD ដែលកើតចេញពីការពិនិត្យស្ថានភាពនេះ គេនៅត្រូវការប៉ាន់ប្រមាណនិងផ្សព្វផ្សាយអំពីថាតើ MWD នឹងត្រូវផ្តោតការយកចិត្តទុកដាក់ដែរឬទេ និងយកចិត្តទុកដាក់បែបណាទៅអនាគត ចំពោះទិដ្ឋភាពនានានៃការអភិបាលកិច្ច ដែលទាក់ទងនឹងប្រធានបទសំខាន់ៗបន្ថែមទៀត លើការគ្រប់គ្រងទឹកក្រោមដី លំហូរបរិស្ថាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ឯកសារយោង

3s River Protection Network, (2007). *Abandoned villages along the Sesan River in Ratanakiri Province, Northeastern Cambodia*. 3s River Protection Network, Ratanakiri, Cambodia.

Australian Mekong Resource Centre, (2002). *Hydropower development in the Se San Watershed*. Australian Mekong Resource Centre, Sydney, Australia.

Cacaud, P. and Latdavong, P. (2008). *Fisheries and Aquaculture in the Lao PDR - A legislative Review.* FAO, Bangkok, Thailand.

Government of Lao PDR, (2004). *National Growth and Poverty Eradication Strategy*, Vientiane, Lao PDR

Kellogg Brown and Root Pty Ltd, (2008). *VIE Water Sector Review Project: Draft Final Report,* Kellogg Brown and Root Pty Ltd, South Australia, Australia

Kurien, J, So, N. and Mao, S.O. 2006. *Cambodia's Aquarian Reforms: The Emerging Challenges for Policy and Research*. Inland Fisheries Research and Development Institute, Phnom Penh, Cambodia.

Mekong River Commission Secretariat, (2004). *The MRC Basin Development Plan*: *National Water Sector Review*.

Middleton, C. and Sam, C. (2008). *Hydropower development in Cambodia and Chinese involvement*. International Rivers, Berkeley, California.

NGO Forum on Cambodia, (2005). *Down River: The consequences of Vietnam's Se San River dam on life in Cambodia and their meaning in international law*. NGO Forum on Cambodia, Phnom Penh, Cambodia.

NIS, (2006). *Statistical Year Book 2006*. National Institute of Statistic, Ministry of Planning, Royal Government of Cambodia, Phnom Penh, Cambodia.

Pongkhao, S. (2009). *Fishery law to tackle fish decline*. Vientiane Times (July 6, 2009)

Sam, C. (2006). "Cambodia water resources development: A review of existing policy and legislation framework." in Robert A.R. Oliver, Moore, P. and Lazarus, K. (eds), *Mekong Region Water Resources Decision-making: National policy and legal frameworks vis-a-via World Commission on Dams Strategic Priorities*. IUCN, Bangkok, Thailand and Gland, Switzerland.

United Nations, (1999). *Tourism Development in the Lao PDR*, Vientiane, Lao PDR.

Vietnam Environment Protection Agency, (2001), *Vietnam GEF biodiversity programme (2001-2005)*, Available online: http://www.nea.gov.vn/html/Quy_MT/GEF/Gef_ta/GEF_VN/Strategy_Program/biodiversity_programme.htm

Veng Sakhon, (2007). *Irrigation Development and Management in Cambodia: A Presentation on the Occasion of the First Cambodian Development Cooperation Forum held at Council for the Development of Cambodia from 19th to 20th June 2007*, Ministry of Water Resource and Meteorology, Phnom Penh, Cambodia.

Water Supply Authority (2004), *A.1 Summary Report-Building consensus for small town water supply management model in Lao PDR*, Vientiane, Lao PDR.

World Bank, (2008). *Lao Economic Monitor*, Vientiane, Lao PDR.

អំពីការបោះពុម្ពផ្សាយនេះ

នេះជាការបោះពុម្ពផ្សាយនៅក្នុងស៊េរីនៃការចេញផ្សាយ ពីកម្មវិធីពិគ្រោះយោបល់អំពីទឹកនៅក្នុងតំបន់ទន្លេមេគង្គ ។ ការចេញផ្សាយទាំងនេះមានគោលដៅជូនដំណឹងផ្លាស់ប្តូរ និងលើកកំពស់យុទ្ធសាស្ត្រ ដើម្បីអោយមានការគ្រប់គ្រងធនធានទឹកបានត្រឹមត្រូវ និងដោយនិរន្តរភាព នៅក្នុងតំបន់ទន្លេមេគង្គ ។

អំពីការពិគ្រោះយោបល់ស្តីពីទឹកនៅក្នុងតំបន់ទន្លេមេគង្គ

ការពិគ្រោះយោបល់ទឹកនៅក្នុងតំបន់ទន្លេមេគង្គ ធ្វើការសម្រួលឱ្យមានការធ្វើសេចក្តីសម្រេចដោយតម្លា ភាពនៅក្នុងតំបន់ទន្លេមេគង្គ ដោយជួយអោយមានការចូលរួមពីសំណាក់អ្នកពាក់ពន្ធ័នានា នៅក្នុងដំណើរការអភិបាលកិច្ចទឹក ។ កម្មវិធីនេះ តភ្ជាប់អភិបាលកិច្ចទឹកល្អ លើផ្នែកទឹក ជាមួយការចិញ្ចឹមជីវិតដោយនិរន្តរភាព និងការអភិរក្សប្រពន្ធ័អេកូឡូស៊ី ។ គម្រោងពិគ្រោះយោបល់ ស្តីពីទឹកនៅក្នុងតំបន់ទន្លេមេគង្គ បានទទួលមូលនិធិគាំទ្រពីក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ និងសម្របសម្រួលដោយកម្មវិធីទឹក និងតំបន់ ដីសើមប្រចាំតំបន់នៃការិយាល័យអង្គការ IUCN ប្រចាំនៅអាស៊ី ។ ការពិគ្រោះយោបល់អំពីទឹកនៅក្នុងតំបន់ទន្លេមេគង្គផ្តោតលើយន្តការនិរន្តរភាពនានា ដែល:

- កែលម្អដំណើរការធ្វើសេចក្តីសម្រេចនៅជុំវិញការវិនិយោគ នានាដែលទាក់ទងនឹងទឹកនៅក្នុងតំបន់ទន្លេ មេគង្គ
- ផ្តល់ឱកាសសម្រាប់ធុរកិច្ច រដ្ឋាភិបាល និងវិស័យឯកជន នៅក្នុងតំបន់ទន្លេមេគង្គ ដើម្បីចូលរួមនៅក្នុង ការពិគ្រោះយោបល់
- ជួយអោយមានទស្សនៈវិស័យខុសៗគ្នា អំពីការអភិវឌ្ឍដែលទាក់ទងនឹងទឹកនៅក្នុងតំបន់ទន្លេមេគង្គ ដើម្បីមានឥទ្ធិពលមកលើការធ្វើសេចក្តីសម្រេចនានា ។

IUCN Asia Regional Office
63 Sukhumvit Soi 39
Wattana, Bangkok
10110 Thailand
Tel: + 66 2 662 4029 ext. 142
Fax: + 66 2 662 4387
Email: iucn@iucnt.org

www.iucn.org/asia

International Union for Conservation of Nature